ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



◆ ខួបមួយឆ្នាំនៃការផ្តន្ទាទោស នួន ជា និង ខៀវ សំផន

◆ អំពើប្រល័យពូជសាសន៍ ៖ ការធ្វើទុកបុកម្នេញលើជនជាតិវៀតណាម

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ២១៥ ខែវិច្ឆិកា ឆ្នាំ២០១៧

# ស្វែងរកការពិត

លេខ២១៥ ខែវិច្ឆិកា ឆ្នាំ២០១៧

## ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា


◆ ខួបមួយឆ្នាំនៃការផ្តន្ទាទោស នួន ជា និង ខៀវ សំផន ......................១

### ផ្នែកឯកសារ

◆ ពង្រឹងការដឹកនាំ ដោយដោះស្រាយឲ្យចំទំនាស់ ...................................៣

◆ ចម្លើយសារភាពរបស់ ង៉ែត អឿង សមាជិកកងអនុសេនាធំ ................៨

### ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ

◆ ចូលរួមចលនាបដិវត្តន៍ដោយសារការបង្ខំ ........................................១៤

◆ អន្លង់វែង និងការផ្លាស់ប្តូរ .......................................................១៦

◆ ពែង រី អតីតកងទ័ពរដ្ឋាភិបាលដែលកម្ចាំង តាម៉ុក ចាប់ខ្លួនបញ្ជូន .......១៨

◆ ដួង ដុន អតីតពេទ្យខ្មែរក្រហម ...................................................១៩

◆ ឆាយ ស៊ិន អតីតនីរសារគណៈស្រុកចុងកាល់ .................................២០

◆ របបខ្មែរក្រហមបានធ្វើឲ្យ វ៉ាន់ បាត់បង់ មនុស្សជាទីស្រឡាញ់ ..........២៣

◆ ដំណើរទស្សកិច្ចទៅអន្លង់វែង ធ្វើឲ្យខ្ញុំចាប់អារម្មណ៍កាន់តែខ្លាំង.............២៥

◆ ខ្ញុំហៀបនឹងស្លាប់ដោយសារជំងឺ .................................................២៨

◆ ដំណើរជីវិតរបស់ ពាក់ ធឿន ......................................................៣០

### ផ្នែកច្បាប់

◆ មអំពើប្រល័យពូជសាសន៍: ការធ្វើទុកបុកម្នេញលើជនជាតិ ...............៣២

◆ សេចក្តីថ្លែងការណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ........................ ៣៨

◆ សេចក្តីថ្លែងការណ៍របស់សហព្រះរាជអាជ្ញាជាតិ................................៤៣

### វេទិកាពិភាក្សាសាធារណៈ

◆ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងទទួលបានការលើកទឹកចិត្ត .....................៤៥

### ទំព័រស្រាវជ្រាវរកគ្រួសារ

◆ ព្រលឹងមាសម្តាយ .......................................................................៤៩





## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ០២៩១ពម.៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩


រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង


**ស្នេរលេខនេះ** : ឆេង វ៉េង, ទូន ឡៃហុល, កុល ដាលីន, យាង សេងហៀន, ហួត សេងលីម, សយ ណាទ្រី, រិន រចនា, រ៉ូនិត អារី , អ៊ុង វណ្ណា **អ្នកនិពន្ធនិងស្រាវជ្រាវ** : ទាវ សារៈមុន្និន្ទ និង ហូ ថុនា **អ្នកបកប្រែ** : អ៊ួច គន្ធា **និពន្ធនាយកទូទៅ** : ឆាំង យុ **ជំនួយការនិពន្ធនាយក** : សោម ប៊ុនថន **ក្រាហ្វិកកុំព្យូទ័រ** : សោម ប៊ុនថន **គ្រប់គ្រងការចែកផ្សាយ** : សន ល័ក្ខ **Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org, khmerrougehistory.org www.truthcambodia.com**

# ខួបមួយឆ្នាំនៃការផ្តន្ទាទោស នួន ជា និង ខៀវ សំផន ៖ យុត្តិធម៌សម្រាប់ជនរងគ្រោះ

មកដល់ខែវិច្ឆិកា ឆ្នាំ២០១៧ មានរយៈពេលមួយឆ្នាំហើយ ចាប់តាំងពីអង្គជំនុំតុលាការកំពូល សម្រេចតម្កល់ការផ្តន្ទាទោស នួន ជា អតីតប្រធានសភាតំណាងប្រជាជននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និង ខៀវ សំផន ជាអតីតប្រមុខរដ្ឋនៅក្នុងរបបនេះ ឲ្យជាប់គុកមួយជីវិតចំពោះឧក្រិដ្ឋកម្ម ប្រឆាំងមនុស្សជាតិ ដែលក្នុងនោះមាន ការធ្វើមនុស្សឃាត ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងទៀត នៅក្នុងសំណុំរឿង០០២,១ ។ ចាប់តាំងពីបើកសវនាការដំបូង នៅឆ្នាំ ២០០៦ អង្គការជំនុំវិសាមញ្ញក្នុងតុលាការកម្ពុជា បានចោទប្រកាន់ និងដំណើរការ កាត់ក្តីជនសង្ស័យចំនួន៥នាក់ហើយ គឺ កាំង ហ្គេចអ៊ាវ អតីតប្រធានមន្ទីរសុខស-២១ (គុកទួលស្លែង) ក្នុងសំណុំរឿង០០១, ខៀវ សំផន និង នួន ជា ដោយឡែកជនជាប់ចោទ អៀង ធីរិទ្ធ អតីតរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច និង អៀង សារី អតីតរដ្ឋមន្ត្រីក្រសួងការបរទេស បានស្លាប់នៅអំឡុងពេលដំណើរកាត់ក្តី ។ បច្ចុប្បន្ន តុលាការបានបន្តស៊ើបអង្កេតនៅក្នុងសំណុំរឿង ០០៣ និង០០៤ នៅឡើយ ។ ក្នុងរយៈពេលជាង១០ឆ្នាំមកនេះ អង្គការជំនុំវិសាមញ្ញក្នុងតុលាការកម្ពុជាបានសម្រេចនូវយុត្តិធម៌សម្រាប់ជនរងគ្រោះពីរបបខ្មែរក្រហម និងបានប៉ះប៉ូវនូវរបួសផ្លូវចិត្តដល់អ្នកទាំងនេះបានមួយចំណែក ទោះបីតុលាការនេះមានដំណើរយឺតយ៉ាវ និងមានការខ្វែងគំនិតគ្នារវាងសហព្រះរាជអាជ្ញាចៅក្រមជាតិ និងអន្តរជាតិលើសំណុំរឿង០០៣ និង០០៤ ក៏ដោយ ។ ជាទូទៅនៅក្នុងដំណើរកាត់ ទោសពាក់ព័ន្ធនឹងបទឧក្រិដ្ឋធ្ងន់ធ្ងរ តុលាការមិនអាចសម្រេចយុត្តិធម៌ឲ្យបាន១០០ភាគរយ និងល្អឥតខ្ចោះនោះទេ ប៉ុន្តែតុលាការត្រូវគិតទៅដល់ ថាតើជនរង


ខៀវ សំផន និង នួន ជា នៅបន្ទប់សាវនាការ សំណុំរឿង០០២ (រូបថត ៖ អ.វ.ត.ក)

គ្រោះមានសំឡេងក្នុងដំណើរការក្ដីដែររឺទេ រឿងរ៉ាវរបស់គាត់ត្រូវបានទទួលស្គាល់ ហើយយុត្តិធម៌កម្រិតណាដែលគាត់អាចទទួលយកបាន ។ ការរួមចំណែករបស់ជនរងគ្រោះ មិនត្រឹមតែជាដំណើរការប្រកបដោយយុត្តិធម៌ប៉ុណ្ណោះទេ ប៉ុន្តែនឹងជំរុញឲ្យមានការបង្ហាញ និងដំណើរការផ្សះផ្សារជាតិទូលំទូលាយ បន្ទាប់ពីតុលាការបិទបញ្ចប់ទៅថ្ងៃខាងមុខ ។

ពៅ ភារុណ អាយុ៧៦ឆ្នាំ រស់នៅខេត្តបាត់ដំបង ដែលធ្លាប់បានតាមដានដំណើរការកាត់ ក្ដីមេដឹកនាំខ្មែរក្រហម និងធ្លាប់បំពេញពាក្យបណ្ដឹងប្ដឹង កាំង ហ្កេចអ៊ាវ ហៅ ឌុច អតីតប្រធានមន្ទីរស-២១ នៅក្នុងសំណុំរឿង០០១ បានមានប្រសាសន៍ថា “ការកាត់ទោសមេដឹកនាំខ្មែរក្រហម ទាំងនេះ ហាក់ដូចជាយូរបន្តិចសម្រាប់គាត់ដែលជាអ្នករង់ចាំ និងដែលមានវ័យកាន់តែចាស់ជរា ប៉ុន្តែ ទោះបីយ៉ាងណា ក៏ការកាត់ទោសនេះបានបង្ហាញពីការខិតខំប្រឹងប្រែងរបស់តុលាការក្នុងការកាត់ទោស រឿងរ៉ាវដែលបានកើតឡើងយូរឆ្នាំមកហើយដែរ ។ ភារុណ បានរៀបរាប់ថា ប្ដីរបស់គាត់ដែលជាអ្នកបើករថភ្លើងនៅបាត់ដំបង ត្រូវខ្មែរក្រហមយកទៅសម្លាប់ដោយមិនដឹងមូលហេតុ រួមជាមួយបងប្អូន សាច់ញាតិក្នុងភូមិប្រមាណជាង៥០នាក់ទៀត ។ ភារុណ បានបន្តថា នៅពេលរំពុកពីរបបខ្មែរក្រហម គាត់តែងតែស្រក់ទឹកភ្នែកដោយស្រណោះប្ដីដែលបែកពីគាត់ ពេលគាត់កំពុងមានជំងឺ និងសម្រាកនៅមន្ទីរពេទ្យខេត្តបាត់ដំបង ។ ភារុណ បានបញ្ជាក់ថា រហូតមកដល់សព្វថ្ងៃគាត់មិនចង់ចងពៀរជាមួយ មេដឹកនាំខ្មែរក្រហមទាំងនេះទេ ប៉ុន្តែគាត់ចង់ឲ្យមេដឹកនាំនេះទទួលផលកម្មទៅតាមអំពើដែលខ្លួនបានប្រព្រឹត្ត” ។

នួន សាវុធ រស់នៅខេត្តកំពង់ឆ្នាំង មានប្រសាស៍ថា “គាត់ធ្លាប់បានចូលដំណើរការកាត់ទោសនៅសាលាក្ដីខ្មែរក្រហម ហើយគាត់ពេញចិត្តនឹងការកាត់ទោសមេដឹកនាំខ្មែរក្រហមឲ្យជាប់គុកអស់មួយជីវិត” ។ សាវុធ បានរៀបរាប់ថា គាត់កំព្រាឪពុកម្ដាយតាំងពីវ័យក្មេង ដោយឪពុករបស់គាត់ត្រូវខ្មែរក្រហមសម្លាប់ដោយចោទថា សេ.អ៊ី.អា រីឯម្ដាយស្លាប់ដោយសារអត់អាហារ ហើយបងប្អូន៤នាក់ទៀត ក៏ត្រូវខ្មែរក្រហមសម្លាប់ដែរ ។ គាត់បានរស់នៅក្នុងស្ថានភាពលំបាកដោយសារមិនមានឪពុកម្ដាយថែទាំ ។ មកដល់សព្វថ្ងៃ គាត់នៅសល់បងប្អូនបង្កើតបីនាក់ប៉ុណ្ណោះដែលនៅរស់ជីវិត ។ សាវុធ យល់ឃើញថា គាត់ទទួលយុត្តិធម៌ដោយសារតុលាការកាត់ទោសមេដឹកនាំឲ្យជាប់គុកអស់មួយជីវិត ហើយគាត់ក៏សំណូមឲ្យតុលាការផ្ដោតទៅលើទស្សនយល់ឃើញរបស់ជនរងគ្រោះដែរ ។

**សោម ប៊ុនថន**



សាលសវនាការនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (រូបថត : អ.វ.ត.ក)

# ពង្រឹងការដឹកនាំ ដោយដោះស្រាយឱ្យចំទំនាស់

***ដកស្រង់ចេញឯកសារទង់បដិវត្តន៍លេខ៧ ខែកក្កដា ឆ្នាំ១៩៧៨ D២១៤២៩***

ក្នុងការដឹកនាំ បើដោះស្រាយចំទំនាស់ គឺការដឹកនាំខ្លាំង ទោះជាមានកម្លាំងតិចក្តី ឬទោះជាមានសភាពការណ៍ស្មុគស្មាញយ៉ាងណាក្តី ។

ផ្ទុយទៅវិញ បើដោះស្រាយមិនចំទំនាស់ ទោះជាមានកម្លាំងច្រើនយ៉ាងណាក្តី ឬសភាពការណ៍អំណោយយ៉ាងណាក្តី ការដឹកនាំនោះមិនខ្លាំងទេ ។

ការងារតូចក៏មានទំនាស់ ។ ការងារធំក៏មានទំនាស់ ។ ក្នុងសភាពការណ៍លំបាកក៏មានទំនាស់ ក្នុងសភាពការណ៍ស្រួលក៏មានទំនាស់ នៅទីកន្លែងណាក៏មានទំនាស់ ។ ដូច្នេះ មិនមានអ្វីចម្លែកទេ ។ បញ្ហាសំខាន់នៅត្រង់រកទំនាស់ឲ្យឃើញ ។ រកឲ្យឃើញទំនាស់ជាមូលដ្ឋាន ទំនាស់ជាគន្លឹះ ។ យើងរកទំនាស់ឲ្យឃើញ ដើម្បីលើកវិធានការដោះស្រាយទំនាស់ឲ្យចំ ជំរុញការងារឲ្យកាន់តែខ្លាំងក្លាថែមទៀត ។

បញ្ហានេះ ជាកត្តាសំខាន់ណាស់ក្នុងការដឹកនាំបដិវត្តន៍ ព្រោះបើការងារមានគុណវិបត្តិច្រើន លើកវិធានការដោះស្រាយមិនចេះត្រូវ នាំឲ្យយឺតដំណើរបដិវត្តន៍ ។ ដំណើរបដិវត្តន៍ក៏យឺត កម្លាំងក៏ខាតបង់ ទុនជាសម្ភារផ្សេងៗរបស់បក្ស របស់បដិវត្តន៍ក៏ត្រូវខូចខាត ។ ការពារប្រទេសមិនខ្លាំង ។ ធ្វើបដិវត្តន៍សង្គមនិយមមិនជ្រៅ ។ កសាងសង្គមនិយមមិនខ្លាំង ។ ដោះស្រាយជីវភាពប្រជាជនមិនបានតាមបក្សកំណត់ ។ល ។ ឧទាហរណ៍ អង្គភាពយោធាមួយ វាយខ្មាំងយួនឈ្លានពានមិនខ្លាំង ។ វាយខ្មាំងមិនខ្លាំង ជាគុណវិបត្តិ ជាទំនាស់ ។ តើមូលហេតុមកពីអ្វី? នេះជាចំណុចទំនាស់ដែលត្រូវរកដើម្បីដោះស្រាយ ។ ទំនាស់វាមានច្រើន អាចមកពីគោលជំហរនយោបាយ សតិអារម្មណ៍ចាត់តាំង អាចមកពីបញ្ញាការ



រូបទីពីររាប់ពីស្តាំ ៖ នួន ជា បងធំទី២ និងជាប្រធានសភាប្រជាជន ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩) ទស្សនកិច្ចនៅការដ្ឋានសាងសង់ស្ពាន ។

ឬអាចមកពីមានខ្ទាំងបង្កប់ស៊ីរូងផ្ទៃក្នុង ។ យើងត្រូវរកទំនាស់ជាគន្លឹះឲ្យឃើញ ។ ជួនកាលមកពីមានខ្ទាំងបង្កប់ស៊ីរូងផ្ទៃក្នុងដែលជាទំនាស់ជាគន្លឹះ តែយើងរកមិនឃើញ ។ យើងដោះស្រាយតែខាងគោលជំហរនយោបាយ សតិអារម្មណ៍ ចាត់តាំង ដោយអនុវត្តធ្វើជីវទស្សនបដិវត្តន៍ ទិតៀន ស្វ័យទិតៀន ។ យ៉ាងនេះ ដោះស្រាយមិនរួច ព្រោះរកទំនាស់ជាគន្លឹះមិនឃើញ វាយខ្ទាំងនៅតែមិនខ្ទាំង ។ ការងារច្រើន ការស្មុគស្មាញ បត់បែន ការលំបាក ការស្រួល គុណសម្បត្តិ គុណវិបត្តិ ក៏ច្រើនទៅតាមនោះ ។ ដូច្នេះ ដើម្បីរកទំនាស់ជាគន្លឹះរបស់ការងារមួយៗឲ្យឃើញ ដើម្បីលើកវិធានការដោះស្រាយឲ្យចំទំនាស់ តើត្រូវធ្វើយ៉ាងណា?

ការងារដែលត្រូវធ្វើគឺគ្មានអ្វីថ្មីទេ ។ ថ្មីតែត្រង់មិនទាន់ធ្វើ ឬមិនសូវធ្វើ ឬក៏ធ្វើខុស ។ ដូច្នេះ យើងលើកឡើងនូវការងារខ្លះខាងក្រោមនេះ ដើម្បីរម្លឹកគ្នាប៉ុណ្ណោះ ។

## ១) ត្រូវចុះដល់មូលដ្ឋាន

ចង់រកឃើញការពិតជាក់ស្តែង ត្រូវចុះដល់មូលដ្ឋានខាងក្រោម ។ អង្គុយនៅមួយកន្លែង រកការពិតជាក់ស្តែងមិនឃើញទេ គឺរកទំនាស់ជាគន្លឹះមិនឃើញ មូលដ្ឋានខាងក្រោមជាកន្លែងប្រយុទ្ធជាក់ស្តែង ។ គុណសម្បត្តិក៏មានច្រើន ការខ្វះខាតក៏មានច្រើន ។ ទំនាស់ច្រើនជ្រុងជ្រោយកើតនៅមូលដ្ឋានខាងក្រោម ។ ដូច្នេះ ទាល់តែចុះទៅដល់មូលដ្ឋានខាងក្រោម ទើបឃើញបញ្ហាច្រើន ឃើញបញ្ហាជាគន្លឹះ ឃើញបញ្ហាធម្មតា ឃើញបញ្ហាត្រូវដោះស្រាយចំពោះមុខ ឃើញបញ្ហាត្រូវដោះស្រាយជាមូលដ្ឋាន ។ល ។

តើចុះទៅមូលដ្ឋានខាងក្រោម ដូចជាចុះដល់សហករណ៍ ដល់សហជីពដល់ការដ្ឋានដល់រោងចក្រ ។ល ។ ត្រូវក្តាប់កត្តាអ្វីដែលដើរតួជាងគេ? ត្រូវក្តាប់កត្តាពីរជាមូលដ្ឋាន ដើម្បីរកទំនាស់ ។ គឺមួយត្រូវក្តាប់កត្តាបក្សដឹកនាំ ពីរត្រូវក្តាប់កត្តាមហាជន ។

អំពីកត្តាបក្ស ត្រូវយល់អំពីសភាពការណ៍របស់សាខានៅមូលដ្ឋាននោះ ។ យល់អំពីសមាសភាពនយោបាយ សតិអារម្មណ៍ ចាត់តាំង ។ យល់អំពីសមាសភាពរបស់គណកម្មាធិការសាខាបក្ស ។ យល់អំពីសមាសភាពរបស់បក្ខជន ។ យល់អំពីសភាពការណ៍ដឹកនាំរបស់សាខាបក្សនោះយ៉ាងណា ។ បានសេចក្តីថា ស្វែងរកយល់ថា តើនៅក្នុងបញ្ហាបក្សដឹកនាំមានទំនាស់អ្វីខ្លះ? ទំនាស់អ្វីជាគន្លឹះ ។

អំពីកត្តាមហាជន ត្រូវយល់អំពីសភាពការណ៍នយោបាយ សតិអារម្មណ៍ ចាត់តាំង យល់អំពីជីវភាពរបស់មហាជន ។ យល់អំពីសមាសភាពវណ្ណៈក្នុងមហាជន ។ យល់អំពីសំណូមពររបស់មហាជន ។ យល់អំពីចលនារបស់មហាជន ។ បានសេចក្តីថា ស្វែងរកយល់ថា តើនៅក្នុងមហាជនមានទំនាស់អ្វីខ្លះ? ទំនាស់គឺជាគន្លឹះ ។ ដូច្នេះ ចង់ដោះស្រាយទំនាស់ឲ្យចំ ត្រូវចុះដល់មូលដ្ឋានខាងក្រោម ។ ចុះទៅមូលដ្ឋានខាងក្រោម រកឲ្យឃើញទំនាស់ជាគន្លឹះនៅក្នុងបក្សដឹកនាំ និងនៅក្នុងមហាជនជាសំខាន់ ដើម្បីលើកវិធានការដោះស្រាយ ។

## ២) រាយការណ៍ឲ្យបានត្រឹមត្រូវ

ដើម្បីដោះស្រាយទំនាស់ឲ្យចំ ត្រូវរាយការណ៍ឲ្យបានត្រឹមត្រូវ ។ កុំរាយការណ៍បំផ្លើសពីគុណសម្បត្តិ ។ មានគុណសម្បត្តិប៉ុណ្ណារាយការណ៍ឲ្យត្រឹមត្រូវ ។ កុំលាក់គុណវិបត្តិ ។ មានគុណវិបត្តិប៉ុន្មានរាយការណ៍ឲ្យអស់ ។ ដូច្នេះ តាមទាន់នូវស្មារតីស្មោះត្រង់របស់អ្នករាយការណ៍ ។

សមមិត្តយើងខ្លះមិនទាន់ឃើញពីគ្រោះថ្នាក់ ដែលកើតមកពីការរាយការណ៍មិនត្រូវតាមការពិត ឬរាយកាណ៍មិនអស់សេចក្តី ។ ការរាយការណ៍មិនបានត្រឹមត្រូវ ធ្វើឲ្យការដឹកនាំមានការខុសឆ្គង ។ មួងខុសឆ្គងបន្តិច មួងខុសឆ្គងបន្តិច យូរៗទៅកាន់តែច្រើន ។ ការអនុវត្តកាន់តែរវាតចេញពីមាគ៌ារបស់បក្ស ។ ថ្នាក់ដឹកនាំក្តាប់ការពិតមិនបាន ក្តាប់ទំនាស់មិនបាន ដូច្នេះ អាចបណ្តាលឲ្យការដឹកនាំទន់ខ្សោយចុះដាលំដាប់ ប៉ះពាល់ដល់ចលនា ប៉ះពាល់ដល់ផលប្រយោជន៍បក្ស បដិវត្តន៍ និងមហាជន ។

ដើម្បីពង្រឹងការដឹកនាំ ដោះស្រាយទំនាស់ឲ្យចំ ត្រូវកម្ចាត់របៀបរាយការណ៍មិនត្រឹមត្រូវ ជំរុញរបៀបរបបរាយការណ៍ដែលស្មោះត្រង់ មិនបន្ថែមគុណសម្បត្តិ មិនលាក់គុណវិបត្តិ ។ ធ្វើបានប៉ុណ្ណារាយការណ៍ប៉ុណ្ណឹង ។

## ៣) អនុវត្តប្រជាធិបតេយ្យប្រមូលផ្តុំឲ្យបានល្អ និងផ្អែកលើមហាជន

ម្នាក់ឯងមិនសូវមានសមត្ថភាព ដើម្បីរកទំនាស់ជាគន្លឹះ និងដោះស្រាយទំនាស់បានល្អទេ ។ ដើម្បីរកទំនាស់ជាគន្លឹះឲ្យបានចំ

ដោះស្រាយឲ្យបានល្អ ត្រូវអនុវត្តប្រជាធិបតេយ្យប្រមូលផ្តុំឲ្យបានល្អ ។

មានសមមិត្តយើងខ្វះអត្តនោម័តិ មិនចង់ឲ្យសមមិត្តយើងមានមតិឲ្យធំទូលាយ គឺខ្វះប្រជាធិបតេយ្យ ។ មានបញ្ហាស្មុគស្មាញអ្វីកើតឡើង ដោះស្រាយតាមតែមតិខ្លួនម្នាក់ ឬក៏ចាំសួរតែថ្នាក់លើតែម្តង ។ ការដោះស្រាយរបៀបនេះ គឺមិនផ្អែកលើមហាជន ។ ការដោះស្រាយទំនាស់ដោយមិនអនុវត្តតាមលាក់ការណ៍ប្រជាធិបតេយ្យប្រមូលផ្តុំ ឬមិនផ្អែកលើមហាជន ទោះជាដោះស្រាយត្រូវក៏មិនខ្លាំង ព្រោះមហាជនមិនបានចូលរួមពិភាក្សា មិនបានចូលរួមដោះស្រាយ ។ បើអនុវត្តតាមលាក់ការណ៍ប្រជាធិបតេយ្យប្រមូលផ្តុំ ឬផ្អែកលើមហាជនដោះស្រាយមិនចំទំនាស់ ក៏មហាជនមានពិសោធ ថ្ងៃក្រោយមុខជាដោះស្រាយត្រូវ ។ បើដោះស្រាយទំនាស់ចំវិញ ក៏មហាជនមានពិសោធល្អ កាន់តែយល់ដឹងបញ្ហា ការដឹកនាំកាន់តែខ្លាំង កាន់តែមានប្រសិទ្ធភាពល្អ ។

ដើម្បីដោះស្រាយទំនាស់ឲ្យចំ ដឹកនាំបានខ្លាំង ត្រូវអនុវត្តប្រជាធិបតេយ្យប្រមូលផ្តុំ និងផ្អែកលើមហាជន ។ ដើម្បីពង្រឹងការដឹកនាំរកទំនាស់គន្លឹះឲ្យឃើញ ដោះស្រាយទំនាស់ឲ្យបានល្អ ត្រូវយកចិត្តទុកដាក់ធ្វើការងារមួយចំនួនដូចពោលខាងលើជាប្រចាំ ហើយធ្វើឲ្យបានល្អ ។

## ជ័យជម្នះមួយជំហានទៀតរបស់សហករណ៍យើង

ក្នុងដំណាក់កាលថ្មី នៃបដិវត្តន៍សង្គមនិយមបីឆ្នាំកន្លងមកនេះ សហករណ៍បានពង្រឹង និងពង្រីកជាលំដាប់ ក្នុងមហាចលនាការពារប្រទេស កម្ចាត់ខ្មាំងយួនឈ្លានពានវាតទីលេបទឹកដី មហាចលនាធ្វើបដិវត្តន៍សង្គមនិយម និងមហាចលនាកសាងសង្គមនិយម លើកតម្កើងជីវភាពប្រជាជន ។

ខាងផ្នែកចាត់តាំង សហករណ៍បានពង្រឹងអង្គភាពចាត់តាំងរបស់ខ្លួនមកដល់១០០០គ្រួសារ ជាអង្គភាពសហករណ៍មួយ ។ ក្នុងអង្គភាពសហករណ៍មួយៗ កាន់តែបានពង្រីកផ្នែកផ្សេងៗទៀត ដូចជា សិប្បកម្ម ចិញ្ចឹមសត្វ សង្គមកិច្ច ពេទ្យ វប្បធម៌ ។ល ។

ការរីកចម្រើនខាងផ្នែកចាត់តាំងទាំងនេះ បានប្រព្រឹត្តទៅលើមូលដ្ឋាននៃស្មារតីឯករាជ្យម្ចាស់ការ ខ្លួនឧបត្ថម្ភខ្លួនជាអតិបរមា ។ ព្រមជាមួយគ្នានេះ ក៏មានការសហការជួយឧបត្ថម្ភគ្នាទៅវិញទៅមក រវាងសហករណ៍មួយ និងសហករណ៍មួយទៀត ។ ជាពិសេសថែមទៀត ក្នុងមហាចលនាមហាជន វាយកម្ទេចខ្មាំងយួនឈ្លានពាន វាតទីលេបទឹកដី បំបាត់ពូជសាសន៍ និងក្នុងមហាចលនាមហាជនបោសសម្អាតខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង ជាភ្នាក់ងារ សេ.អ៊ី.អា ភ្នាក់ងារឆ្កែបម្រើយួន និងភ្នាក់ងារ កា.ហ្សេ.បេ សហករណ៍ទូទាំងប្រទេសបានដើរតួយ៉ាងសំខាន់ក្នុងការធ្វើសកម្មភាពបំពេញភារកិច្ចរបស់ខ្លួន នាំមកនូវជ័យជម្នះជាយុទ្ធសាស្ត្រជូនជាតិ ប្រជាជន បក្ស និងបដិវត្តន៍ ។


កម្មាភិបាលខ្មែរក្រហម នៅមូលដ្ឋាន

គឺក្នុងមហាចលនានេះហើយ ដែលគោលជំហរនយោបាយ សតិអារម្មណ៍ ចាត់តាំងរបស់សមាជិកសហករណ៍ទាំងអស់ បានរីកចម្រើនធំធាត់ជាបណ្តើរៗ តាមគោលជំហរបដិវត្តន៍នៃវណ្ណៈអធន និងតាមមាគ៌ានយោបាយធ្វើបដិវត្តន៍សង្គមនិយម របស់បក្សកុម្មុយនីស្តកម្ពុជាយើង ។

អំពើឈ្លានពាន វាតទី លេបទឹកដី និងបំបាត់ពូជសាសន៍កម្ពុជាយ៉ាងកាចសាហាវរបស់ខ្មាំងយួន

និងសកម្មភាពក្បត់ជាតិ បំផ្លាញបដិវត្តន៍ បំផ្លាញជីវភាពរបស់ប្រជាជនរបស់ខ្មាំងបក្កប់ស៊ីរូងផ្ទៃក្នុង ជាភ្នាក់ងារ សេ.អ៊ី.អា ភ្នាក់ងារផែ្កបម្រើយួន និងភ្នាក់ងារ កា.ហ្សេ.បេ បានដុតភ្លើងកំហឹងជាតិ និងកំហឹងវណ្ណៈ យ៉ាងឆាបឆេះដល់សមាជិកសហករណ៍ទាំងអស់ ។ ភ្លើងកំហឹងជាតិ និងភ្លើងកំហឹងវណ្ណៈនេះ បានប្រែក្លាយទៅជាមហាចលនាកម្ចាត់ខ្មាំងយួនឈ្លានពាន វាតទី លេបទឹកដី និងបោសសម្អាតខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង យ៉ាងធំទូលាយ ។

ដោយសមាជិកសហករណ៍ទាំងអស់ មានថ្វីដៃប្រយុទ្ធ និងថ្វីដៃបង្កើនផល ហើយដើម្បីជំរុញមហាចលនាប្រយុទ្ធកម្ចាត់ខ្មាំងយួនឈ្លានពាន វាតទីលេបទឹកដី និងបោសសម្អាតខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុងឲ្យកាន់តែស្អាតថែមទៀត តាមមាគ៌ាដ៏ត្រឹមត្រូវរបស់បក្សយើង និងជំរុញចលនាបង្កើនផលឲ្យខ្លាំងក្លា បក្សយើងបានសម្រេចលើកគុណភាពរបស់មិត្តទាំងអស់នៅក្នុងសហករណ៍ ជាសមាជិកសហករណ៍ទាំងអស់គ្នា ។ នេះជាជ័យជម្នះមួយដ៏ហានសំខាន់ទៀតរបស់សហករណ៍ ។

សូមបញ្ជាក់ថា ពីមុខសមាជិកសហករណ៍មានបីប្រភេទ គឺប្រភេទពេញសិទ្ធិ ប្រភេទត្រៀម និងប្រភេទផ្ញើ ។ តែចាប់តាំងពីពេលនេះទៅ គឺទាំងអស់គ្នា ជាសមាជិកសហករណ៍ដូចគ្នាទាំងអស់ ។ មិនមានប្រភេទត្រៀម ឬប្រភេទផ្ញើទៀតទេ ។ ចំពោះការជ្រើសរើសគណៈកម្មាធិការសហករណ៍ ត្រូវផ្អែកតាមលក្ខណៈដប់យ៉ាងរបស់បក្ស ក្នុងការវិនិច្ឆ័យកម្មាភិបាលគឺ ៈ

**១) គោលជំហរបដិវត្តន៍រឹងប៉ឹង ខាងមាគ៌ានយោបាយរបស់បក្ស**

ត្រូវមានជំហរនយោបាយត្រឹមត្រូវ និងរឹងប៉ឹងជាលំដាប់មិនស្តាំ "មិនឆ្វេង" ក្នុងការបំពេញភារកិច្ចនយោបាយជាក់ស្តែងរបស់បក្ស ដែលខ្លួនអនុវត្តជាបន្តបន្ទាប់ ហើយពិសេសក្នុងកិច្ចការពារប្រទេស និងកសាងប្រទេសកម្ពុជាប្រជាធិបតេយ្យ ក្នុងរយៈកាលបដិវត្តន៍សង្គមនិយម និងការកសាងសង្គមនិយមបច្ចុប្បន្ននេះ ។

**២) ជំហរបដិវត្តន៍រឹងប៉ឹង ខាងសតិអារម្មណ៍អធនរបស់បក្ស**

ត្រូវមានជំហរសតិអារម្មណ៍វណ្ណៈអធនត្រឹមត្រូវ និងរឹងប៉ឹងលើគ្រប់ផ្នែក សម្ភារ សិទ្ធិអំណាច និងសីលធម៌រស់នៅ ។

មានជំហរកម្មសិទ្ធិសមូហភាពត្រឹមត្រូវ និងរឹងប៉ឹងគ្រប់ផ្នែកសម្ភារ សិទ្ធិអំណាច និងសីលធម៌រស់នៅ ហើយរស់នៅតាមរបបចាត់តាំងសមូហភាព ។

មានជំហរលះបង់កម្មសិទ្ធិស្ទួនតួខ្លួស់ និងដាច់ខាតគ្រប់ផ្នែកសម្ភារ សិទ្ធិអំណាច និងសីលធម៌រស់នៅ ។

មានជំហរប្រយុទ្ធមោះមុត សកម្ម ទ្រាំទ្រលំបាកវេទនាគ្រប់កាលៈទេសៈក្នុងការតស៊ូវណ្ណៈដាច់ខាត ក្នុងកិច្ចការពារប្រទេស និងកសាងប្រទេសកម្ពុជាប្រជាធិបតេយ្យ តាមទិសបដិវត្តន៍សង្គមនិយម និងការកសាងសង្គមនិយម ។

ប្រយ័ត្នបំផុត ជំហរកម្មសិទ្ធិបុគ្គល ស្ទួនតួ ឯកជនក្រាស់ខាងសម្ភារ សិទ្ធិអំណាច និងសីលធម៌រស់នៅ ។

**៣) ជំហរបដិវត្តន៍រឹងប៉ឹង ខាងសាមគ្គីភាព ឯកភាពផ្ទៃក្នុងរបស់បក្ស**

ត្រូវមានជំហរ អត្តចរិត ស្មារតី និស្ស័យ និងសកម្មភាពថែរក្សា ការពារ កសាង ពង្រឹង និងពង្រីកសាមគ្គីភាព ឯកភាពផ្ទៃក្នុងរបស់បក្សជាប់ជានិច្ច តាមជំហរនយោបាយ សតិអារម្មណ៍ និងចាត់តាំងរបស់បក្ស ហើយមានលក្ខណៈសាមគ្គីបានជាមួយភាគច្រើនដាច់ខាត ពី៩៥ ដល់១០០ភាគរយ ដោយមហាជនទទួលទំនុកទុកចិត្តកក់ក្តៅ ស្រឡាញ់ ពេញចិត្ត ក្នុងក្របខណ្ឌទូទៅក្តី ។

ប្រយ័ត្នបំផុតចំពោះជំហរ អត្តចរិត ស្មារតី និស្ស័យ និងសកម្មភាពប្រឆាំង និងវាយប្រហារបក្ស សមមិត្តផងគ្នា ដោយគោលជំហរ កម្មសិទ្ធិ បុគ្គល ស្ទួនតួ និងបក្ខពួក ។

**៤) ជំហរបដិវត្តន៍រឹងប៉ឹង ខាងមាគ៌ាចាត់តាំងដឹកនាំ និងធ្វើការងាររបស់បក្ស**

ត្រូវមានជំហរមាគ៌ាចាត់តាំងរបស់បក្សត្រឹមត្រូវ និងរឹងប៉ឹង ។ ត្រូវមានជំហរប្រជាធិបតេយ្យប្រមូលផ្តុំ ទស្សនមហាជនមាគ៌ាមហាជន និងមាគ៌ាវណ្ណៈរបស់បក្សត្រឹមត្រូវ និងរឹងប៉ឹង ។

ត្រូវមានជំហរដឹកនាំធ្វើការងារដោយសមូហភាពត្រឹមត្រូវ និងរឹងប៉ឹង ហើយនិងជំហរទទួលខុសត្រូវភារកិច្ច និងអនុវត្តភារកិច្ចដោយខ្លែកខ្ពស់ ។

ត្រូវមានគោលជំហរ និងអាកប្បកិរិយាដឹកនាំធ្វើការងារជាប់មហាជនក្នុងសហជីព សហករណ៍ និងកងទ័ពបដិវត្តន៍ មានគំនិត

ផ្ដើមច្នៃប្រឌិតម្ចាស់ការ ស៊ុះស្មាញ និងវាយសម្រុកក្ដៅជាប់ ។

ប្រយ័ត្នបំផុតគោលជំហរ និងអកប្បកិរិយាធ្វើការងារបែប ការិយាល័យនិយម សេរីនិយម ឯកចិត្តនិយម អត្តនោម័តិនិយម បែបមិនទទួលខុសត្រូវអ្វីទាំងអស់ ចំពោះបក្ស បដិវត្តន៍ និង ប្រជាជន ។

### ៥) ជំហរបដិវត្តន៍រឹងប៉ឹង ខាងការប្រុងប្រយ័ត្នបដិវត្តន៍ របស់បក្ស រក្សាការពារសម្ងាត់ និងការពារកម្លាំងបដិវត្តន៍

ត្រូវមានជំហរប្រុងប្រយ័ត្នបដិវត្តន៍ រក្សាការសម្ងាត់ និង ការពារកម្លាំងបដិវត្តន៍ត្រឹមត្រូវ និងរឹងប៉ឹង គ្រប់កាលៈទេសៈ និង គ្រប់អំពើប្រព្រឹត្ត ធ្វើការងារ និយាយស្ដី អាកប្បកិរិយា ការរស់ នៅគ្រប់បែបយ៉ាងចំពោះមុខ និងយូរអង្វែងក្នុងបក្ស និងក្រៅបក្ស ។ ប្រយ័ត្នបំផុត សេរីនិយម និងគោលជំហរមិនទទួលខុសត្រូវ ចំពោះ ការប្រុងប្រយ័ត្នបដិវត្តន៍ ការពារសម្ងាត់ ការពារកម្លាំងបដិវត្តន៍ ដែលចេញជាអំពើប្រព្រឹត្តធ្វើការងារ និយាយស្ដី អាកប្បកិរិយា និងការរស់នៅ ។

### ៦) ជំហរបដិវត្តន៍រឹងប៉ឹង ខាង "ឯករាជ្យម្ចាស់ការ ខ្លួនទីពឹង ខ្លួន និងខ្លួនធ្វើម្ចាស់លើខ្លួនឯង" របស់បក្ស

ត្រូវមានជំហរ "ឯករាជ្យម្ចាស់ការ ខ្លួនទីពឹងខ្លួន និងខ្លួនធ្វើ ម្ចាស់លើខ្លួនឯង" ខ្ពស់ការបំពេញភារកិច្ចផ្សេងៗ របស់បក្សលើគ្រប់ ផ្នែកទាំងអស់ និងគ្រប់កាលៈទេសៈ ។

### ៧) ជំហរបដិវត្តន៍រឹងប៉ឹង ខាងការធ្វើ និងត្រួតពិនិត្យប្រវត្តិ រូប និងជីវទស្សនបដិវត្តន៍

ត្រូវមានគោលជំហរបដិវត្តន៍ត្រឹមត្រូវ និងរឹងប៉ឹងដោយ ស្មារតីទទួលខុសត្រូវខ្ពស់ ក្នុងការធ្វើការត្រួតពិនិត្យ និងកសាង ប្រវត្តិរូបបដិវត្តន៍ ជីវទស្សនបដិវត្តន៍របស់ខ្លួន ជាបន្តបន្ទាប់ ។

ត្រូវស្មោះត្រង់ ក្នុងការត្រួតពិនិត្យ ប្រវត្តិរូបជីវទស្សន បដិវត្តន៍របស់ខ្លួន ហើយនិងក្នុងការកែប្រែគុណវិបត្តិតូចធំរបស់ខ្លួន ដាច់ខាត ហើយជំរុញការកសាង ពង្រឹងពង្រីកគុណសម្បត្តិរបស់ ខ្លួន ឲ្យរីកចម្រើនឆាប់រហ័សជាបន្តបន្ទាប់ ។

### ៨) ជំហរបដិវត្តន៍រឹងប៉ឹង ខាងវណ្ណៈភាព

ត្រូវមានវណ្ណៈភាពល្អ ជាវណ្ណៈដើម ហើយជាពិសេស ជា ជំហរវណ្ណៈកម្មកររបស់បក្ស ដែលខ្លួនបានខំកសាង ជាបន្តបន្ទាប់ ក្នុងចលនាបដិវត្តន៍ ដែលបក្សដឹកនាំ ។

### ៩) ជំហរបដិវត្តន៍រឹងប៉ឹង ខាងសីលធម៌រស់នៅស្អាតស្អំ និង ស្អាតស្អំខាងនយោបាយ

ត្រូវមានសីលធម៌រស់នៅល្អ ស្អាតស្អំ ត្រឹមត្រូវ មិនពុក រលួយ ពាលាអាវ៉ាសែ ហើយមិនជំពាក់ជំពិនជាមួយខ្មាំង ។ ប្រយ័ត្ន បំផុតចំពោះប្រភេទ សេរីនិយម ខាងការរស់នៅ ។

### ១០) លទ្ធភាពកសាងខ្លួន និងទទួលនាទីដឹកនាំទៅអនាគត

ត្រូវពិនិត្យមើលតាមលក្ខណៈសម្បត្តិ នយោបាយ សតិអា រម្មណ៍ សាមគ្គីភាព ឯកភាព ចាត់តាំង ដឹកនាំធ្វើការងារ ។ល។ ដែលសាមីខ្លួនមានពីពេលមុន និងពេលបច្ចុប្បន្ន តើលទ្ធភាពកសាង ខ្លួន ឲ្យចម្រើនជឿនលឿនទៅមុខបានយ៉ាងណា ហើយនិងលទ្ធភាព ទទួលខុសត្រូវ ដឹកនាំទៅអនាគតបានយ៉ាងណា ។

ក្នុងការអនុវត្តជាក់ស្ដែង យើងមិនអាចរកឲ្យបានគ្រប់ទាំង "១០ខ" នេះទេ តែត្រូវថ្លឹងថ្លែង ប្រៀបធៀបឲ្យបានល្អ ជាអតិ បរិមា ។ ក្នុង១០ខនេះ យកចិត្តទុកដាក់ក្ដាប់ ខទី១-២-៣-និង៤ ជាសំខាន់ ព្រោះជាខមូលដ្ឋាន និងគន្លឹះ ។ ព្រមជាមួយគ្នានេះដែរ ក៏ត្រូវក្ដាប់ និងស្គាល់ប្រវត្តិរូបឲ្យបានច្បាស់លាស់ ជាខ្សែសង្វាក់ ដោយសាកសួរមហាជនឲ្យបានធំទូលាយ ។

ក្ដាប់ជាប់នូវជ័យជម្នះនេះ សមាជិកសហករណ៍ទូទាំងប្រទេស ខិតខំវាយសម្រុកខ្លាំងក្លាថែមទៀត ។ គឺវាយសម្រុកកម្ទេចខ្មាំង យួនឈ្លានពាន វាតទីលេបទឹកដី បំបាត់ពូជសាសន៍ បោសសម្អាត ខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង ជាភ្នាក់ងារ សេ.អ៊ី.អា ភ្នាក់ងារក្អែបម្រើ យួន និងភ្នាក់ងារ កា.ហ្សេ.បេ វាយសម្រុកបង្កបង្កើនផលជាស្រូវ ជាដំណាំដាំដុះផ្សេងៗ ។ ព្រមជាមួយគ្នានេះ ខិតខំរៀនសូត្រថែ បំប៉នខាងគោលជំហរ នយោបាយ សតិអារម្មណ៍ ចាត់តាំង វប្បធម៌ បច្ចេកទេស ដើម្បីលើកស្ទួយសមត្ថភាពគ្រប់ផ្នែក សម្រាប់បម្រើ សហករណ៍ ឲ្យកាន់តែមានប្រសិទ្ធភាពថែមទៀត ។

អនាគតនៃសហករណ៍យើង កាន់តែមានពន្លឺកាន់តែឈានទៅ មុខតាមមាគ៌ានៃបដិវត្តន៍សង្គមនិយមរបស់បក្សកុម្មុយនីស្តកម្ពុជា យើង ។ អនាគតនៃខ្លួនយើង និងកូនចៅយើង កាន់តែត្រចេះត្រចង់ ជារៀងរាល់ថ្ងៃ ។

**ឆេង ទៀង**

# ចម្លើយសារភាពរបស់ ង៉ែត អៀង សមាជិកកងអនុសេនាធំ

***ដកស្រង់ចេញពីឯកសារលេខ J០០០៦១***

ង៉ែត អៀង មានអាយុ២៥ឆ្នាំ ភេទប្រុស មានស្រុកកំណើតនៅភូមិស្វាយរលំ ឃុំស្វាយរលំ ស្រុក២០ ភូមិភាគនិរតី ។ អៀង បានចូលបដិវត្តន៍ នៅក្នុងឆ្នាំ១៩៧២ និងមានតួនាទីជាយុទ្ធជន តំបន់២៥ ។ ឆ្នាំ១៩៧៣ អៀង បានចូលបក្សពលករវៀតណាមប្រឆាំងនឹងអង្គការ ។ អៀង បានធ្វើសកម្មភាពឃោសនាឲ្យប្រជាជន និងយុទ្ធជនបាត់ជំនឿទុកចិត្តលើអង្គការ ដោយប្រើវិធីបង្កទំនាស់ក្នុងអង្គភាពទ័ព មន្ទីរពេទ្យ និងឃោសនាឲ្យយុទ្ធជនដើរហើរដោយសេរី និងបំផ្លិចបំផ្លាញសម្ភារផ្សេងៗ ។ កំណត់ហេតុអំពីប្រវត្តិរបស់ ង៉ែត អៀង មានចំនួនសរុប៥០ទំព័រ ដែលបានរៀបរាប់អំពីសកម្មភាពប្រឆាំងអង្គការ ចាប់តាំងពីឆ្នាំ១៩៧២ រហូតដល់ថ្ងៃអង្គការចាប់ខ្លួន ។

ខាងក្រោមនេះ គឺជាសេចក្តីសង្ខេបដែលដកស្រង់ចេញពីសេចក្តីកំណត់ហេតុប្រវត្តិរបស់ ង៉ែត អៀង៖

នៅឆ្នាំ១៩៧២ អៀង បានចូលបដិវត្តន៍នៅភូមិប្រាសាទ ឃុំប្រាសាទ ស្រុក១៦ តំបន់២៥ ដោយអ្នកនាំចូលមានឈ្មោះ ស្រ៊ិន នាទីលេខាស្រុក១៦ ។ ក្រោយពេល អៀង ចូលបដិវត្តន៍រួចមក គាត់មាននាទីជាមេក្រុមកងអនុសេនាតូច ក្រោយមកនៅកងអនុសេនាធំ ។ កាល អៀង ចូលបដិវត្តន៍ដំបូង អ្នកដែលទទួលខុសត្រូវ



យុទ្ធនារីខ្មែរក្រហមប្រយុទ្ធនៅសមរភូមិមុខ

លើគាត់មានឈ្មោះ អុល នាទីលេខាអង្គភាពស្រុក១៦ ។ បន្ទាប់មក អង្គភាពស្រុកនេះ ត្រូវបានអង្គការរៀបចំជាមួយកងវរសេនាតូច ១២៧ ប្រចាំតំបន់២៥ ដោយមានអ្នកដឹកនាំឈ្មោះ លាត នាទីលេខាវរសេនាតូច១២៧ ។ ក្រោយមក អង្គភាពវរសេនាតូច១២៧ នេះ ត្រូវបានតំបន់២៥ ប្រគល់ឲ្យមកនៅក្នុងវរសេនាធំ២៦៨ ដែលមានឈ្មោះ សុន ជាអ្នកដឹកនាំ និងស្ថិតក្រោមការគ្រប់គ្រងរបស់កងពល១២ ។

## ប្រវត្តិសកម្មភាពជាខ្សែសង្វាក់ចាត់តាំងក្បត់

កន្លងមក អឿង ធ្លាប់ស្ថិតនៅក្រោមការដឹកនាំរបស់ សុន ប៉ុន្តែសុនមិនដែលបានទាក់ទងជាមួយ អឿង ទេ ។ រហូតដល់អង្គការបានចាត់តាំងឲ្យអង្គភាពអនុសេនាធំរបស់ អឿង ទៅបោះខ្សែត្រៀមនៅសមរភូមិកោះក្របីក្រោម ទើប សុន បានហៅ អឿង ទៅសួរអំពីសភាពការណ៍នៅក្នុងអង្គភាព និងសមរភូមិយ៉ាងដូចម្ដេចដែរ? ពេលនោះ អឿង បានឆ្លើយថា នៅក្នុងសមរភូមិមានសភាពការណ៍ល្អប្រសើរ រីឯបងប្អូននៅក្នុងខ្សែត្រៀម មានសភាពធម្មតា ចំណែកឯស្បៀងអាហារវិញ មានការខ្វះខាតម្ដងម្កាលដែរ ។ លុះដល់ពេលល្ងាច ក្នុងថ្ងៃដដែល សុន បាននិយាយណែនាំ និងអូសទាញគោលជំហររបស់ អឿង ដោយបានលើកហេតុផលជាច្រើនមកនិយាយបញ្ជាក់ប្រាប់ អឿង ថា ត្រូវខិតខំពង្រឹងគោលជំហរប្រយុទ្ធឲ្យខ្លាំងក្លា និងខិតខំកសាងខ្លួនឲ្យបានល្អ ។ ពេលនោះ សុន បានសួរ អឿង បន្ថែមទៀតថា តើសព្វថ្ងៃ អឿង ពេញចិត្តនឹងតួនាទីរបស់ខ្លួនដែរឬទេ? ប្រសិនបើមិនទាន់ពេញចិត្តទេ គាត់នឹងបញ្ចូល អឿង ឲ្យចូលបក្សពលករវៀតណាម ។ ពេលនោះ អឿង បានឆ្លើយថា ប្រសិនបើ សុន ឯងឲ្យខ្ញុំធ្វើអ្វីក៏ខ្ញុំព្រមធ្វើដែរ ។ នៅពេល សុន ឮដូច្នេះ ក៏បញ្ចូល អឿង ក្នុងបក្សពលករវៀតណាម និងបានបង្កើតកម្មវិធីប្រកាសជាផ្លូវការ ហើយអ្នកដែលត្រូវបានបញ្ចូលជាបក្សពលករវៀតណាមកាលនោះមានចំនួន១០នាក់ ។ អឿង បានចូលជាបក្សពលករវៀតណាមចាប់តាំងពីពេលនោះមក ។ ក្រោយពីបានបញ្ចូលអ្នកទាំងនោះ ជាសមាជិកពេញសិទ្ធិរបស់បក្សពលករហើយ សុន និង លាត បានប្រគល់ភារកិច្ចឲ្យអ្នកទាំងនោះធ្វើ គឺត្រូវបង្កប់ខ្លួននៅក្នុងជួរបដិវត្តន៍កសាង និងសម្របខ្លួនឲ្យអង្គការមានទំនុកចិត្ត ។ ក្រោយមក សុន និង លាត បានបង្ហាត់បង្រៀនអ្នកទាំងនោះឲ្យចេះរបៀបរបបនៃការអូសទាញសមាជិកថ្មីដូចជា៖ ត្រូវសង្កេតមើលអត្តចរិតពីសង្គមចាស់ និងប្រវត្តិសកម្មភាព តើអ្នកទាំងនោះមានគោលជំហរខ្សោយឬខ្លាំង ។ ប៉ុន្តែត្រូវប្រុងប្រយ័ត្នចំពោះការកសាងយុទ្ធជន ឬកម្មាភិបាលណាដែលមាត់រអិល ពីព្រោះខ្លាចបែកការណ៍នាំឲ្យមានគ្រោះថ្នាក់ដល់ក្រុមយើង ។ បន្ទាប់ពីបានណែនាំរួចហើយ សមាជិកទាំងអស់ក៏បំបែកគ្នាទៅតាមកន្លែងរៀងៗខ្លួន ចំណែក អឿង ក៏ត្រឡប់ទៅអង្គភាពរបស់ខ្លួនដែរ ។ លុះព្រឹកស្អែក អឿង បានចេញទៅខ្សែត្រៀមសមរភូមិកោះក្របី ។ រយៈពេលបីថ្ងៃក្រោយមក អឿង បានរងរបួសហើយបានសម្រាកព្យាបាលនៅពេទ្យតំបន់២៥ ។ អស់រយៈពេលជាងពីរខែក្រោយមក របួសរបស់ អឿង បានជាសះស្បើយ ហើយបានវិលត្រឡប់មកអង្គភាពវិញ ។ ក្រោយពេលមកដល់ខ្សែត្រៀមវិញ បានរយៈពេលជាងដប់ថ្ងៃ អឿង ក៏ត្រូវរបួសម្ដងទៀត ហើយបានសម្រាកព្យាបាលនៅពេទ្យអស់រយៈពេលជាងបីខែ នៅអំឡុង ឆ្នាំ១៩៧៣ ។ ក្រោយពីបានជាសះស្បើយពីរបួស អឿង ក៏ត្រឡប់មកអង្គភាពដើមវិញ ។ ប៉ុន្តែពេលនោះ អឿង បានមកសម្រាកនៅវត្តឬស្សីស្រុក ដោយមាននាទីជាមេបញ្ជាការកងអនុសេនាតូច ។ ក្រោយពីសម្រាកបានរយៈពេលបីថ្ងៃ អង្គភាពរបស់ អឿង ត្រូវបានអង្គការចាត់តាំងឲ្យត្រៀមវាយខ្ទាំងនៅសមរភូមិវត្តកណ្ដាល នៅកោះអន្លង់ចិន ។ ក្រោយពីចូលវាយនៅសមរភូមិបានប្រាំបីថ្ងៃ អឿង បានរងរបួស ហើយអង្គភាពក៏បានបញ្ជូនគាត់ឲ្យទៅសម្រាកនៅពេទ្យព្រែកថ្មី តំបន់២៥ ។ អឿង បានសម្រាកព្យាបាលនៅពេទ្យរយៈពេលជិតបីខែ រហូតដល់ឆ្នាំ១៩៧៤ ។ នៅអំឡុងពេលដែល អឿង សម្រាកនៅពេទ្យព្រែកថ្មី គាត់បានទាក់ទងជាមួយឈ្មោះ ថៃ និង ប៉េង ដែលបានសម្រាកនៅពេទ្យជាមួយគ្នា ។ មូលហេតុដែល អឿង ទាក់ទងជាមួយ ថៃ និង ប៉េង បានគឺនៅពេលដែលអ្នកទាំងពីរបានបបួល អឿង ចេញពីបន្ទប់មកអង្គុយនៅខាងក្រៅជជែកគ្នាលេងអំពីការស្នាក់នៅ និងការហូបចុកនៅក្នុងមន្ទីរពេទ្យថា មិនដែលមានសម្ល ឬបាយហូបឆ្ងាញ់ទេ ។ ចំពោះថ្នាំព្យាបាលវិញ គឺមានត្រឹមតែថ្នាំអាចម៍ទន្សាយតែប៉ុណ្ណោះ ជូនកាលផឹកថ្នាំនោះហើយ ធ្វើឲ្យឈឺក្បាល វិលមុខ រាកអាចម៍ និងឈឺធ្ងន់លើសដើមទៅទៀត ។ ពេលនោះ អឿង, ថៃ និង ប៉េង បាន

រៀបចំផែនការ និងធ្វើសកម្មភាពឲ្យចលាចលនៅក្នុងមន្ទីរពេទ្យ ដើម្បីឲ្យបក្សពិបាកដោះស្រាយ ។ បន្ទាប់មក អឿង ត្រូវបាន ប្រធានមន្ទីរពេទ្យព្រែកថ្មី បញ្ជូនគាត់ឲ្យទៅសម្រាកនៅពេទ្យតាកុក វិញ ទើបការទាក់ទងជាមួយ ថៃ និង ប៉េង បានដាច់ខ្សែរយៈ ។

ក្រោយពេលចេញពីមន្ទីរពេទ្យ អឿង បានវិលត្រឡប់មក អង្គភាពវិញ ។ អឿង សម្រាកនៅអង្គភាពបានប្រហែលបួនថ្ងៃ ក៏ត្រូវបានឈ្មោះ មុយ នាទីប្រធានអនុសេនាធំ ចាត់តាំងគាត់ឲ្យទៅ សមរភូមិម្តងទៀត ។ ក្រោយពេល អឿង បានចូលសមរភូមិរយៈ ពេលជាងដប់ថ្ងៃមក វរសេនាតូច១២៧ បានផ្លាស់មកស្នាក់នៅ ខាងក្រោយវត្តចំពុះក្អែកចម្ងាយប្រហែលមួយគីឡូម៉ែត្រពីព្រែក ប្រាវិញ ។ អឿង បានសម្រាកនៅទីនោះមិនបានប៉ុន្មានថ្ងៃផង ក៏ស្រាប់តែ ប៉េង បានណាត់ជួបគាត់ រួមជាមួយបក្ខពួកប្រាំបួននាក់ ទៀត ដើម្បីដាក់ផែនការលបបាញ់អង្គភាពវាយមីន ។ បន្ទាប់ពីបាន ដាក់ផែនការរួចរាល់ហើយ ប៉េង, អឿង និង គ្រុយ (នាទីស្នងការ កងអនុសេនាតូច) បានចេញដំណើរទៅតាមកងទ័ព ។ ពេលនោះ អឿង, ប៉េង និង គ្រុយ បានរៀបចំខ្សែត្រៀម ហើយមិនយូរប៉ុន្មាន អង្គភាពវាយមីនក៏មកដល់ និងបានវាយប្រយុទ្ធគ្នាមួយសន្ទុះ បណ្តាលឲ្យអង្គភាពវាយមីនស្លាប់ម្នាក់ និងរបួសធ្ងន់ម្នាក់ ចំណែក បក្ខពួករបស់ អឿង ក៏ត្រូវរបួសស្រាលម្នាក់ដែរ ។ ក្រោយពេល ធ្វើសកម្មភាពរួចហើយ អឿង ក៏បានវិលត្រឡប់មកអង្គភាពវិញ ។ សម្រាកបានមួយយប់ អង្គការបានចាត់តាំង អឿង និងសមាជិក ក្នុងអង្គភាពទាំងមូលឲ្យរៀបខ្សែត្រៀមនៅសមរភូមិកោះក្របីលើ (ជាប់ទន្លេបាសាក់) ។ បន្ទាប់ពី អឿង ចូលប្រយុទ្ធនៅសមរភូមិ បានរយៈពេលពីរថ្ងៃ គាត់ក៏រងរបួស ហើយបានសម្រាកព្យាបាល នៅពេទ្យព្រែកតាកុក ។

អឿង បានសម្រាកព្យាបាលនៅពេទ្យព្រែកតាកុកអស់ រយៈពេលជាងមួយខែ ទើបគណៈមន្ទីរពេទ្យបានប្រកាសជ្រើស រើសអ្នករបួសណាដែលមានលទ្ធភាពអាចដើរបាន ឲ្យទៅចូលរួម កម្មពិធីបុណ្យនៅកោះធំ ។ ក្រោយពីប្រកាសរួច អង្គការបានយក កាណូតមកដឹកអ្នករបួសមួយចំនួនទៅចូលរួមពិធីបុណ្យនោះ ។ ពេលទៅដល់កន្លែង អឿង បានឮអង្គការឧទ្ទេសនាមថា អង្គភាពវរ សេនាតូច១២៧ នឹងប្រគល់ឲ្យកងពល១២ ជាអ្នកគ្រប់គ្រងវិញ ។ ក្រោយពីអង្គការប្រកាសឧទ្ទេសនាមរួចហើយ ពិធីបុណ្យនោះក៏ ត្រូវបានបញ្ចប់ រីឯអ្នកដែលទៅចូលរួមបានវិលត្រឡប់មកមន្ទីរ ពេទ្យវិញ ។

ក្នុងអំឡុងពេល អឿង សម្រាកនៅពេទ្យរយៈពេលជាងដប់ ថ្ងៃ អឿង បានទាក់ទងជាមួយឈ្មោះ វ៉ែន និង សូត្រ ដើម្បីប្រជុំដាក់ ផែនការប្រឆាំងបដិវត្តន៍ នៅក្នុងមន្ទីរពេទ្យ ។ ខ្លឹមសារប្រជុំ ៖ គឺធ្វើ សកម្មភាពបំផុសបំផុលអ្នកជំងឺទាំងអស់ដែលសម្រាកនៅមន្ទីរពេទ្យ ឲ្យមានទំនាស់ជាមួយបុគ្គលិកពេទ្យ ឬគណៈពេទ្យ និងលើកជាបញ្ហា ចំពោះបុគ្គលិកពេទ្យ អំពីកង្វះអនាម័យ និងមិនយកចិត្តទុកដាក់មើល ថែអ្នកជំងឺ ចំណែកម្ហូបអាហារវិញ គឺមិនដែលមានម្ហូបឆ្ងាញ់ទេ ។ ចំពោះផែនការខាងលើនេះ អ្នកទាំងបីនាក់អនុវត្តបានសម្រេច ហើយ បានធ្វើសកម្មភាពអុកឡុក នៅក្នុងមន្ទីរពេទ្យនេះជាបន្តបន្ទាប់ ។

រហូតដល់ខែសីហា ឆ្នាំ១៩៧៤ ជំងឺរបស់ អឿង បានជាសះ ស្បើយ ហើយបានវិលត្រឡប់មកអង្គភាពវិញ ។ អឿង សម្រាក នៅអង្គភាពបានមួយរយៈ ក៏ត្រូវបានឈ្មោះ ប៉ាវ នាទីសមាជិកវរ សេនាតូច១២៧ បានចាត់តាំងគាត់ឲ្យទៅសមរភូមិវត្តឬស្សីស្រុក ។ ក្រោយពីចូលសមរភូមិបានរយៈពេលប្រាំពីរថ្ងៃ អឿង បានត្រូវ របួស ហើយអង្គភាពពេទ្យបានបញ្ជូនគាត់ឲ្យទៅសម្រាកនៅមន្ទីរ ពេទ្យព្រែកថ្មី ។ អឿង បានសម្រាកនៅទីនោះ រយៈពេលជិតបីខែ នៅក្នុងអំឡុងឆ្នាំ១៩៧៥ ។ បន្ទាប់ពីរបួសបានជាសះស្បើយហើយ អឿងក៏វិលត្រឡប់ទៅអង្គភាពវិញ ។ អង្គការបានរៀបចំ អឿង ឲ្យ ឡើងនាទីជាសមាជិកកងអនុសេនាធំ ។ បន្ទាប់មក អង្គការបានចាត់ តាំង អឿង ឲ្យចូលទៅសមរភូមិដងទន្លេមេគង្គ ។ ក្រោយពេលទៅ ដល់សមរភូមិ អឿង និងអង្គភាពទាំងមូលបានចូលវាយខ្មាំងជាបន្ត បន្ទាប់ រហូតបានរំដោះសមរភូមិដងទន្លេមេគង្គនេះបានជាស្ថាពរ ។ លុះដល់ខែមីនា ឆ្នាំ១៩៧៥ អង្គភាពបានចាត់តាំង អឿង ឲ្យទៅ រៀននៅសាលាបច្ចេកទេសរបស់កងពល១២ នៅម្តុំភូមិកំពង់ស្វាយ កណ្តាល និងវត្តទួលសង្កែ (ស្រុកកោះធំ) ។ ក្រោយពេល អឿង រៀននៅសាលាបច្ចេកទេសនេះបានមួយខែ អង្គការបាន រំសាយ សាលានេះ រីឯអ្នកដែលទៅចូលរៀនក៏វិលត្រឡប់មកអង្គភាព រៀងៗខ្លួនវិញ ។ នៅខែឧសភា ឆ្នាំ១៩៧៥ ឈ្មោះ សុន បានធ្វើ ការណែនាំ អឿង និងសមាជិកបក្សពលករវៀតណាម៤១នាក់

ទៀត ឲ្យស្គាល់គ្នាដើម្បីធ្វើការទាក់ទងនៅថ្ងៃខាងមុខ ។ ក្រោយពេលធ្វើការណែនាំរួចហើយ សុន បានប្រកាសបិទអង្គប្រជុំ ។

**សកម្មភាពជាក់ស្តែងរបស់ អឿង និងបក្ខពួកពេលនោះ**

សកម្មភាពមុនរំដោះ ៖

១) បំផុសទំនាស់នៅក្នុងមន្ទីរពេទ្យ

២) បង្កបក្ខពួកបំផុសទំនាស់នៅក្នុងអង្គភាពជាបន្តបន្ទាប់

៣) សេរី ប្រើអាវុធដាក់យុទ្ធជន និងកម្មាភិបាលខាងក្រោមជាញឹកញាប់

សកម្មភាពក្រោយរំដោះ :

១) បំផុសយុទ្ធជន និងកម្មាភិបាលថ្នាក់ក្រោម ឲ្យសេរី ភ្លើតភ្លើនទៅតាមសម្ភារល្អៗ លើសរបបអង្គការកំណត់

២) បំផុសទំនាស់ជាមួយអង្គភាពនារី និងឃាត់ចាប់គេទុកជាញឹកញាប់

៣) សេរីរើដើរហើរ ទាក់ទង បង្កបក្ខពួក បង្កទំនាស់ ធ្វើឲ្យបក្សពិបាកដោះស្រាយជាបន្តបន្ទាប់ ។

ក្រោយពេលធ្វើសកម្មភាពដូចខាងលើរួចមក សុន បានចាត់តាំង អឿង និងបក្ខពួក ឲ្យទៅនៅក្នុងអង្គភាពវរសេនាតូច ៣១៣ វរសេនាធំ៣១ កងពល៧០៣ថ្មីវិញ ។ ប៉ុន្តែមុននឹងទៅអង្គភាពថ្មី សុន បានហៅ អឿង និងបក្ខពួកមកណែនាំជាសម្ងាត់ដែលមានខ្លឹមសារដូចតទៅ ៖ ត្រូវក្តាប់សកម្មភាពឲ្យបានណែនមុននឹងធ្វើសកម្មភាពអ្វីមួយ ហើយត្រូវប្រុងប្រយ័ត្នចំពោះយុទ្ធជន ឬកម្មាភិបាលខ្មែរក្រហម ព្រោះអង្គការកំពុងតាមដានបក្ខពួកយើង ។ ក្រោយពេលធ្វើការណែនាំរួចហើយ សុន បានខទ្មេសនាម អឿង និងបក្ខពួកទៅកាន់អង្គភាពថ្មីដើម្បីធ្វើការទាក់ទងស្គាល់គ្នា ។ កាលនោះមានឈ្មោះ អុល គ្រប់គ្រងនៅអង្គភាពវរសេនាតូច៣១៣ ។ ក្រោយពេល អឿង បានរស់នៅក្នុងអង្គភាពថ្មីនេះបានមួយរយៈ ក៏ស្រាប់តែបានជួប សុន នៅមន្ទីរវិមានឯករាជ្យ និងបានពិភាក្សាអំពីសភាពការណ៍ផ្ទៃក្នុងខ្លះៗ ។ ពេលនោះ សុន បានប្រាប់ អឿង ថា នៅខែតុលា ឆ្នាំ១៩៧៥ ខាងមុខនេះ នឹងរៀបចំធ្វើបាតុកម្ម និងវាយបដិវត្តន៍ ហើយបច្ចុប្បន្ននេះកំពុងរៀបចំរបបថ្មីមួយទៀត ។ បន្ទាប់ពីពិភាក្សាគ្នាចប់ អឿង បានវិលត្រឡប់មកអង្គភាពវិញ រួចហើយបានរៀបចំអាវុធ និងកម្លាំងបក្សពលករនៅក្នុងអង្គភាពឲ្យត្រៀមលក្ខណៈដើម្បីចូលរួមបាតុកម្ម ។ រយៈពេលជិតមួយសប្តាហ៍ក្រោយមក អង្គការបានចាត់តាំងអង្គភាពវរសេនាធំរបស់ អឿង ឲ្យទៅធ្វើស្រែនៅភូមិបាគូរ នៅខាងត្បូងភ្នំពេញ ។ រីឯកងអនុសេនាធំមួយទៀត ឲ្យឈរជើងនៅទីក្រុងភ្នំពេញដដែល ។ ចំពោះការទាក់ទងរវាង អឿង និងបក្ខពួក ក៏បានដាច់ខ្សែរយៈចាប់តាំងពីពេលនោះមក ។ មិនយូរប៉ុន្មាន អឿង បានឮដំណឹងថាបក្ខពួកមួយចំនួនត្រូវបានអង្គការចាប់ខ្លួន ដោយអង្គការស៊ើបដឹងថា ជាបក្សពលករវៀតណាម ដែលមកបង្កប់ខ្លួនស៊ីរូងផ្ទៃក្នុង ។ អឿង ចាប់ផ្តើមមានការព្រួយបារម្ភអំពីខ្លួនឯងផ្ទាល់ និងបក្ខពួក ហើយបានហៅសមាជិកបក្សពលករទាំងអស់មកជួបជុំ និងពិភាក្សាគ្នា ។ ក្នុងខ្លឹមសារប្រជុំនោះ អឿង បាននិយាយថា សមាជិកទាំងអស់ត្រូវតាមដាន និងក្តាប់សភាពការឲ្យជាប់នៅក្នុងដៃ ប្រសិនបើមានសភាពការណ៍អ្វីប្លែក ត្រូវរាយការណ៍ឲ្យគាត់ជាបន្ទាន់ ។ ភ្លាមនោះ មានសមាជិកម្នាក់បានលើកឡើងថា រយៈពេលកន្លងមកនេះ គាត់ពិតជាខំពុះពាររាល់ឧបសគ្គតូចធំដើម្បីបំពេញភារកិច្ចជូនបក្សពលករ ដូចជាបំផុសទំនាស់នៅក្នុងអង្គភាពរវាងយុទ្ធជន និងកម្មាភិបាល ឲ្យកុហកថាឈឺ ហើយសព្វថ្ងៃនេះ គាត់បានបំផុសឲ្យយុទ្ធជនរត់ទៅផ្ទះបានបីនាក់ ប៉ុន្តែត្រូវបានអង្គការចាប់យកមកវិញ ។ ពេលនោះ អឿង បានបន្ថែមថា សមាជិកទាំងអស់ត្រូវផ្អាកធ្វើសកម្មភាពប្រឆាំងនឹងបដិវត្តន៍ ពីព្រោះសភាពការណ៍បច្ចុប្បន្ននេះ អង្គការកំពុងតែតាមដានបក្ខពួកយើង ដូច្នេះហើយសមាជិកទាំងអស់ត្រូវបង្កប់ខ្លួនឲ្យជ្រៅនៅក្នុងចលនាបដិវត្តន៍ ហើយខំកសាងខ្លួនឲ្យបានល្អកុំឲ្យអង្គការចាប់ថ្នាក់បាន ។ រីឯចលនាក្នុងបដិវត្តន៍កាន់តែវិវត្តទៅមុខជាប្រចាំចំពោះមហាជន និងកម្មាភិបាលគឺកាន់តែខ្លាំងក្លាក្នុងការវាយកម្ទេចកម្មសិទ្ធិឯកជន ជាពិសេសមានគោលជំហររឹងមាំក្នុងសមូហភាព ។ រយៈពេលជាងដប់ថ្ងៃក្រោយប្រជុំ សុន ក៏ត្រូវបានអង្គការចាប់ខ្លួន បានធ្វើឲ្យបក្ខពួករបស់ អឿង ចាប់ផ្តើមភ័យខ្លាច រួចនាំគ្នារត់បែកខ្ញែកអស់ ។ រីឯ អឿង ក៏មិនហ៊ានធ្វើសកម្មភាពប្រឆាំងនឹងបដិវត្តន៍ខ្លាំងក្លាទេ គ្រាន់តែធ្វើសកម្មភាពបំភ្លើសមាគ៌ារបស់បក្សបន្តិចបន្តួច និងសកម្មភាពផ្សេងៗដែលគាត់អាចធ្វើទៅបានរហូតដល់ថ្ងៃអង្គការចាប់ខ្លួន នៅថ្ងៃទី៨ ខែសីហា ឆ្នាំ១៩៧៧ ។

**ហូ ថុនា**

# ការិយាល័យព័ត៌មានសាធារណៈ

“ការិយាល័យព័ត៌មានសាធារណៈ” របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ និងព្រឹត្តិការណ៍វិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម ។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ ។ ប្រភេទឯកសារទីពីរគឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះនិងអតីតកម្មាភិបាលខ្មែរក្រហម ។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម ។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារប្រភេទទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត ។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចអាននឹងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារខ្លះទៀតរួមមាន ៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង អន វណ្ណារ៉ា តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល *truthvannara@dccam.org* ។





















# កាលវិភាគបញ្ចាំងខ្សែភាពយន្ត
# ឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា
















*រៀងរាល់ថ្ងៃសុក្រ វេលាម៉ោង ១០ : ០០ ព្រឹក*

*ទីតាំង : អគារ H នៃវិទ្យាស្ថានជាតិអប់រំ (មហាវិថីព្រះសីហនុ ភ្នំពេញ)*

*សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង : ស៊ាង ចិន្តា ទូរសព្ទលេខ : ០២៣ ២១១ ៨៧៥ អ៊ីម៉ែល : truthchenda.s@dccam.org*

# ចូលរួមចលនាបដិវត្តន៍ដោយសារការបង្ខំ

បន្ទាប់ពីរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ ១៩៧០ ដោយសេនាប្រមុខ លន់ នល់ ចលនាតស៊ូបដិវត្តន៍របស់ខ្មែរក្រហមបានកើនឡើង និងរីងមាំជាលំដាប់ ។ នៅតាមតំបន់ដាច់ស្រយាលស្ទើរទូទាំងប្រទេស ត្រូវបានខ្មែរក្រហមគ្រប់គ្រង ។ ខ្មែរក្រហមបានធ្វើការឃោសនាប្រឆាំងនឹងរបប លន់ នល់ ដើម្បីដណ្តើមអំណាចថ្វាយសម្តេច សីហនុ វិញ ។ ខ្មែរក្រហមបានកេណ្ឌប្រជាជនឲ្យចូលរួមក្នុងចលនាតស៊ូរបស់ខ្លួនតាមការស្ម័គ្រចិត្ត ហើយប្រជាជនខ្លះទៀតក៏ត្រូវបានខ្មែរក្រហមបង្ខំតាមរយៈការគំរាមសម្លាប់ ឬធ្វើបាបសមាជិកគ្រួសារ ប្រសិនបើមិនព្រមចូលរួម ។

ជាក់ស្តែង នៅអំឡុងឆ្នាំ១៩៧៣ ភូមិស្រុកមួយចំនួនក្នុងខេត្តកំពង់ឆ្នាំងត្រូវបានខ្មែរក្រហមគ្រប់គ្រង ។ ជានារីវ័យជំទង់ម្នាក់ក្នុងអំឡុងពេលនោះ កុយ រិទ្ធ ត្រូវបានខ្មែរក្រហមបង្ខំឲ្យចូលរួមតស៊ូបដិវត្តន៍ដោយគំរាមកំហែងដល់អាយុជីវិត និងគ្រួសារ ។ រិទ្ធ ត្រូវឃ្លាតឆ្ងាយពីគ្រួសារទៅធ្វើជាឈ្លប និងធ្វើជានីរសារឃុំពោធិ៍ ។ ពេលនោះដោយសារការនឹករលំបាក រិទ្ធ បានលួចត្រឡប់មកផ្ទះវិញ ប៉ុន្តែត្រូវអង្គភាពមកចាប់ទៅវិញ ។ រិទ្ធ បានរម្លឹករឿងរ៉ាវដែលគាត់បានតស៊ូ និងឆ្លងកាត់របបខ្មែរក្រហមប្រាប់ខ្ញុំថា ៖

## អំពីគ្រួសារ និងការរៀនសូត្រ

កុយ រិទ្ធ ជាកូនកសិករ ដែលមានឪពុកឈ្មោះ ចាប សាញ់ និងម្តាយឈ្មោះ យិន មិក រស់នៅភូមិថ្មី ឃុំពោធិ៍ ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង ។ រិទ្ធ មានបងប្អូន៣នាក់ (ប្រុសពីរនាក់) ។ ដោយសារតែជីវភាពគ្រួសារមានការខ្វះខាត រិទ្ធ បានរៀនត្រឹមថ្នាក់ទី១១ (សង្គមចាស់) នៅសាលាបឋមសិក្សាឃុំពោធិ៍ ។ ក្រោយរដ្ឋប្រហារទម្លាក់សម្តេច សីហនុ ឆ្នាំ១៩៧០ រិទ្ធ បានឈប់រៀន ហើយត្រឡប់មកជួយធ្វើស្រែឪពុកម្តាយវិញ ។

## សកម្មភាពមុនឆ្នាំ១៩៧៥

នៅឆ្នាំ១៩៧៣ ភូមិស្រុកដែល រិទ្ធ រស់នៅត្រូវបានខ្មែរក្រហមគ្រប់គ្រង ។ រិទ្ធ ត្រូវបានខ្មែរក្រហម កេណ្ឌឲ្យចូលចលនាតស៊ូបដិវត្តន៍ ព្រមទាំងបានចាត់ឲ្យធ្វើជាឈ្លបនារី និងនីរសារឃុំ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់យាយ រ៉ែន គណៈឃុំពោធិ៍ ។ រិទ្ធ បានធ្វើកិច្ចការនេះបានមួយរយៈ ក្រោយមកដោយនឹកដល់គ្រួសារ និងការនឿយលំបាក គាត់ក៏បានលួចរត់មកផ្ទះ ប៉ុន្តែមិនយូរប៉ុន្មាន អង្គភាពក៏មកចាប់គាត់យកទៅវិញ ។ ស្ថិតក្នុងវ័យ១៧ឆ្នាំ រិទ្ធ ត្រូវបានខ្មែរក្រហមផ្លាស់ពីការងារឈ្លប និងនីរសារ ឲ្យទៅធ្វើជាយោធានៅតំបន់៣១ ម្តុំក្រាំងស្រម៉ ដែលមានយាយ ម៉ែន ជាគណៈតំបន់ (ក្រោយមកយាយ ម៉ែន ត្រូវបានចាប់ខ្លួនដោយសារខុសសីលធម៌) ។ ចូលជាយោធា រិទ្ធ បានរៀនបាញ់កាំភ្លើង និងដោះមីន ។ នៅឆ្នាំ១៩៧៤ រិទ្ធ ត្រូវបានផ្លាស់ទៅធ្វើជាយុទ្ធនារីនៅកងពលទី១ ភូមិភាគនិរតី ។ សង្គ្រាមរវាងកម្លាំងតស៊ូខ្មែរក្រហម និង លន់ នល់ កាន់តែខ្លាំងឡើងៗពីមួយថ្ងៃទៅមួយថ្ងៃ ។ កងពលរបស់ រិទ្ធ បានវាយចូលក្រុងភ្នំពេញ តាមទំនប់កប់ស្រូវ ដែលសម័យនោះនាំគ្នាហៅថា សមរភូមិ៩៩០ ។ នៅថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ យោធាខ្មែរក្រហមបានទទួលជ័យជម្នះទាំងស្រុងលើរដ្ឋាភិបាល លន់ នល់ និងដណ្តើមកាន់កាប់ទីក្រុងភ្នំពេញទាំងមូល ។

## ក្រោយជ័យជម្នះ១៧ មេសា ១៩៧៥

បន្ទាប់ពីខ្មែរក្រហមទទួលជ័យជម្នះទាំងស្រុង យោធាទាំងអស់បានចូលមកក្នុងទីក្រុងភ្នំពេញជាបន្តបន្ទាប់ ។ ក្នុងនោះ កងរបស់ រិទ្ធ ក៏បានចូលមកភ្នំពេញដែរ ។ ខ្មែរក្រហមក៏ចាប់ផ្តើមប្រកាស និងជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុង ។ កំពុងតែធ្វើដំណើរតាមផ្លូវក្នុងក្រុងភ្នំពេញ គាត់ក៏បានឃើញបុរសម្នាក់កំពុងរុញរទេះដឹកកូនដែលមានព្យួរសេរ៉ូមផង រិទ្ធ ចាំច្បាស់ណាស់ថា បុរសម្នាក់នោះជាបងប្អូនជីដូនមួយរបស់គាត់ដែលធាក់រ៉ឺម៉ក នៅភ្នំពេញ ។ គាត់មិនបាននិយាយអ្វីច្រើនជាមួយនឹងបងជីដូនមួយគាត់ទេ ដោយហេតុថាមេកងរបស់គាត់ បានប្រាប់គាត់ឆាប់ឲ្យស្រួតដំណើរទៅមុខ និងមិនត្រូវទំនាក់ទំនងជាមួយអ្នកជម្លៀសដើម្បីកុំឲ្យមានការពាក់ព័ន្ធនឹងរបបចាស់ ។ រិទ្ធ អាណិតបងជីដូនមួយយ៉ាងខ្លាំង ហើយគាតក៏មិន

ដឹងថា បងជីដូនមួយធ្វើដំណើរទៅស្រុកកំណើត ឬទៅខាងណាទេ ព្រោះគាត់មិនបានទទួលដំណឹងពីបងជីដូនមួយរបស់គាត់ទេរហូតមកដល់សព្វថ្ងៃ។

តាមការចងចាំ រិទ្ធ បានធ្វើដំណើរកាត់ផ្សារ ហើយបានឃើញមាសប្រាក់ដែលគាំងលក់នៅក្នុងទូចាំងនឹងពន្លឺភ្លើងអំពូលភ្លឺផ្លេកក្រហមច្រាល ប៉ុន្តែមិនមាននរណាម្នាក់ហ៊ានទៅយកទេ។ កងរបស់គាត់មិនបានស្នាក់នៅក្នុងទីក្រុងភ្នំពេញទេ គឺត្រូវទៅឈរជើងនៅអូរបែកក្អម និងកំបូល។ អំឡុងពេលឈរជើងនៅទីនោះ កងរបស់ រិទ្ធ មាននាទីការពារ រៀបចំបោសសម្អាត និងប្រមូលរបស់របរតាមផ្ទះ ឬទីកន្លែងផ្សេងៗ។ ប្រាំមួយខែក្រោយ មកកងរបស់ រិទ្ធ ត្រូវបានអង្គការផ្លាស់ឲ្យទៅបន្ទាយលង្វែកវិញ ដោយយកទៅជាមួយនូវសម្ភារមួយចំនួនដែលប្រមូលបានពីក្រុងភ្នំពេញ។

## ផ្លាស់ទៅខេត្តសៀមរាប និងការដួលរលំនៃរបបខ្មែរក្រហម

មកដល់បន្ទាយលង្វែក កងរបស់ រិទ្ធ ត្រូវបានអង្គការចាត់ឲ្យធ្វើស្រែ។ កងរបស់គាត់នៅធ្វើស្រែរហូតដល់ឆ្នាំ១៩៧៧ តាម៉ុក ក៏បានផ្លាស់កងរបស់គាត់ឲ្យទៅនៅខាងខេត្តសៀមរាប ដែលពេលនោះមានសមាជិកប្រហែល១០០ ទៅ ២០០នាក់។ ទៅដល់សៀមរាប អង្គការបានចាត់តាំង រិទ្ធ ឲ្យកាន់ខាងបើកសាំង។ គាត់មិនដឹងថាឡានជារបស់អ្នកណាខ្លះទេ គាត់គ្រាន់តែចាក់តាមការសរសេរលើក្រដាសថាប៉ុន្មានលីត្រៗប៉ុណ្ណោះ។ បើតាមគាត់ស្មាន គាត់ចាក់សាំងឲ្យឡានមេៗ ឬគណៈភូមិភាគ។ រិទ្ធ បានឲ្យដឹងថា នៅអង្គភាពសាំងមានសមាជិកប្រហែល៧ ទៅ៨នាក់ ដែលភាគច្រើនជាស្រីដែលមានវ័យពី១៥ ទៅ២១ឆ្នាំ។ ចំណែកកន្លែងបើកសាំងមានបីទីតាំងគឺ នៅភ្នំក្រោម ស្ពានអង្គរ និងអាស្រមព្រះអង្គចេកព្រះអង្គចម។ រិទ្ធ ធ្វើការខាងផ្នែកបើកសាំងនេះរហូតដល់ថ្ងៃដួលរលំនៃរបបខ្មែរក្រហម។ គាត់បានឲ្យដឹងថា ពេលដែលវៀតណាមវាយចូលខេត្តសៀមរាប គាត់បានភៀសខ្លួនទៅតាមខ្មែរក្រហមដទៃទៀត ដោយមិនហ៊ានរត់ទៅស្រុកកំណើតទេ ព្រោះខ្មែរក្រហមឃោសនាថា ប្រសិនបើវៀតណាមចាប់បាន នោះនឹងសម្លាប់ចោលពុំខាន។

រិទ្ធ និងអ្នកឯទៀតបានរត់ភៀសខ្លួនពីភូមិមួយទៅភូមិមួយសំដៅទៅព្រំដែនថៃ។ នៅតាមផ្លូវធ្វើដំណើរពិតជាលំបាកខ្លាំងណាស់សម្រាប់អ្នកទាំងនោះ ព្រោះមិនមានស្បៀងគ្រប់គ្រាន់។ ម្នាក់ៗប្រឹងរត់រៀងៗខ្លួន អ្នកខ្លះត្រូវទុកប្រពន្ធប្តី ឬកូនដែលឈឺធ្ងន់ចោល ព្រោះតែមិនមានលទ្ធភាពនាំទៅជាមួយបាន។

## ការតស៊ូចុងក្រោយ

ក្រុមរបស់ រិទ្ធ បានធ្វើដំណើរកាត់កន្លែងជាច្រើនទម្រាំដល់ខ្លែម ជាប់ព្រំប្រទល់ថៃ។ នៅទីនោះ មានអង្គការមនុស្សធម៌បានជួយទំនុកបម្រុង ដោយផ្តល់ ការពិនិត្យជំងឺ ថ្នាំសង្កូវ សម្ភារ និងស្បៀងអាហារ។ មួយរយៈក្រោយមក អង្គភាពបានផ្លាស់ រិទ្ធ និងនារីផ្សេងទៀតឲ្យទៅម៉ាឡៃដើម្បីដឹកជញ្ជូនស្បៀង និងគ្រាប់ទៅសមរភូមិមុខ។ នៅឆ្នាំ១៩៨០ កងនារីដឹកជញ្ជូនរបស់ រិទ្ធ ត្រូវបានផ្ទាក់លើបញ្ជូនបន្តទៅតំបន់១០០១ ដែលជាតំបន់ស្ថិតក្រោមការគ្រប់គ្រងរបស់ សុន សេន។

ក្រៅពីការងារដឹកជញ្ជូនស្បៀង និងគ្រាប់ទៅសមរភូមិមុខ ហើយ រិទ្ធ មានភារកិច្ចបិតចម្រូងឫស្សី។ ដោយសារពេលនោះប្រុសៗត្រូវទៅប្រយុទ្ធនៅសមរភូមិមុខ ហេតុដូច្នេះ នារីៗត្រូវទៅកាប់ឫស្សីដោយខ្លួនឯង និងបិតឲ្យបាន៣០០ចម្រូងក្នុងមួយថ្ងៃ។ ចំពោះការងារជានារីដឹកជញ្ជូន រិទ្ធ បានរំឭកថា មានគ្រោះថ្នាក់ខ្លាំងណាស់ ព្រោះបើយើងមិនប្រយ័ត្ន នឹងជាន់មីនស្លាប់មិនខាន។

## ជីវិតថ្មីក្រោយសន្តិភាព

រិទ្ធ បានរៀបការនៅឆ្នាំ១៩៨២ ជាមួយប្តីឈ្មោះ សេក សាំង ដែលជាយុទ្ធជននៅកងពល៨០១។ ក្រោយសមាហរណកម្មឆ្នាំ១៩៩៨ រិទ្ធ និងប្តីបានមករស់នៅស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ រិទ្ធ និងគ្រួសារចាប់ផ្តើមជីវិតថ្មី ដោយប្រកបរបរជាកសិករ។ គាត់នៅតែសោកស្តាយ ព្រោះគិតថា ពេលដែលខ្មែរក្រហមកាន់អំណាច ប្រទេសជាតិនឹងចប់សង្គ្រាម ហើយគាត់អាចត្រឡប់ទៅរស់នៅជួបជុំគ្រួសារវិញ។ ប៉ុន្តែអ្វីៗមិនដូចជាការរំពឹងគិតរបស់គាត់ទេ គាត់ត្រូវផ្លាស់ពីកន្លែងមួយទៅកន្លែងមួយ តាំងពីស្រុកកំណើតនៅខេត្តកំពង់ឆ្នាំង រហូតចុងក្រោយមកខេត្តឧត្តរមានជ័យ។ ទោះបីជាយ៉ាងណា រិទ្ធ រីករាយនឹងការរស់នៅបច្ចុប្បន្ន ព្រោះគាត់រស់នៅដោយមានសិទ្ធិសេរីភាព ប្រកបរបរដែលចង់ធ្វើ និងបានរស់នៅជួបជុំគ្រួសារ មិនបែកបាក់គ្នាដូចរបបខ្មែរក្រហម។ ចំណែកកូនប្រុសស្រីទាំងបីរបស់គាត់ មានគ្រួសារ និងជីវភាពរស់នៅសមរម្យគ្រប់ៗគ្នា។ **ឆាច សារៈមុនិន្ទ**

# អន្លង់វែង និងការផ្លាស់ប្តូរ

អន្លង់វែងគឺជាតំបន់ទេសចរណ៍បែបប្រវត្តិសាស្ត្រដែលអាចទាក់ទាញភ្ញៀវទេសចរជាតិ និងអន្តរជាតិមកពីគ្រប់ទិសទីដើម្បីទស្សនា និងស្រាវជ្រាវពីធនធានធម្មជាតិ និងទីតាំងប្រវត្តិសាស្ត្រទាក់ទងនឹងសម័យខ្មែរក្រហម ដែលបានបន្សល់ទុកនូវកេរដំណែល រួមមានសាលារៀន មន្ទីរពេទ្យ ស្ពាន និងផ្ទះរបស់មេដឹកនាំខ្មែរក្រហមមកដល់បច្ចុប្បន្ននេះ ។ ការសិក្សាអំពីប្រជាជននៅតំបន់អន្លង់វែង ពិបាកនឹងជៀសឲ្យផុតអំពីផ្នត់គំនិតនៃការចោទប្រកាន់ណាស់ ។ អន្លង់វែងគឺជាតំបន់តស៊ូចុងក្រោយរបស់ខ្មែរក្រហម ។ ប្រជាជនកម្ពុជាប្រមាណជិតពីរលាននាក់បានបាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ហើយរហូតមកដល់បច្ចុប្បន្ននេះ ប្រទេសកម្ពុជានៅតែតស៊ូជាមួយនឹងលទ្ធផលនៃប្រវត្តិសាស្ត្រនេះ ។ ប្រជាជនដែលរស់នៅតំបន់អន្លង់វែងភាគច្រើនគឺជាអតីតកងទ័ព និងជាអតីតកម្មាភិបាលខ្មែរក្រហម ដែលមួយចំនួនប្រហែលជាធ្លាប់ចូលរួមប្រព្រឹត្តអំពើឃោរឃៅ ។ ទោះបីជារបបខ្មែរក្រហមបានដួលរលំទៅហើយក្តី ក៏ប្រជាជនកម្ពុជានៅទូទាំងប្រទេសមិនថាអ្នកដែលរស់នៅក្នុងតំបន់ដែលគ្រប់គ្រងដោយខ្មែរក្រហម ឬតំបន់ផ្សេងទេ គឺសុទ្ធតែទទួលរងទុក្ខវេទនា ។

ទោះជាយ៉ាងនេះក្តី នៅពេលដែលប្រជាជនក្នុងតំបន់អន្លង់វែងទទួលស្គាល់នូវផលវិបាកដ៏អាក្រក់នៃចលនាខ្មែរក្រហមដែលខ្លួនបានចូលរួម និងទ្រទ្រង់នៅក្នុងកាលៈទេសៈជាច្រើន ដូច្នេះឥរិយាបថរបស់ប្រជាជនទាំងនោះចំពោះរបបខ្មែរក្រហម គឺមិនអាចប្រៀបធៀបទៅនឹងទំហំនៃអំពើឃោរឃៅដែលខ្លួនបានដឹងថាបានកើតមានឡើងនោះទេ ។ ទោះបីជាមនុស្សគ្រប់រូបយល់ស្របថា ឧក្រិដ្ឋកម្មដ៏អាក្រក់បានកើតឡើងនៅក្នុងរបបខ្មែរក្រហម និង



និស្សិតស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ទស្សនកិច្ចសិក្សានៅវិទ្យាល័យអន្លង់វែង ។ អគារសិក្សានៅវិទ្យាល័យនេះបានសាងសង់ឡើងតាំងពីសម័យដែលតាម៉ុក គ្រប់គ្រងនៅអំឡុងទសវត្សរ៍៩០ ។

បន្តកើតមានក្រោយមកទៀតក្តី ក៏ប្រជាជនមួយចំនួននៅតែមានមនោសញ្ចេតនាស្រឡាញ់អតីតកាលបែបនេះ ហើយបុគ្គលមួយចំនួនទៀតនៅតែជឿជាក់ថា លទ្ធិកុម្មុយនីស្តនៅតែអនុវត្តបាន ប្រសិនបើមានមេដឹកនាំល្អជាងនេះ ។ ដូចគ្នានេះ នៅពេលដែលប្រជាជនជាច្រើនទទួលស្គាល់ថា មេដឹកនាំខ្មែរក្រហមមួយចំនួនដូចជា តាម៉ុក ជាមនុស្សសាហាវឃោរឃៅ ក៏មានមនុស្សមួយចំនួននៅតែមានការគោរព ស្រឡាញ់ និងដឹងគុណចំពោះ តាម៉ុក រហូតមកដល់សព្វថ្ងៃនេះ ។

ជាក់ស្តែង យ៉ើប យើន ជាអតីតយុទ្ធនារីខ្មែរក្រហម ដែលមានប្តីឈ្មោះ ទៀប ស៊ី និងមានកូន៨នាក់ (ស្រី២នាក់) ។ គាត់មានស្រុកកំណើតនៅភូមិដាំស្តែ ស្រុកសង្កែ ខេត្តបាត់ដំបង ។ យើន រួមទាំងគ្រួសារត្រូវបានផ្លាស់ប្តូរទីលំនៅទៅតំបន់ផ្សេងៗដូចជា ម៉ាឡៃ ភ្នំឆ័ត្រ ជប់គីរី និងនៅជួរភ្នំដងរែក ។ សព្វថ្ងៃ យើន បានមករស់នៅស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ។

យើន និងកងទ័ពផ្សេងទៀតបានផ្លាស់ទៅនៅតំបន់ជប់គិរី ដោយប្រកបរបរជាកសិករ ។ ក្រោយមក តាម៉ុក បានបញ្ជាឲ្យមេបញ្ជាការយោធា យកឡានទៅដឹកប្រជាជន និងកងទ័ពដែលជម្លៀសមកនៅជប់គីរី ចំនួនប្រហែលជាង២០ឡាន មកនៅតំបន់អន្លង់វែងវិញ ហើយគ្រួសារ យើន ក៏មករស់នៅក្នុងភូមិឈើទាលជ្រុំ ព្រោះគាត់ក៏ធ្លាប់ជាកងយោធាខ្មែរក្រហមជួរក្រោយដែរ ។ យើន បន្តទៀតថា ពេលដែលគាត់មកដល់អន្លង់វែងដំបូងៗ គឺ តាម៉ុក ជាអ្នកចែកដីឲ្យប្រជាជន និងកងទ័ពទាំងអស់រស់នៅ ដោយក្នុងមួយគ្រួសារៗទទួលបានដីសម្រាប់សង់ផ្ទះមួយកន្លែង និងរបបអាហារហូបប្រចាំថ្ងៃ មានដូចជា អង្ករ ត្រីខកំប៉ុង ប៊ីចេង ស្ករស អំបិល ។ ពេលនោះ តាម៉ុក ជាអ្នកផ្គត់ផ្គង់គ្រប់បែបយ៉ាងដល់ការរស់នៅរបស់ប្រជាជនដែលទើបមកដល់តំបន់ថ្មីៗ (អន្លង់វែង) ។

យើន បានរៀបរាប់ថា ពេលមកដល់តំបន់នេះដំបូង គឺមានសុទ្ធតែព្រៃឈើធំៗព័ទ្ធជុំវិញ និងដុះយ៉ាងក្រាស់ ពិសេសដើមឈើមានតម្លៃ ជាមួយសត្វព្រៃជាច្រើនប្រភេទ និងភ្នំដងរែក ។ ពេលគាត់ដើរចូលព្រៃម្តងៗ គាត់មិន អាចមើលពន្លឺថ្ងៃរះឃើញទេ ព្រោះព្រៃដុះក្រាស់ និងមានដើមឈើ ខ្ពស់ៗដុះគ្របពីលើ ។

ព្រៃឈើទាំងនេះគឺជាជម្រកដល់សត្វព្រៃច្រើនប្រភេទរស់នៅ ។ ចំណែកឯអាកាសធាតុ គឺត្រជាក់ល្មមដែលអាចឲ្យប្រជាជនរស់នៅស្រួល និងមានទេសភាពពណ៌បៃតង ។ យើន បានបន្តថា ភូមិឈើទាលជ្រុំពីមុន គឺមានប្រជាជនរស់នៅច្រើនគ្រួសារដែលភាគច្រើនជាអតីតកងទ័ពខ្មែរក្រហម ។ ប្រជាជន គឺស្រឡាញ់ រាប់អានគ្នា និងអធ្យាស្រ័យឲ្យគ្នាទៅវិញទៅមក និងរស់នៅដោយភាពរីករាយ ។ ប្រជាជនដែលបានមករស់នៅភូមិឈើទាលជ្រុំនេះពីមុនមក ដោយសារភូមិនេះមានធនធានធម្មជាតិ និងមានផ្ទៃដីធំទូលាយ ។

ភូមិឈើទាលជ្រុំត្រូវបានកាន់កាប់ និងគ្រប់គ្រងដោយខ្មែរក្រហមដែលមាន តាម៉ុក ជាអ្នកដឹកនាំ ដែលមិនអនុញ្ញាតឲ្យមានការកាប់បំផ្លាញព្រៃឈើឡើយ ។ ភូមិនេះមានសាលារៀនមួយខ្នងបីបន្ទប់ ដំបូលប្រក់ស្បូវ ប៉ុន្តែសម័យនោះមិនទាន់មានវត្តអារាម និងមន្ទីរពេទ្យទេ ។ ក្រោយមក ប្រជាជនមួយចំនួន ក៏បានផ្លាស់ប្តូរទីលំនៅពីភូមិឈើទាលជ្រុំ ទៅរស់នៅទីប្រជុំជន និងមួយចំនួនទៀតបានវិលត្រឡប់ទៅស្រុកកំណើតរបស់ខ្លួនវិញ ព្រោះប្រជាជនទាំងនោះ បានគិតថា ភូមិនេះទៅថ្ងៃខាងមុខ ក៏មិនមានផ្លូវថ្នល់ សាលារៀន វត្តអារាម ដែរ ។

តាមការសង្កេតរបស់ យើន ក្រោយឆ្នាំ១៩៩៨ ពេលដែលយោធាខ្មែរក្រហមដែលនៅសេសសល់ធ្វើសមាហរណកម្មចុះចូលជាមួយរដ្ឋាភិបាលកម្ពុជា ពេលនោះប្រទេសក៏ចាប់ផ្តើមមានសុខសន្តិភាព ទើបធ្វើឲ្យកំណើនប្រជាជននៅតំបន់អន្លង់វែងមានការកើនឡើងជាជាបន្តបន្ទាប់ ចំណែកព្រៃឈើមានការថយចុះបន្តិចម្តងៗដែរ ដោយសារលំនៅដ្ឋានរបស់ប្រជាជនបានកើនឡើង ពិសេសចំនួនប្រជាជនដែលបានចូលមករស់នៅតំបន់អន្លង់វែងមានការកើនឡើងកាន់តែច្រើន ។ ព្រៃឈើត្រូវរងការទន្ទ្រានពីមនុស្សដើម្បីយកឈើ រានដីធ្វើស្រែចម្ការ និងសង់លំនៅដ្ឋានផ្ទាល់ខ្លួន ។

រហូតមកដល់បច្ចុប្បន្ននេះ អន្លង់វែង ហាក់ខុសប្លែកពីអ្វីដែល យើន បានឃើញកាលពីជាងម្ភៃឆ្នាំមុន ដោយសារមិនមានព្រៃឈើ ហើយដីដែលធ្លាប់តែមានព្រៃក្រាស់ៗក្លាយទៅជាវាល ដែលមានតែដី និងចម្ការរបស់អ្នកស្រុកប៉ុណ្ណោះ ។

**ធួន ឡៃហុល**

# វែង រី អតីតកងទ័ពរដ្ឋាភិបាល ដែលកម្លាំង តាម៉ុក ចាប់ខ្លួនបញ្ជូនទៅនៅអន្លង់វែង

អន្លង់វែង ជាអតីតតំបន់តស៊ូចុងក្រោយរបស់ខ្មែរក្រហមប្រឆាំងនឹងកងទ័ពរដ្ឋាភិបាល ។ តំបន់នេះសម្បូរទៅដោយព្រៃឈើក្រាស់ និងព័ទ្ធជុំវិញដោយភ្នំ ។ ប្រជាជនដែលរស់នៅតំបន់នេះ ភាគច្រើនជាអតីតខ្មែរក្រហម មកពីខេត្តផ្សេងៗ ។ វែង រី



កងដឹកជញ្ជូនទៅកាន់ស្រុកអន្លង់វែង នៅអំឡុងឆ្នាំ១៩៨៥

មានស្រុកកំណើតនៅខេត្តព្រៃវែង មករស់នៅស្រុកអន្លង់វែង បានរៀបរាប់ពីរឿងរ៉ាវរបស់គាត់ថា នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងទ័ពបដិវត្តន៍ខ្មែរក្រហមបានទទួលជ័យជម្នះទាំងស្រុងលើរដ្ឋាភិបាល លន់ នល់ ។ ខ្មែរក្រហមចាប់ផ្តើមជម្លៀសប្រជាជនដោយបង្ខំចេញ ពីផ្ទះសម្បែង ទីក្រុង និង ទីប្រជុំជននានានៅទូទាំងប្រទេស ។ គ្រួសាររបស់គាត់ពេលនោះដែលរស់នៅស្រុកកញ្ច្រៀច ខេត្តព្រៃវែង ក៏ត្រូវខ្មែរក្រហមជម្លៀសចេញពីភូមិជាមួយប្រជាជនឯទៀតដែរ ។ ដោយពេលនោះ គាត់ស្ថិតក្នុងវ័យកុមារនៅឡើយ ហេតុនេះ គាត់មិនសូវចងចាំនូវអ្វីដែលគាត់បានជួបប្រទះទេ ហើយគាត់ក៏មិនចាំថា ខ្មែរក្រហមបានជម្លៀសគាត់និងគ្រួសារទៅរស់នៅទីណាខ្លះដែរ ។ រី គ្រាន់តែចាំថា អង្គការបានចាត់តាំងគាត់ឲ្យចូលក្នុងកងកុមារ ។ ការងារដែល រី ធ្វើប្រចាំថ្ងៃគឺដើររើសអាចម៍គោ និងកាប់ទន្ទ្រានខែត្រ ។ រី ធ្វើការនៅកងកុមាររហូតដល់របបខ្មែរក្រហមដួលរលំនៅដើមឆ្នាំ១៩៧៩ ។

ស្ថិតក្នុងវ័យជំទង់ អំឡុងឆ្នាំ១៩៨៦-១៩៨៧ រី បានស្ម័គ្រចិត្តចូលធ្វើកងទ័ពរដ្ឋាភិបាល ឈរជើងនៅស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ។ អង្គភាពបានចាត់ឲ្យ រី រៀន សូត្រ និងហាត់បាញ់កាំភ្លើងធំ ។ មួយរយៈក្រោយមក អង្គភាពបានបញ្ជូនរី ទៅប្រយុទ្ធជាមួយកម្លាំងខ្មែរក្រហមដែលនៅសេសសល់ នៅប្រេកជាំ ខេត្តឧត្តរមានជ័យ ។ កម្លាំងទាំងពីរបានប្រយុទ្ធគ្នាជាបន្តបន្ទាប់ ដោយមិនអាចទប់ទល់នឹងកម្លាំងខ្មែរក្រហមបាន កម្លាំងរបស់ រី បានដកថយមកនៅព្រៃស្អាកវិញ ។ មកដល់ព្រៃស្អាក កម្លាំងរបស់ រី ដែលនៅសល់សមាជិកតែ២០នាក់ ក៏ត្រូវកម្លាំង តាម៉ុក ចាប់ខ្លួនបាន រួចបញ្ជូនទៅអន្លង់វែងវិញ ។ បន្ទាប់ពីបញ្ជូនទៅដល់អន្លង់វែង តាម៉ុក បានណែនាំ និងអប់រំដល់ក្រុមរបស់រី ឲ្យចុះចូលជាមួយខ្លួន និងចាត់តាំងឲ្យធ្វើជាយោធាដើម្បីប្រយុទ្ធនឹងកងទ័ពរដ្ឋាភិបាលវិញ ។ តាម៉ុក បានគំរាមថា ប្រសិនបើអ្នកទាំងអស់គ្នាមិនចុះចូលទេ នឹងត្រូវសម្លាប់ចោលទាំងអស់ ។ ដោយគ្មានផ្លូវជ្រើសរើស រី និងអ្នកដទៃទៀត បានយល់ព្រមចុះចូល ។ តាម៉ុក បានចាត់ឲ្យ រី ធ្វើការនៅក្នុងកងដឹកជញ្ជូន ដោយមានភារកិច្ចដឹកជញ្ជូនស្បៀងទៅសមរភូមិមុខ ។

បើតាមការរៀបរាប់របស់ រី អំពីបុគ្គលិកលក្ខណៈរបស់ តាម៉ុក នៅពេលដែល គាត់រស់នៅក្រោមការគ្រប់គ្រងរបស់ តាម៉ុក បានឲ្យដឹងថា សម្រាប់គាត់ផ្ទាល់ តាម៉ុក យកចិត្តទុកដាក់ជាមួយប្រជាជន និងកងទ័ពដែលរស់នៅតំបន់អន្លង់វែងខ្លាំងណាស់ ។ តាម៉ុក បានកសាងស្ពាន សាលារៀន មន្ទីរពេទ្យសម្រាប់ប្រជាជនអន្លង់វែង ។

នៅឆ្នាំ១៩៩៨ បន្ទាប់ពីការចាប់ខ្លួន តាម៉ុក និងការធ្វើសមាហរណរបស់កម្លាំងខ្មែរក្រហមដែលនៅសេសសល់ចុះចូលជាមួយរាជរដ្ឋាភិបាល រី បានរៀបការ និងរស់នៅស្រុកអន្លង់វែងរហូតដល់សព្វថ្ងៃ ។ **កុល ដាលីន**

# ជួង ជុន អតីតពេទ្យខ្មែរក្រហម

ជួង ជុន កើតនៅភូមិចេក ឃុំភ្នំស្រួច ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ។ ជុន មានឪពុកឈ្មោះ ឃួន មុត (ស្លាប់) និងម្តាយឈ្មោះ ជិន ភឺន (ស្លាប់) ។ ជុន មានបងប្អូនបង្កើតប្រាំនាក់ ប៉ុន្តែសព្វថ្ងៃនៅរស់តែប្អូននាក់ប៉ុណ្ណោះ ។

កាលពីសង្គមចាស់ ជុន បានរៀនសូត្រត្រឹមថ្នាក់ទី៩ (សង្គមចាស់) ក៏ឈប់រៀន ដោយគ្រួសារទីទាល់ ។ ជុន បានមកជួយធ្វើស្រែឪពុកម្តាយវិញ ។ រហូតដល់ឆ្នាំ១៩៧៣ ជុន បានចាកចេញពីគ្រួសារ ចូលទៅបម្រើកងទ័ពរំដោះ ។ កាលនោះ ជុន ទទួលបានការហ្វឹកហ្វឺនពីសំណាក់យោធាខ្មែរក្រហម ដើម្បីត្រៀមវាយជាមួយកងទ័ព លន់ នល់ ។

ក្នុងរយៈពេលចន្លោះពីឆ្នាំ១៩៧៣-៧៤ ជុន និងកងកម្លាំងខ្មែរក្រហម បានបើកការវាយលុកចូល ទីក្រុងភ្នំពេញតាមផ្លូវជាតិលេខ៥ រហូតដល់ទទួលបានជ័យជម្នះ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។

ក្រោយពីរបប លន់ នល់ ត្រូវបានដួលរំលំ កងកម្លាំងខ្មែរក្រហមបានចាប់ផ្តើមជម្លៀសប្រជាជនដែលរស់នៅទីក្រុងភ្នំពេញឲ្យទៅនៅតាមទីជនបទ ដោយប្រើរយៈពេលជិតមួយសប្តាហ៍ ។ បន្ទាប់ពីជម្លៀសប្រជាជនអស់ពីទីក្រុងហើយ ជុន ត្រូវបានខ្មែរក្រហមចាត់តាំងឲ្យទៅកាំបូលដើម្បីយាមការពារឃ្លាំងគ្រាប់អស់រយៈពេលមួយឆ្នាំ ។ បន្ទាប់មក អង្គការបានបញ្ជូន ជុន ឲ្យទៅនៅកោះកុង ហើយបានចាត់តាំងគាត់ឲ្យបម្រើការងារពេទ្យ ដែលគាត់មិនធ្លាប់រៀនមុខវិជ្ជានេះទាល់តែសោះ ។ ជុន បានបញ្ជាក់ថា គាត់ធ្វើពេទ្យចាប់តាំងពីឆ្នាំ១៩៧៧ រហូតដល់ខ្មែរក្រហមដួលរំលំនៅឆ្នាំ១៩៧៩ ។

ក្រោយមក ជុន បានរត់គេចខ្លួនពីខេត្តកោះកុង កាត់តាមព្រៃ និងព្រំដែន ជាមួយបក្ខពួកប្រមាណជាងដប់នាក់ ។ ដោយគ្មានអាហារហូបនៅតាមផ្លូវ ជុន បេះស្លឹកឈើ ឬផ្លែឈើព្រៃហូបជំនួសបាយ ។ អស់រយៈពេលជាងមួយខែ ទើប ជុន បានទៅដល់ទឹកដីថៃ ។

ជុន បានស្នាក់នៅក្នុងទឹកដីថៃ អស់រយៈពេលជាច្រើនខែ ទើប (នៅអំឡុងឆ្នាំ១៩៨១) កងទ័ពរាជរដ្ឋាភិបាលថៃ បានបញ្ជូនគាត់ និងបក្ខពួកឲ្យមករស់នៅខ្សែម ព្រំប្រទល់កម្ពុជា-ថៃវិញ ។ ក្រោយមក ការប្រយុទ្ធគ្នារវាងកងទ័ពរដ្ឋាភិបាល និងខ្មែរក្រហម បានកើតឡើង បណ្តាលឲ្យមនុស្សស្លាប់ និងរបួសបក្ខពួករបស់ ជុន មួយចំនួន ។

នៅឆ្នាំ១៩៨៥ ជុន បានមករស់នៅក្នុងស្រុកម៉ាឡៃវិញ ។ ជុន បានរៀបរាប់ថា ស្រុកម៉ាឡៃកាលនោះ គឺសម្បូរទៅដោយព្រៃក្រាស់ និងដើមឈើធំៗ ប៉ុន្តែសព្វថ្ងៃមិនមានព្រៃ ឬដើមឈើដូចពីមុនទេ ។ សម័យនោះ យោធាខ្មែរក្រហម បានកាប់ឈើលក់ ឬយកទៅដូរយកសម្ភារពីភាគីថៃ ។ ម្យ៉ាងទៀត មានប្រជាជនខ្លះបានកាប់ឈើដើម្បីសាងសង់ផ្ទះ ឬទន្រ្ទានកាប់ព្រៃដើម្បីយកដីធ្វើស្រែចម្ការ ។

នៅឆ្នាំ១៩៩៣ ជាដំណាក់កាលដំបូងនៃការបោះឆ្នោតដែលរៀបចំឡើងដោយ អ៊ុន តាក់ ប៉ុន្តែប្រជាជនដែលរស់នៅក្នុងស្រុកម៉ាឡៃ ភាគច្រើនមិនបានទៅចូលរួមបោះឆ្នោតទេ ។ រហូតដល់ឆ្នាំ១៩៩៨ ទើបខ្មែរក្រហមនៅក្នុងស្រុកម៉ាឡៃ បានធ្វើសមាហរណកម្មចុះចូលជាមួយរាជរដ្ឋាភិបាល ។

ជុន បានបញ្ជាក់ថា ក្រោយសមាហរណកម្ម ប្រជាជនដែលរស់នៅក្នុងស្រុកម៉ាឡៃ មានសិទ្ធិសេរីភាពពេញលេញ មានសន្តិសុខល្អ ហើយអាចប្រកបរបររកស៊ី និងធ្វើដំណើរទៅកន្លែងផ្សេងៗ ដោយគ្មានការព្រួយបារម្ភ ។ រីឯ ជុន ក៏មិនបានវិលត្រឡប់ទៅស្រុកកំណើតវិញដែរ ដោយគាត់គិតថា គាត់គ្មានសេសសល់ដីធ្លី ឬទ្រព្យសម្បត្តិអ្វីនៅទីនោះ ។ ដូច្នេះ ជុន បានសម្រេចចិត្តយកប្រពន្ធ ហើយប្រកបរបរ ធ្វើស្រែចម្ការ និងរស់នៅក្នុងស្រុកម៉ាឡៃរហូតមកដល់សព្វថ្ងៃ ។

**ហូ ថុណា**

# ឆាយ សិុន អតីតនីរសារគណៈស្រុកចុងកាល់

ឆាយ សិុន កើតក្នុងឆ្នាំ១៩៥៦ នៅភូមិត្រពាំងស្វាយ ឃុំអន្លង់ធំ ស្រុកសៀមរាប ខេត្តសៀមរាប ។ ឆាយ សិុន មានឪពុកឈ្មោះ ឆាយ ចាយ និងម្តាយឈ្មោះ ស៊ឹម ។ សិុន មានប្អូនប្រុសពីរនាក់ មួយឈ្មោះ ឆាយ ភ្លីវ និងម្នាក់ទៀតឈ្មោះ ឆាយ អឿន ដែលបានបែកគ្នាក្នុងសម័យក្រហមខ្មែរ និងបាត់ដំណឹងរហូតមកដល់សព្វថ្ងៃ ។

នៅក្នុងឆ្នាំ១៩៦៦ សិុន បានចាកចេញពីគ្រួសារទៅរស់នៅជាមួយឪពុកមានៅឃុំចុងកាល់ ស្រុកចុងកាល់ ខេត្តឧត្តរមានជ័យ ដោយសារគ្រួសារឪពុកមារបស់គាត់មិនមានកូនប្រុស ។ អំឡុងពេលនៅជាមួយឪពុកមា សិុន មានភារកិច្ចឃ្វាលគោ ។

នៅឆ្នាំ១៩៧០ បន្ទាប់ពីរដ្ឋប្រហារទម្លាក់សម្តេច សីហនុ សិុន និងក្រុមគ្រួសាររបស់ឪពុកមាបានទៅរស់នៅឃុំស្រែណូយ ស្រុកវ៉ារិន ខេត្តសៀមរាប ដោយសារពេលនោះ នៅក្នុងឃុំចុងកាល់មានភាពប្របូកប្រល់ ។ សិុន និងគ្រួសារឪពុកមាត្រូវធ្វើដំណើរដោយជិះរទេះគោ ដោយមានដឹកអង្ករ សម្លៀកបំពាក់ និងអីវ៉ាន់មួយចំនួនទៀត ។ ការធ្វើដំណើរពេលនោះត្រូវឆ្លងកាត់ស្រុកស្រីស្នំ ក្លូត និងត្រាំកង់ ដោយចំណាយជិតមួយខែ ទើបទៅដល់ស្រែណូយ ។ ទៅដល់ទីនោះ សិុន និងគ្រួសារឪពុកមា ត្រូវស្នាក់នៅបណ្តោះអាសន្នជាមួយអ្នកភូមិរយៈពេលមួយខែ ទើបអាចរកផ្ទះនិងដីផ្ទាល់ខ្លួនស្នាក់នៅបាន ។ ការរស់នៅទីនោះ មិនមានភាពខ្វះខាតឡើយ ព្រោះសម្បូរត្រី និងសត្វព្រៃ ។

មកដល់ឆ្នាំ១៩៧៣ ប្រជាជននៅស្រែណូយ ត្រូវបានខ្មែរក្រហមរៀបចំឲ្យហូបបាយរួម ហើយ សិុន ត្រូវបានចាត់តាំងឲ្យឃ្វាលគោ ព្រោះពេលនោះ គាត់នៅវ័យក្មេងនៅឡើយ ចំណែក



ឆាយ សិុន កំពុងអានសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩) នៅផ្ទះរបស់គាត់ នៅភូមិយាងខាងជើង ឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ។

ឪពុកមារបស់គាត់ត្រូវបានចាត់តាំងឲ្យធ្វើស្រែ ។ រីឯប្រជាជនផ្សេងទៀតត្រូវបានចាត់តាំងឲ្យធ្វើកិច្ចការរៀងៗខ្លួន ខ្លះធ្វើជាកងទ័ព និងខ្លះទៀតធ្វើស្រែ ។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ បន្ទាប់ពីខ្មែរក្រហមឡើងកាន់អំណាចនៅតំបន់ស៊ិន រស់នៅ ត្រូវបានខ្មែរក្រហមរំសាយអង្គភាពដែលបានរៀបចំនៅក្នុងឆ្នាំ១៩៧៣ ចោលទាំងអស់ ហើយខ្មែរក្រហមបានឲ្យប្រជាជនទាំងអស់នោះទៅរស់នៅភូមិកំណើតវិញ ។ ពេលនោះគ្រួសារឪពុកមារបស់ ស៊ិន បានត្រឡប់ទៅរស់នៅស្រុកកំណើតនៅចុងកាល់ ចំណែក ស៊ិន មិនបានត្រឡប់ទៅនៅជាមួយឪពុកមាទេ គឺគាត់បន្តរស់នៅឃុំស្រែណូយដដែល ដោយពេលនោះគាត់មាននាទីជាកងឈ្លប ។

រយៈពេលប្រមាណមួយឆ្នាំក្រោយមក បន្ទាប់ពីខ្មែរក្រហមបានស្រាវជ្រាវដឹងថា ស៊ិន មានស្រុកកំណើតនៅស្រុកចុងកាល់ គាត់ក៏ត្រូវបានកម្មាភិបាលខ្មែរក្រហមបញ្ជូនឲ្យមកធ្វើជាយោធានៅស្រុកចុងកាល់វិញ ដោយពេលនោះមាន ឆឹង ជាគណៈស្រុកចុងកាល់ និង សន ជាអនុលេខាស្រុក ។ ស៊ិនធ្វើការបានមួយរយៈក៏ត្រូវបានគណៈស្រុក ឆឹង ចាត់តាំងគាត់ឲ្យធ្វើជានីរសារ ប៉ុន្តែគាត់មិនសូវស្និទ្ធស្នាលជាមួយ ឆឹង ទេ ។

ស៊ិន បានរៀបរាប់ថា ក្នុងអំឡុងពេលធ្វើជានីរសាររបស់ ឆឹង គាត់បានយកសំបុត្រពីស្រុកទៅចែកតាមភូមិមួយចំនួន ដូចជាភូមិជើងទៀន ភូមិឆ្នូក ភូមត្រាំកង់ និងភូមិពង្រ ដោយជិះកង់ដែលផលិតនៅចិន (កង់តួប្រុស) ហើយជួនកាលគាត់ជិះសេះ ប្រសិនបើផ្លូវឆ្ងាយ និងមានខ្សាច់ច្រើន ។ សំបុត្រពេលនោះ គឺត្រូវបានបិទភ្ជិតដោយមានសរសេរឈ្មោះតំបន់ដែលត្រូវយកទៅប្រគល់ឲ្យនៅពីលើសំបុត្រនោះ ។

ក្រៅពីធ្វើជានីរសារ ស៊ិន ត្រូវបានចាត់តាំងឲ្យធ្វើជាអ្នកយាមគុកនៅវត្តចុងកាល់ ប៉ុន្តែដោយសារក្នុងចំណោមអ្នកយាមគុកទាំងអស់សុទ្ធសឹងជាមនុស្សដែលមានវ័យចំណាស់ជាងគាត់ ដូច្នេះ គាត់ក៏ត្រូវបានអ្នកនៅក្នុងក្រុមជាមួយគ្នាចាត់តាំងគាត់ឲ្យធ្វើជាអ្នកដាំបាយឲ្យអ្នកទោសហូប ។ ស៊ិន បានបន្តថា នៅមន្ទីរសន្តិសុខវត្តចុងកាល់ មិនមានការសម្លាប់អ្នកទោសទេ ប៉ុន្តែអ្នកទាំងអស់នោះត្រូវបានដឹកតាមឡានយកទៅសម្លាប់នៅកន្លែងផ្សេង ។



ឆាយ ស៊ិន បានប្រគល់សាក់កាដូដែលគាត់បានរក្សាទុកក្នុងអំឡុងពេលគាត់នៅបម្រើកងទ័ពខ្មែរក្រហម មកឲ្យបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាដើម្បីរក្សាទុក ។

ក្នុងរយៈពេលបួនទៅដប់ថ្ងៃ មានអ្នកទោសយ៉ាងតិចមួយឡាន ត្រូវបានដឹកទៅកន្លែងផ្សេង ហើយការដឹកភាគច្រើនគឺធ្វើឡើងនៅម៉ោង១២យប់ ។

នៅពាក់កណ្ដាលឆ្នាំ១៩៧៧ ឪពុកមារបស់ សុិន ត្រូវបានខ្មែរក្រហមសម្លាប់ចោលដោយចោទប្រកាន់ថា ជាធ្មប់ ហើយក្រោយមក នៅចុងឆ្នាំ១៩៧៧ សុិន ត្រូវបានកម្មាភិបាលខ្មែរក្រហមដកចេញពីកងយោធាទៀត បន្ទាប់ពីស្រាវជ្រាវដឹងថា សុិន មានជាប់សាច់ឈាមជាមួយឪពុកមាដែលខ្មែរក្រហមបានចោទប្រកាន់ ។

ក្រោយដកចេញពីយោធា សុិន បានមករស់ក្នុងសហករណ៍នៅស្រុកចុងកាល់ដែលមាន មូល ជាប្រធានសហករណ៍ ។ មូល បានចាត់តាំង សុិន ឲ្យដឹកប្រឡាយ ប៉ុន្តែ សុិន បដិសេធដោយសុំធ្វើការងារផ្សេងក្រៅពីដឹកប្រឡាយ ។

បើតាមការឲ្យដឹងពី សុិន មូល ស្រឡាញ់ចូលចិត្តគាត់ណាស់ ។ មូល ក៏បានទាក់ទងទៅភូមិជ្រោយធ្លូនដោយសារ មូល ទទួលដំណឹងថា នៅជ្រោយធ្លូន ត្រូវការព្រូឡានពីរនាក់ដើម្បីលើកដាក់អីវ៉ាន់ ។ មូល បានបញ្ជូន សុិន និង ជិត ឲ្យទៅធ្វើការនៅជ្រោយធ្លូនវិញ ។ ពេលទៅដល់ជ្រោយធ្លូន សុិន ត្រូវបានចាត់តាំងឲ្យធ្វើការនៅក្នុងក្រុមជាមួយ រ៉េត ដែលស្គាល់ និងជាមិត្តភក្តិគ្នាតាំងពីតូចម្ល៉ះ ។ សុិន ធ្វើការងារបើកឡាន និងព្រូឡានជាមួយ រ៉េត រហូតដល់ចុងឆ្នាំ១៩៧៨ ទើបបែកគ្នាបន្ទាប់ពីរបបខ្មែរក្រហមដួលរលំ ។

សុិន បានត្រឡប់ទៅភូមិត្រពាំងស្វាយ ឃុំអង្គរធំ ស្រុកសៀមរាប ខេត្តសៀមរាប ដែលជាស្រុកកំណើតវិញ ។ សុិន បានរស់នៅជាប្រជាជនធម្មតា ក្រោមការការពារពីកងទ័ពវៀតណាមនៅទីនោះ ។ មួយរយៈក្រោយមក សុិន ត្រូវបានជ្រើសរើសឲ្យចូលកងទ័ពរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាវិញ ។ នៅពាក់កណ្ដាលឆ្នាំ១៩៧៩ សុិន ត្រូវបានជ្រើសរើសឲ្យទៅរៀនក្បួនយោធានៅវៀតណាមរយៈពេលប្រាំមួយខែ នៅខេត្តតាយនិញ ដែលមានគ្រូជនជាតិខ្មែរ និងជនជាតិវៀតណាមជាអ្នកបង្រៀន ។ ត្រឡប់មកពីប្រទេសវៀតណាមវិញ សុិន ត្រូវបានចាត់តាំងឲ្យចូលនៅក្នុងកងទ័ពស្រួច នៅសាលាលីសេ ខេត្តសៀមរាប ។ នៅដើមឆ្នាំ១៩៨០ សុិន បានចាកចេញពីកងទ័ព ដោយសារគាត់ខឹងមេបញ្ជាការដែលស្ដីបន្ទោសគាត់ ។ បន្ទាប់ពីចាកចេញពីកងទ័ពរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាបានមួយរយៈ សុិន បានត្រឡប់ទៅបម្រើកងទ័ពខ្មែរក្រហមវិញ ។ សុិន បាន ចូលនៅក្នុងកងពល៩២ ដោយមានឈ្មោះ ម៉ុន ជាមេកងពល ឈរជើងនៅវាលស្រងាំ ។ ក្រោយមក កងពលរបស់ សុិន បានចល័តទៅឈរជើងនៅអូរក្រញូង ដាំកង់ ជប់ម្លូរ និងកន្លែងផ្សេងៗទៀត ។ នៅឆ្នាំ ១៩៨៥ សុិន បានពិការជើងដោយសារជាន់មីន ដែលបង្កប់ដោយកងទ័ពវៀតណាម ។

នៅឆ្នាំ១៩៨៦ សុិន បានរៀបការជាមួយប្រពន្ធឈ្មោះ បុិល សារ៉ាត់ ដែលជាប្រធានកងដឹកជញ្ជូនគ្រាប់ និងស្បៀងទៅភ្នំ១០០៣ ។ នៅក្នុងពិធីរៀបការរបស់ សុិន ពេលនោះគឺមាន រ៉ែន ប្រធានកងពល បានចូលរួមជាគណៈអធិបតី ។

នៅឆ្នាំ១៩៩០ សុិន និងប្រពន្ធបានចុះពីលើភ្នំមករស់នៅអន្លង់វែង ។ ប៉ុន្តែគាត់រស់នៅបានមួយរយៈ ក៏នាំប្រពន្ធត្រឡប់ទៅលើភ្នំដងរែកវិញ បន្ទាប់ពីមានការប្រយុទ្ធរវាងកងទ័ពរដ្ឋាភិបាល និងយោធាខ្មែរក្រហម ។ សុិន បានរស់នៅលើភ្នំរយៈពេលជិតមួយខែ ទើបគាត់ត្រឡប់មកនៅអន្លង់វែងវិញ រហូតដល់សមាហរណកម្មឆ្នាំ១៩៩៨ ។

មកដល់ឆ្នាំ១៩៩៩ សុិន និងភរិយា បានប្ដូរទៅរស់នៅភូមិយាងខាងជើង ឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ រហូតមកដល់បច្ចុប្បន្ន ។ សព្វថ្ងៃ សុិន មានកូនបីនាក់ ហើយកូនៗរបស់គាត់សុទ្ធតែមានប្ដីប្រពន្ធអស់ហើយ ។

**ឃាង សេងហឿន**

## អានទស្សនាវដ្ដីតាមគេហទំព័រ

ទស្សនាវដ្ដីស្វែងរកការពិតត្រូវបានផ្សព្វផ្សាយតាមគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ អ្នកអានអាចរកបានតាមៈ http://d.dccam.org/Projects/Magazines/Magazine_Searching.htm ។ ព័ត៌មានបន្ថែម សូមទាក់ទង សោម ប៊ុនថន ទូរស័ព្ទលេខ ០ ១២ ៩៩៦ ៧៥០ ឬ ០២៣ ២១១ ៨៧៥ ។

# របបខ្មែរក្រហមបានធ្វើឱ្យ វ៉ាន់ បាត់បង់ មនុស្សជាទីស្រឡាញ់

ខ្ញុំបានចូលរួមដំណើរទស្សនកិច្ចសិក្សារបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ទៅកាន់ស្រុកអន្លង់វែង ដែលជាអតីតតំបន់តស៊ូចុងក្រោយនៃរបបខ្មែរក្រហម ក្រោយពីរបបនេះបានដួលរលំនៅដើមឆ្នាំ១៩៧៩ ។ បន្ទាប់ពីស្ដាប់ការធ្វើបទបង្ហាញត្រួសៗអំពីតំបន់អន្លង់វែងពី សំណាក់អ្នកសម្របសម្រួលនៃកម្មវិធីមក ខ្ញុំ ក៏ត្រូវបានផ្ដល់ឱកាសឲ្យចុះសាកសួរប្រជាជនអំពីបទពិសោធជីវិតដែលបានឆ្លងកាត់របបខ្មែរក្រហម ។ ខ្ញុំបានជួបសម្ភាសផ្ទាល់ជាមួយអ៊ុំស្រី យ៉ុន វ៉ាន់ ហៅ ស្រីពៅ ដែលបានរស់នៅតំបន់អន្លង់វែងតាំងពីសង្គមចាស់ ។ វ៉ាន់ បានរំឭករឿងរ៉ាវដែលគាត់ធ្លាប់បានឆ្លងកាត់ និងជួបប្រទះប្រាប់ដល់ខ្ញុំដូចខាងក្រោម ៖

វ៉ាន់ កើតនៅឆ្នាំ១៩៦៣ នៅភូមិលំទងចាស់ ឃុំលំទងចាស់ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ។ វ៉ាន់ ជាកូនពៅក្នុងគ្រួសារកសិករ ដែលមានបងប្អូនប្រុសស្រី៦នាក់ ។ ដោយសារតែគាត់ជាកូនស្រីពៅ ទើបគ្រួសាររបស់គាត់ ស្រឡាញ់ថ្នាក់ថ្នមគាត់ជាងគេ ។ វ៉ាន់ ចូលចិត្តច្រៀងណាស់ ។ ដោយសារតែ វ៉ាន់ នៅវ័យក្មេងនៅឡើយ ហេតុនេះគាត់មិនសូវចងចាំអំពីអ្វីដែលបានកើតឡើងក្នុងអំឡុងឆ្នាំ១៩៧០នោះទេ គឺគាត់គ្រាន់តែដឹងថា គ្រួសាររបស់គាត់រស់នៅ និងធ្វើស្រែចម្ការជាធម្មតា ។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានគ្រប់គ្រងប្រទេសទាំងស្រុង ។ វ៉ាន់ បានឲ្យដឹងថា រយៈពេលដប់ថ្ងៃ



រូបខាងឆ្វេង ៖ យ៉ុន វ៉ាន់ បានផ្ដល់បទសម្ភាសដល់ ហួត សេងលីម បុគ្គលិកស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង នៅភូមិលំទងចាស់ ឃុំលំទងចាស់ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ

បន្ទាប់មក ខ្មែរក្រហមក៏បានជម្លៀសប្រជាជនចេញពីភូមិ ដែលក្នុងប្រជាជនទាំងនោះ ក៏មានគ្រួសាររបស់គាត់ដែរ ។ អង្គការបានជម្លៀសគ្រួសាររបស់គាត់ឲ្យទៅរស់នៅភូមិកំពង់ស្តូល ឃុំកំពង់ស្តូល ស្រុកក្រឡាញ់ ខេត្តសៀមរាប ។ ទៅដល់ភូមិ អង្គការបានប្រកាសឲ្យប្រជាជនទាំងអស់ប្រមូលទ្រព្យសម្បត្តិ ចាន ឆ្នាំង យកមកដាក់សមូហភាព ។ ឪពុករបស់ វ៉ាន់ បានសួរទៅកម្មាភិបាលម្នាក់ថា "តើឯណាផ្ទះសម្រាប់គ្រួសារខ្ញុំស្នាក់នៅ?" កម្មាភិបាលនោះឆ្លើយថា "គ្មានផ្ទះអាស្រ័យស្អីទេ ឲ្យតែមានកន្លែងដេកទៅបានហើយ!" ។

ក្រោយមក អង្គការបានបែងចែកប្រជាជនឲ្យធ្វើការតាមក្រុម និងកងដោយគិតទៅតាមអាយុរបស់ប្រជាជន ។ ស្ថិតក្នុងវ័យ ១២ឆ្នាំ វ៉ាន់ ត្រូវអង្គការចាត់ឲ្យចូលធ្វើការនៅកងចល័ត ។ រៀងរាល់ថ្ងៃ វ៉ាន់ ធ្វើការស្ទើរតែ២០ ម៉ោង ដោយប្តូរបានមកវិញ ត្រឹមតែបបរមួយកូនចានប៉ុណ្ណោះ ។ នៅឆ្នាំ១៩៧៧ វ៉ាន់ និងគ្រួសារត្រូវបានអង្គការជម្លៀសលើកទីពីរ ទៅខេត្តស្ទឹងត្រែង ។ អំឡុងពេលធ្វើដំណើរ បងប្រុសច្បងរបស់គាត់បានស្លាប់ ដោយសារតែការហត់នឿយក្នុងដំណើរដ៏វែងឆ្ងាយនោះ ។ វ៉ាន់ និងគ្រួសារ បានធ្វើដំណើរអស់រយៈពេលជាច្រើនខែ ទម្រាំទៅដល់ខេត្តស្ទឹងត្រែង ប៉ុន្តែអ្វីដែលគាត់នឹកស្មានមិនដល់នោះ គឺគ្រាន់តែគ្រួសារគាត់ ទៅដល់មិនបានកន្លះម៉ោងផង អង្គការចាត់ឲ្យទៅធ្វើការភ្លាម ដោយមិនឲ្យសម្រាកឡើយ ។

អ្វីដែល វ៉ាន់ បំភ្លេចមិនបាន មានថ្ងៃមួយ ឪពុករបស់គាត់ឃើញកូនស្រេកឃ្លានខ្លាំងពេក ក៏ប្រថុយជីវិតទៅលួចជីកដំឡូងយកមកស្ងោរឲ្យកូនហូប ។ ប៉ុន្តែមកដល់ផ្ទះមិនបានប៉ុន្មានផង កងឈ្លបក៏មកទាន់ រួចហើយចាប់ឪពុកគាត់យកទៅសម្លាប់តែម្តង ។ ឈ្លបបានចោទប្រកាន់ឪពុករបស់គាត់ថា "ជាខ្មាំងក្បត់សមូហភាព និងអង្គការ ដែលត្រូវតែយកទៅរៀនសូត្រ" ។ ការបាត់បង់បងប្រុស និងឪពុកបានធ្វើឲ្យគ្រួសាររបស់ វ៉ាន់ រន្ធត់ចិត្តយ៉ាងខ្លាំង ជាពិសេស ការលះបង់របស់ឪពុកគាត់ចំពោះគ្រួសារ ។

មានពេលមួយ វ៉ាន់ បានដើរជាន់បន្លា បណ្តាលឲ្យមុត និងហើមជើងដើរមិនរួច ។ ម្តាយ និងបងៗរបស់គាត់ បានស្នើសុំអង្គការដើម្បីមើលថែគាត់ ប៉ុន្តែអង្គការបានបដិសេធនឹងការស្នើសុំនោះ ។ វ៉ាន់ បានរៀបរាប់ទាំងអារម្មណ៍ឈឺចាប់ថា អង្គការមិនត្រឹមតែ មិនអនុញ្ញាតឲ្យម្តាយ និងបងៗមកមើលគាត់ទេ ថែមទាំងប្រាប់គាត់ថា "បើចង់មកសម្រាក អង្គការក៏គ្មានបាយឲ្យស៊ីដែរ សម្រាប់អ្នកឈឺ" ។ ហេតុនេះ វ៉ាន់ ត្រូវខិតខំប្រឹងប្រែងទាំងឈឺទៅធ្វើការដើម្បីទទួលបានរបបអាហារ ។

នៅអំឡុងឆ្នាំ១៩៧៨ មានការវាយប្រយុទ្ធគ្នារវាងខ្មែរក្រហម និងវៀតណាម និងមានការបាញ់ផ្លោងដាក់គ្នាទៅវិញទៅមក ។ គាប់ជួនគ្រាប់ផ្លោងបានធ្លាក់ និងខ្ទាតអម្បែងមកត្រូវម្តាយរបស់ វ៉ាន់ បណ្តាលឲ្យស្លាប់នៅពេលនោះតែម្តង ។ វ៉ាន់ និងបងៗមានអារម្មណ៍រន្ធត់យ៉ាងខ្លាំង ចំពោះព្រឹត្តិការណ៍នេះ ដោយសារតែបាត់បង់មនុស្សជាទីស្រឡាញ់ក្នុងគ្រួសារម្នាក់ទៀត បន្ទាប់ពីបងប្រុសច្បង និងឪពុក ។

បន្ទាប់ពីមរណភាពម្តាយ វ៉ាន់ ហាក់មានអារម្មណ៍តែលតោល និងគិតចង់សម្លាប់ខ្លួន ។ ប៉ុន្តែគាត់បាននឹកឃើញពាក្យចាស់ប្រដៅថា "ជីវិត គឺជាការតស៊ូ" ហេតុនេះទើបធ្វើឲ្យគាត់មានសង្ឃឹម និងតស៊ូរស់បន្តទៀត ។

នៅដើមឆ្នាំ១៩៧៩ របបខ្មែរក្រហមត្រូវបានផ្តួលរំលំ វ៉ាន់ និងគ្រួសារ បានធ្វើដំណើរត្រឡប់មកភូមិលំនៅចាស់ ដែលជាភូមិកំណើតវិញ ។ គាត់បានត្រឡប់មកនៅលើទីតាំងផ្ទះរបស់គាត់ពីមុន ។

អំឡុងពេលនោះ តំបន់ដែល វ៉ាន់ រស់នៅ គឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់ តាម៉ុក ដែលជាមេដឹកនាំជាន់ខ្ពស់មួយរូបរបស់ខ្មែរក្រហម ។ បើនិយាយអំពី តាម៉ុក នៅពេលនោះ វ៉ាន់ គ្រាន់តែដឹងថា តាម៉ុក គ្រប់គ្រង និងយកចិត្តទុកដាក់ប្រជាជនណាស់ ព្រមទាំងបានកសាងសាលារៀន មន្ទីរពេទ្យ ស្ពាន ថ្នល់ និងបឹងស្តុកទឹកយ៉ាងធំ សម្រាប់ប្រជាជនប្រើប្រាស់ទៀតផង ។

ទោះបីជាយ៉ាងណា វ៉ាន់ នៅតែមានអារម្មណ៍ស្អប់របបខ្មែរក្រហម ព្រោះរបបនេះបានបន្សល់នូវការឈឺចាប់ និងធ្វើឲ្យគាត់បាត់បង់មនុស្សជាទីស្រឡាញ់ ។ ជារឿយៗ វ៉ាន់ តែងតែនិយាយអំពីរបបខ្មែរក្រហមប្រាប់ដល់កូនៗ ។ នៅឆ្នាំ១៩៨២ វ៉ាន់ បានរៀបការជាមួយឈ្មោះ អ៊ុំ សាវឿន (ស្លាប់) និងមានប្រុសស្រីចំនួន៤នាក់សព្វថ្ងៃ ។

**ហ្វូត សេងលីម**

# ដំណើរទស្សនកិច្ចទៅអន្លង់វែង ធ្វើឱ្យខ្ញុំចាប់អារម្មណ៍កាន់តែខ្លាំងលើប្រវត្តិសាស្ត្រ

ចាប់តាំងពីខ្ញុំចូលរៀននៅសាលាចំណេះទូទៅ រហូតដល់មហាវិទ្យាល័យ ខ្ញុំមិនដែលមានឱកាសទៅដល់តំបន់ឆ្ងាយៗទេ ទើបតែពេលថ្មីៗនេះ ខ្ញុំបានមកដល់តំបន់អន្លង់វែង ដែលជាតំបន់តស៊ូចុងក្រោយរបស់ខ្មែរក្រហម ។ ខ្ញុំគិតថា ខ្ញុំមានសំណាងណាស់ដែលបានមកដល់តំបន់ដែលធ្លាប់តែកើតមានសង្គ្រាមនេះ ព្រោះបានធ្វើឲ្យខ្ញុំមានការយល់ដឹងកាន់តែច្រើនពីប្រវត្តិសាស្ត្រ និងការរស់នៅរបស់ប្រជាជនក្នុងតំបន់នេះ ។ ទោះបីជាប្រទេសកម្ពុជាបានឆ្លងកាត់របបគ្រប់គ្រងជាច្រើន មកហើយ ប៉ុន្តែខ្ញុំគិតថា មានរបបមួយប៉ុណ្ណោះដែលប្រជាជនខ្មែរចងចាំជាងគេ គឺ "របបកម្ពុជាប្រជាធិបតេយ្យ" ឬហៅជាទូទៅថា "របបខ្មែរក្រហម" ។ របបនេះបានឆក់យកជីវិតប្រជាជនខ្មែរស្លូតត្រង់ប្រមាណជាង១.៧លាននាក់ ។



រូបរាប់ពីឆ្វេង ៖ សយ ណាទ្រី បុគ្គលិកស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង និង ខាំ វ៉ា ថតនៅភូមិលំទងចាស់ ឃុំលំទង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ។

ភាពឃោរឃៅក្នុងរបបខ្មែរក្រហម បានធ្វើឲ្យប្រជាជនកម្ពុជាខ្លាចរអារ ។ ដូច្នេះ ប្រវត្តិសាស្ត្រនៃរបបនេះពិតជាមានសារសំខាន់ណាស់សម្រាប់មនុស្សជំនាន់ក្រោយ សិក្សារៀនសូត្រ ។

កន្លងទៅថ្មីៗនេះ នាងខ្ញុំជាមួយនឹងនិស្សិតស្ម័គ្រចិត្ត១៥នាក់ផ្សេងទៀត បានចូលរួមដំណើរទស្សនកិច្ចសិក្សាទៅកាន់តំបន់ប្រវត្តិសាស្ត្រអន្លង់វែង ដែលរៀបចំដោយមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ។ បន្ទាប់ពីចូលរួមស្តាប់បទបង្ហាញរបស់អ្នកសម្របសម្រួលកម្មវិធី អំពីប្រវត្តិត្រួសៗនៃតំបន់អន្លង់វែង យើងទាំងអស់គ្នា បានធ្វើដំណើរទៅភូមិលំទងចាស់ ឃុំលំទង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ដើម្បីធ្វើការសម្ភាសជាមួយអ្នកភូមិ ក្នុងគោលបំណងសិក្សាស្វែងយល់អំពីបទពិសោធជីវិតរបស់គាត់ និងរឿងរ៉ាវខ្លះដែលបានកើតឡើងនៅស្រុកអន្លង់វែងកាលពីអតីតកាល ។ យើងបានធ្វើរដំណើរនៅលើផ្លូវលំបណ្តើរ គយគន់ទេសភាពតាមដងផ្លូវបណ្តើរ ។ ផ្លូវដែលយើងធ្វើដំណើរមានសភាពស្ងប់ស្ងាត់យូរម្តងៗទើបយើងឃើញឡានម៉ូតូបើកទៅមក ។ ពេលទៅដល់ស្ពាន ពេលខ្លះយើងទាំងអស់គ្នាត្រូវបង្ខំចិត្តចុះដើរ ព្រោះស្ពានដែលយើងត្រូវឆ្លងកាត់មានសភាពទ្រុឌទ្រោម ។ ក្រោយពីធ្វើដំណើរអស់រយៈពេលកន្លះម៉ោង យើងបានទៅដល់ផ្ទះអ្នកភូមិ ។ ផ្ទះអ្នកភូមិលំទងចាស់ ច្រើនជាផ្ទះឈើប្រក់ស័ង្កសីនៅក្នុងដីឡូត៍ដែលមានទីធ្លាធំទូលាយ ។ នៅតាមផ្ទះអ្នកភូមិភាគច្រើនចិញ្ចឹម គោក្របី ជ្រូក មាន់ ទា និងមានដាំផ្កា ដំណាំបន្តិចបន្តួចនៅខាងមុខផ្ទះ ។ ចំណែកឯរបរចញ្ចឹមជីវិតប្រចាំថ្ងៃរបស់ប្រជាជនភាគច្រើន ធ្វើស្រែ ចម្ការ និងដាំដំឡូងមី ។ ផ្ទះរបស់អ្នកភូមិ ពុំសូវមានបង្គន់អនាម័យត្រឹមត្រូវទេ ដូច្នេះពេលបន្ទោបង់ម្តងៗអ្នកទាំងនោះត្រូវដើរចូលទៅព្រៃ ។

យើងបានបែងចែកក្រុមដើម្បីសម្ភាសប្រជាជន ដោយក្នុងមួយក្រុមមានសមាជិក៨នាក់ ដោយឡែក ក្រុមខ្ញុំមានសមាជិកតែ

៣នាក់ប៉ុណ្ណោះ ។ យើងទាំងបីបានដើរទៅដល់ផ្ទះមួយ ដែលមានអ៊ំប្រុសម្នាក់កំពុងសម្រាកនៅលើគ្រែក្រោមផ្ទះ ។ ភ្នែកដែលអ៊ំចិញ្ចឹមបានព្រុសយើងទាំងបីយ៉ាងខ្លាំង ស្ទើរតែធ្វើឲ្យយើងភ័យ និងចង់រត់ម្តងៗ ។ អ៊ំបានដេញឆ្កែចេញ និងហៅខ្ញុំទាំងបីឲ្យចូលមកអង្គុយលេង ។ ខ្ញុំទាំងអស់គ្នាបានណែនាំខ្លួន និងប្រាប់ពីបំណងដែលមកភូមិលំទងនេះ បន្ទាប់ពីស្តាប់រួច អ៊ំរីករាយ និងរៀបរាប់អំពីបទពិសោធជីវិតដែលគាត់ធ្លាប់បានឆ្លងកាត់ និងក្រោយពេលដែលគាត់មករស់នៅអន្លង់វែងនេះ ។

អ៊ំមានឈ្មោះថា ខាំ វ៉ា អាយុ៥៨ឆ្នាំ មានប្រពន្ធឈ្មោះ ចាន់ សុភី ដែលជាអ្នករស់នៅភូមិលំទងផ្ទាល់តែម្តង ។ វ៉ា ជាអ្នកចម្ងាយមកពីឃុំព្រៃឃ្នាស ស្រុកមេសាង ខេត្តព្រៃវែង ។ វ៉ា ជាកូនទី៦ ក្នុងចំណោមបងប្អូនបង្កើត៨នាក់ ។ បងប្រុសរបស់គាត់ពីរនាក់ បានស្ម័គ្រចូលធ្វើជាទាហាន "គាត់មិនចាំថា ទាហានខាងណាទេ" និងបាត់ខ្លួនតាំងពីមុនរបបខ្មែរក្រហមម្ល៉េះ ។ ក្រោយថ្ងៃរំដោះ ខែមេសា ឆ្នាំ១៩៧៥ វ៉ា ដែលមានវ័យ១២ឆ្នាំ ត្រូវបានខ្មែរក្រហមជម្លៀសចេញពីផ្ទះដោយបង្ខំជាមួយនឹងម្តាយ (ឪពុកស្លាប់ឆ្នាំ១៩៧៣) និងបងប្អូន៥នាក់ ឲ្យទៅរស់នៅភូមិកំពង់ថ្កូវ ស្រុកក្រឡាញ់ ខេត្តសៀមរាប ។ ទៅដល់ភូមិកំពង់ថ្កូវ អង្គការបានបែងចែកប្រជាជនទៅតាមក្រុម និងកងរៀងៗខ្លួន ។ វ៉ា ត្រូវបានអង្គការចាត់ឲ្យចូលធ្វើការក្នុងកងកុមារ ដោយមានតួនាទី ឃ្វាលគោ និងក្របី ។ វ៉ា រៀបរាប់លាយឡំជាមួយសំណើចប្រាប់ខ្ញុំថា ក្មេងៗក្នុងកងកុមារឃ្វាលគោជាមួយគ្នាតែងតែហៅខ្ញុំថា "ប្រធានក្របី" ។ វ៉ា ជាក្មេងម្នាក់ដែលចូលចិត្តលេងសើចច្រើន ហេតុនេះ គាត់តែងតែត្រូវមេកងស្តីបន្ទោសជាញឹកញាយ ប៉ុន្តែមិនបានដាក់ទោសគាត់ទេ ។ ចំពោះម៉ោងពេលធ្វើការសម្រាប់កងរបស់គាត់ មិនខុសពីមនុស្សពេញវ័យទេ ម្នាក់ៗត្រូវងើបតាំងពីម៉ោង៤ភ្លឺ ឃ្វាលគោក្របីរហូតដល់ម៉ោង១២ថ្ងៃត្រង់ ទើបឈប់សម្រាកហូបអាហារ ។ បន្ទាប់ពីហូបអាហារថ្ងៃត្រង់រួចហើយ គាត់បន្តធ្វើការរហូតដល់ម៉ោង៦ល្ងាចទៀត ។ វ៉ា បានឲ្យដឹងថា នៅភូមិកំពង់ថ្កូវ មានប្រជាជនរស់នៅប្រហែល៥០០ ទៅ ៦០០គ្រួសារ ។ នៅរៀងរាល់១៥ថ្ងៃម្តង អង្គការបានឲ្យចុងភៅកាប់គោ ឬជ្រូកមួយដើម្បីយកមកធ្វើម្ហូប ។


ផ្ទះរបស់អ្នកភូមិនៅក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ



ខាំ វ៉ា នៅផ្ទះរបស់គាត់នៅភូមិលំទងចាស់ ឃុំលំទង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ។

ក្រោយរបបខ្មែរក្រហមដួលរលំ នៅដើមឆ្នាំ១៩៧៩ វ៉ា បានបាត់បង់បងប្អូន៤នាក់រួមមានបងប្រុស និងបងស្រី ដែលត្រូវបានអង្គការយកទៅសម្លាប់ជាបន្តបន្ទាប់ដោយគ្មានមូលហេតុ ។ ក្នុងចំណោមសមាជិកគ្រួសារ៧នាក់របស់គាត់ នៅរស់រានមានជីវិតតែម្តាយគាត់ និងប្អូនស្រីគាត់ម្នាក់ប៉ុណ្ណោះ ។ នៅអំឡុងពេលនោះ កងកម្លាំងខ្មែរក្រហមដែលនៅសេសសល់ក៏បានកៀរប្រជាជនឲ្យមករស់នៅតំបន់អន្លង់វែងវិញ ហើយ វ៉ា ក៏ត្រូវបានកៀរមកជាមួយដែរ ។ វ៉ា បានធ្វើដំណើរមកភូមិលំទងចាស់ ឃុំលំទង ស្រុកអន្លង់វែង ជាកន្លែងដែលគាត់បានជួប និងរៀបការជាមួយប្រពន្ធរបស់គាត់ ។ នៅអំឡុងឆ្នាំ១៩៨៩ វ៉ា ត្រូវបានថ្នាក់លើចាត់ឲ្យធ្វើការងារ នៅក្នុងកងដឹកជញ្ជូន ដោយមាននាទីដឹកជញ្ជូនគ្រាប់កាំភ្លើង និងចម្រូងទៅសមរភូមិមុខ ។ ក្រៅពីការងារដឹកជញ្ជូន វ៉ា ក៏មាននាទីបិទចម្រូងដែរ ដោយក្នុងមួយថ្ងៃយ៉ាងហោចណាស់គាត់បិទចម្រូងឲ្យបាន១០០ ។ វ៉ា មិនសូវបានមកជួបប្រពន្ធកូននៅភូមិទេ ហើយប្រពន្ធរបស់គាត់ដែលរស់នៅក្នុងភូមិ ក្រៅពីការងារថែទាំផ្ទះសម្បែង កូនៗ និងធ្វើស្រែចម្ការ ក៏តម្រូវឲ្យបិទចម្រូងដែរ ។

រំឭកអំពី តាម៉ុក វិញ វ៉ា បានឲ្យដឹងថា អន្លង់វែងស្ថិតក្រោមការគ្រប់គ្រងរបស់ តាម៉ុក ។ ការរស់នៅរបស់ប្រជាជនមិនសូវរឹតត្បិតដូច ក្នុងរបបខ្មែរក្រហមទេ ។ តាម៉ុក ពេលនោះ បានកសាងផ្លូវ សាលារៀន មន្ទីរពេទ្យ ទំនប់ ជាដើម ។ តាម៉ុក ជាអ្នកទំនុកបម្រុងប្រជាជននៅតំបន់អន្លង់វែង ។ ក្រោយការធ្វើសមាហរណកម្មចុះចូលជាមួយរាជរដ្ឋាភិបាល វ៉ា និងគ្រួសារ ដែលមានកូនប្រុសស្រី៧នាក់ បានចាប់ផ្តើមជីវិតថ្មី ដោយប្រកបរបរធ្វើស្រែ ចម្ការ និងចិញ្ចឹមសត្វ ។

អ្វីដែលបានរៀបរាប់ខាងលើ គឺជាបទពិសោធរបស់ វ៉ា ដែលខិតខំតស៊ូរក្សាជីវិតក្នុងរបបមួយដែលម្នាក់ៗ គ្មានសង្ឃឹមនឹងអាចរស់ ។ ផ្ទុយពីនាងខ្ញុំ ដែលមានសំណាងកើតក្នុងពេលវេលាមួយដែលប្រទេសមានសុខសន្តិភាព រស់នៅដោយគ្មានក្តីបារម្ភ ដូចក្នុងរបបខ្មែរក្រហម ។ សម្រាប់ខ្ញុំផ្ទាល់ អន្លង់វែង ជាតំបន់មួយដែលមានទាំងប្រវត្តិសាស្ត្រ និងធនធានធម្មជាតិ ។ ប្រវត្តិសាស្ត្រអន្លង់វែង អាចចាត់ទុកជាទីកន្លែងសម្រាប់ស្រាវជ្រាវ និងសិក្សាអំពីចលនាតស៊ូរបស់ខ្មែរក្រហម ដែលបន្សល់ទុកភស្តុតាង និងទីតាំងប្រវត្តិសាស្ត្រជាច្រើន ។ តំបន់ប្រវត្តិសាស្ត្រដែលគួរឲ្យចាប់អារម្មណ៍មាន ៖ ផ្ទះតាម៉ុក មន្ទីរពេទ្យ ផ្នូរ ប៉ុល ពត ជាដើម ។ ចំណែក ធម្មជាតិ មានភ្នំដងរែកដែលជាបន្ទាត់ព្រំដែនរវាងប្រទេសកម្ពុជា និង ថៃ អមជាមួយនឹងទេសភាពដ៏ស្រស់ត្រកាល ដែលយើងសម្លឹងមើលពីពើយ តាម៉ុក ដែលជាអតីតទីបញ្ជាការរបស់ តាម៉ុក (មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងបច្ចុប្បន្ន) អាចឃើញស្រុកអន្លង់វែងទាំងមូល ។

ប៉ុន្តែ គួរឲ្យសោកស្តាយតំបន់អន្លង់វែង ពុំសូវទទួលបានការចាប់អារម្មណ៍ប៉ុន្មានទេ ដោយសារតែតំបន់នេះ ជាតំបន់ដាច់ស្រយាល និងជាអតីតតំបន់របស់ខ្មែរក្រហមគ្រប់គ្រង ទើបជះឥទ្ធិពលមិនល្អដល់ផ្នត់គំនិតរបស់មនុស្សភាគច្រើនដែលយល់ថា អន្លង់វែង ជាតំបន់អសន្តិសុខ ។ ខ្ញុំយល់ថា អតីតកាលបានកន្លងហួស ប៉ុន្តែយើងក៏មិនត្រូវបំភ្លេចវាដែរ ហើយពេលនេះ យើងគួរតែរួបរួមគ្នាធ្វើឲ្យតំបន់អន្លង់វែង មានភាពកាន់តែប្រសើរឡើងទាំងប្រវត្តិសាស្ត្រ និងធម្មជាតិ និងដើម្បីភាពរឹងមាំនៃតំបន់ព្រំដែន ។ ការស្រឡាញ់ប្រវត្តិសាស្ត្រ គឺស្រឡាញ់ជាតិ ហើយស្រឡាញ់ធម្មជាតិគឺ ស្រឡាញ់ព្រៃឈើ ។

**សយ ណារ្ធី**

# ខ្ញុំរៀបនឹងស្លាប់ដោយសារជំងឺ

ជាមួយវ័យជរា រស់នៅតែម្នាក់ឯង នៅភូមិលំទងចាស់ ឃុំលំទងចាស់ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ យាយ រីប ហឿន មានវ័យ៧៣ឆ្នាំហើយ ។ ប្តីរបស់យាយ ហឿន បានស្លាប់តាំងពីបីឆ្នាំមុនម៉្លេះ ហើយកូនៗប្រុសស្រីទាំង៧នាក់របស់គាត់បានរៀបការ និងរស់នៅបែកពីគាត់អស់ហើយ ។ យាយបានរៀបរាប់ពីដំណើរជីវិតដែលបានឆ្លងកាត់នៅក្នុងរបបខ្មែរក្រហមថា៖

ក្រោយឆ្នាំ១៩៧០ បន្ទាប់ពីរដ្ឋប្រហារទម្លាក់សម្តេច សីហនុ ការទម្លាក់គ្រាប់បែកបានកើតមានឡើងស្ទើរគ្រប់ទីកន្លែង ។ សំឡេងយន្តហោះបានធ្វើឲ្យប្រជាជនគ្រប់គ្នាមានការភ័យខ្លាច អ្នកខ្លះបានរត់បោលផ្ទះសម្បែង ដោយសារតែភិតភ័យនឹងសំឡេងលាន់កងរំពងរបស់ម៉ាស៊ីនយន្តហោះ ។ ពេលនោះ គាត់និងប្តីឈ្មោះ ហ៊ិន បានសម្រេចចិត្តចេញពីផ្ទះគាត់ទៅរស់នៅក្នុងទឹកដីថៃ ដែលស្ថិតនៅជាប់នឹងព្រំដែនខ្មែរវិញ ។ ប៉ុន្តែរយៈពេលមួយខែក្រោយមក ថៃបានបញ្ជូនគាត់ និងប្តីមកស្រុកកំណើតវិញ បន្ទាប់ពីការទម្លាក់គ្រាប់បែកបានស្ងប់ស្ងាត់ យាយ ហឿន និងប្តីបានប្រកបរបរធ្វើស្រែចម្ការធម្មតាវិញ ។ ប៉ុន្តែរឿងដែលគួរឲ្យសោកស្តាយនោះគឺឪពុកម្តាយរបស់គាត់បានស្លាប់ក្នុងអំឡុងពេលដែលមានការទម្លាក់គ្រាប់បែកនោះ ។

នៅឆ្នាំ១៩៧៣ ប្តីរបស់យាយ ហឿន និងបងប្រុសរបស់គាត់ ឈ្មោះ រី តាប់ បានស្ម័គ្រចិត្តធ្វើជាទាហានលន់ នល់ ។ ប្តីរបស់គាត់ចូលធ្វើទាហានមិនបានប៉ុន្មាន ក៏មានជំងឺគ្រុនចាញ់ ហើយត្រូវអគ្គភាពបញ្ជូនមកផ្ទះវិញ ។ ក្រោយមក គាត់និងប្តីបានផ្លាស់ទៅរស់នៅខេត្តសៀមរាប ។

នៅឆ្នាំ១៩៧៥ ខ្មែរក្រហមបានជ័យជម្នះ និងគ្រប់គ្រង



រិន រចនា បុគ្គលិកស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង សម្ភាស រីប ហឿន នៅភូមិលំទងចាស់ ឃុំលំទង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ

ប្រទេស តន្ត្រី សិល្បៈ សាសនា ទំនៀមទម្លាប់ប្រពៃណី ត្រូវបានខ្មែរក្រហមហាមឃាត់ ហើយក៏ជាពេលដែលកូនត្រូវបែកពីឪពុកម្តាយ ប្រពន្ធបែកពីប្តី គឺស្ទើរតែគ្រប់គ្រួសារបានបែកបាក់គ្នា ។ ប្រជាជនដែលរស់នៅតាមទីក្រុង ទីប្រជុំជននានា ត្រូវខ្មែរក្រហមជម្លៀសចេញឲ្យទៅតាមទីជនបទ ដោយយកលេសថា អាមេរិកាំងនឹងមកទម្លាក់គ្រាប់បែក ។ ប្រជាជនត្រូវបង្ខំឲ្យចាកចេញពីផ្ទះសម្បែង ដោយមិនបានយកអ្វីទៅជាប់នឹងខ្លួនច្រើននោះទេ ព្រោះគិតថា នឹងបានត្រឡប់មកផ្ទះវិញ ក្នុងរយៈពេលបីថ្ងៃក្រោយ ។

ជាក់ស្តែង យាយ ហឿន និងគ្រួសារត្រូវខ្មែរក្រហមជម្លៀសឲ្យទៅរស់នៅស្រុកក្រឡាញ់ ដោយធ្វើដំណើរតាមរថយន្ត និងថ្មើរជើង ។ យាយ ហឿន បានឲ្យដឹងថា គាត់ត្រូវធ្វើដំណើរទាំងថ្ងៃទាំងយប់ ដោយមានតែអាហារបន្តិចបន្តួចហូបប៉ុណ្ណោះ ។ ទៅដល់ស្រុកក្រឡាញ់ អង្គការបានបែងចែកប្រជាជនទៅតាមក្រុមរៀងៗខ្លួន ដោយឡែកយាយ ហឿន ត្រូវអង្គការចាត់ឲ្យចូលកងនារីធ្វើស្រែ ។ ប៉ុន្មានខែក្រោយមក ប្តីរបស់យាយ ហឿន ត្រូវបានអង្គការនាំទៅសួរចម្លើយទាក់ទងនឹងទាហាន លន់ នល់ ។ យាយ ហឿន បានឲ្យដឹងថា ប្តីរបស់គាត់ពេលនៅស្រុកក្រឡាញ់មិនបានប្រើឈ្មោះដើមទេ គឺប្តីរបស់គាត់បានប្តូរឈ្មោះថ្មី (មកដល់សព្វថ្ងៃគាត់មិនចាំឈ្មោះថ្មីរបស់ប្តីគាត់ទេ) ។ ប្តីរបស់គាត់ តាហ៊ីន ត្រូវបានអង្គការបញ្ជូនទៅសួរចម្លើយនៅខេត្តបន្ទាយមានជ័យ (តំបន់៥) និងក្រោយមកបានដោះលែងមកវិញ ដោយរកមិនឃើញឈ្មោះប្តីរបស់គាត់ពាក់ព័ន្ធជាមួយអតីតទាហាន លន់ នល់ ។ ប៉ុន្តែបងប្រុសរបស់យាយ ហឿន ឈ្មោះ វី តាប់ មិនមានវាសនារួចជីវិតដូចប្តីគាត់ទេ ។ បងប្រុសរបស់ គាត់ត្រូវអង្គការចាប់បញ្ជូនមកភ្នំពេញ ទាក់ទងនឹងអតីតភាពជាទាហាន លន់ នល់ ។ មួយខែក្រោយមក ទើបគាត់ដឹងថា បងប្រុសរបស់គាត់ត្រូវបានអង្គការយកទៅសម្លាប់ ។

នៅឆ្នាំ១៩៧៧ តាហ៊ីន ត្រូវបានអង្គការបញ្ជូនឲ្យទៅធ្វើការនៅកងចល័ត ខេត្តកំពង់ធំ ដែលត្រូវទៅលើកទំនប់១មករា ។ ចាប់តាំងពីពេលនោះមក យាយ ហឿន ត្រូវរស់នៅឆ្ងាយពីប្តី រហូតដល់របបខ្មែរក្រហមដួលរលំ ។ អំឡុងពេលរស់នៅតែម្នាក់ឯង យាយ ហឿន កើត មានជំងឺផ្លូវចិត្តដែលគាត់ត្រូវរស់នៅឆ្ងាយពីប្តីម្យ៉ាងទៀត គាត់ត្រូវធ្វើការទាំងយប់ទាំងថ្ងៃ និងហូបមិនគ្រប់គ្រាន់រហូតដល់គាត់ធ្លាក់ខ្លួនឈឺជាទម្ងន់ ។ ពេលនោះ ម្រាមដៃរបស់គាត់ក៏កើតពិស ជាហេតុធ្វើឲ្យគាត់មិនអាចទៅធ្វើការបាន ។ អង្គការបានហៅយាយ ហឿន ទៅសាកសួរ និងបានពិនិត្យឃើញថាគាត់ពិតជាឈឺ ទើបអនុញ្ញាតឲ្យឈប់សម្រាក ។ អំឡុងពេលគាត់សម្រាកព្យាបាលជំងឺ មេកងនារីរបស់គាត់តែងតែយករបបអាហារមកឲ្យគាត់ហូប ។ ប៉ុន្មានថ្ងៃក្រោយមក អង្គការបានហៅមេកងនារីនោះទៅរៀនសូត្របាត់ដោយមិនដឹងពីមូលហេតុ ហើយចាប់តាំងពីថ្ងៃនោះមកគាត់មិនដែលឃើញមេកងនារីនោះត្រឡប់មកវិញទេ ។ គាត់បានត្រឹមតែឮពាក្យចចាមអារ៉ាមថា អង្គការបានចោទថា មេកងនារីនោះ ក្បត់នឹងអង្គការ ។ ដោយឈឺនឹងជំងឺពិសដែលកើតនៅម្រាមដៃគាត់ខ្លាំងពេក យាយ ហឿន បានសម្រេចចិត្តកាត់ម្រាមដែលកើតពិសនោះចោលតែម្តង ។

ក្រោយរបបខ្មែរក្រហមបានដួលរលំ នៅឆ្នាំ១៩៧៩ ប្តីរបស់យាយបានត្រឡប់មករកយាយវិញ និងនាំគ្នាទៅរស់នៅក្នុងទឹកដីថៃអស់រយៈពេល២ឆ្នាំ ។ អំឡុងពេលនោះ យាយ និងប្តីប្រកបរបរបោចវល្លិ៍ បាញ់សត្វ និងកាប់ឈើលក់ ។ បន្ទាប់ពីស្ថានការណ៍វាយប្រយុទ្ធគ្នាស្ងប់ស្ងាត់បន្តិច យាយ ហឿន និងប្តីបានត្រឡប់មកនៅស្រុកអន្លង់វែង ដែលជាតំបន់កាន់កាប់របស់កម្លាំងខ្មែរក្រហមដែលនៅសេសសល់ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់តាម៉ុក ។

យាយ ហឿន បានឲ្យដឹងថា តាម៉ុក គ្រប់គ្រងតំបន់អន្លង់វែង ចំណែកប្រជាជនរស់នៅប្រកបរបរធ្វើស្រែចម្ការធម្មតា ប៉ុន្តែមិនតឹងរ៉ឹងដូចមុនទេ ។ បន្ទាប់មក ប្តីរបស់គាត់ តាហ៊ីន ក៏បានចូលបម្រើបម្រើកងទ័ព តាម៉ុក ។

យាយ ហឿន បានឲ្យដឹងថា តាម៉ុក គ្រប់គ្រងតំបន់អន្លង់វែង និងមិនមានជម្លៀសប្រជាជនទៅណាទេ ។ នៅពេលនោះ ការប្រយុទ្ធគ្នាជាមួយកងទ័ពវៀតណាមមិនទាន់បញ្ចប់ទេ និងបានបង្កឲ្យមានមនុស្សស្លាប់ជាបន្តបន្ទាប់ ។ មិនយូរប៉ុន្មាន ប្តីរបស់គាត់បានធ្លាក់ខ្លួនឈឺ ហើយក៏លាឈប់ពីកងទ័ព និងត្រឡប់មករស់នៅជាមួយគាត់នៅភូមិវិញ ។

**រិន រចនា**

# ដំណើរជីវិតរបស់ ពាក់ ធឿន

ពាក់ ធឿន កើតក្នុងឆ្នាំ១៩៥៣ (ជាឆ្នាំដែលប្រទេសកម្ពុជាទទួលបានឯករាជ្យពីប្រទេសបារាំង) និងមានស្រុកកំណើតនៅភូមិបន្ទាយឆ្មាខាងជើង ឃុំបន្ទាយឆ្មារ ស្រុកថ្មពួក ខេត្តបាត់ដំបង (បច្ចុប្បន្នខេត្តបន្ទាយមានជ័យ) ។ ធឿន មានជីតាឈ្មោះ វ៉ាន់ ដែលជាអតីតមេឃុំបន្ទាយឆ្មា ចំណែកឪពុករបស់គាត់ឈ្មោះ វ៉ាន់ ពាក់ ដែលជាអតីតជំទប់ទី១ ឃុំបន្ទាយឆ្មារក្នុងសម័យសង្គមរាស្ត្រនិយម និងមានម្ដាយឈ្មោះ ណៅ ហ៊ុន ។ ធឿន មានបងប្អូន១១នាក់ (ស្រី៥នាក់ ប្រុស៦នាក់) ។ ធឿន គឺជាកូនច្បងក្នុងគ្រួសារ ។ ធឿន រៀនបានត្រឹមថ្នាក់ទី៧ (សង្គមចាស់) នៅសាលាបន្ទាយឆ្មារ ក៏បានឈប់ បន្ទាប់ពីមានព្រឹត្តិការណ៍រដ្ឋប្រហារទម្លាក់សម្ដេចសីហនុឆ្នាំ១៩៧០ ។ ក្រោយឈប់ពីការសិក្សា ធឿន នៅផ្ទះជួយកិច្ចការធ្វើស្រែចម្ការឪពុកម្ដាយរហូតដល់ឆ្នាំ១៩៧៥ ។

បន្ទាប់ពីខ្មែរក្រហមឡើងកាន់កាប់អំណាច នៅឆ្នាំ១៩៧៥ ទ្រព្យសម្បត្តិរបស់របរ (ចានឆ្នាំង ស្វាព្រា គោក្របី និងមាសប្រាក់ជាដើម) គ្រួសាររបស់ធឿន ក៏ដូចជាទ្រព្យសម្បត្តិ និងរបស់របររបស់ប្រជាជននៅក្នុងឃុំបន្ទាយឆ្មារ ត្រូវបានខ្មែរក្រហមប្រមូលដាក់ឲ្យប្រើប្រាស់ជារបស់រួម ។ នៅក្នុងឃុំបន្ទាយឆ្មារ ខ្មែរក្រហមបានចាត់តាំង ញៀប ឲ្យដឹកនាំ ហើយប្រជាជនត្រូវបានបែងចែកជាបីក្រុម មានក្រុមកុមារ ក្រុមយុវជន និងក្រុមវ័យកណ្ដាល ។ ក្នុងក្រុមនីមួយៗត្រូវបានបែងចែកជាក្រុមតូចៗ (ប្រហែល ១០នាក់) និងមានប្រធានក្រុមម្នាក់ ។ ធឿន ត្រូវបានចាត់តាំងឲ្យនៅក្នុងក្រុមវ័យកណ្ដាល ។ ធឿន ត្រូវបានខ្មែរក្រហមចាប់ផ្សំផ្គុំឲ្យរៀបការជាមួយ ប៉ែ សួន ដែលសរុបមាន៦០គូ នៅចុងឆ្នាំ១៩៧៥ ។ បន្ទាប់ពីរៀបការរួច ធឿន ត្រូវបានខ្មែរក្រហមដកចេញពីក្រុមវ័យកណ្ដាលឲ្យទៅនៅកងចល័តឃុំ ធ្វើការការងារភ្ជួរស្រែ ដកស្ទូង និងលើកទំនប់ជាដើម ។ នៅរដូវវស្សាឆ្នាំ១៩៧៦ ធឿន ត្រូវបានបញ្ជូនឲ្យទៅលើកទំនប់អាងជើងគ្រោះ ហើយឆ្នាំ១៩៧៧ គាត់ត្រូវបានខ្មែរក្រហមបញ្ជូនទៅម្ដងទៀត ដែលពេលនោះមានមនុស្សប្រហែល ៥.០០០នាក់ បានចូលរួម ដោយលើកទំនប់ប្រវែងប្រហែល១.០០០ ម៉ែត្រ (នៅក្នុងសម័យខ្មែរក្រហម ទំនប់អាងជើងគ្រោះត្រូវបានលើកពីរដង ដោយលើកទីមួយមានប្រវែងខ្លី និងទំហំតូច មិនអាចស្តុកទឹកបានច្រើនដូច្នេះទំនប់នេះត្រូវបានលើកម្ដងទៀតនៅឆ្នាំ១៩៧៧ ហើយទំនប់ជើងគ្រោះអាចស្ដុកទឹកធ្វើស្រែខួបប្រាំងខួបវស្សា មិនខ្វះទឹកនោះទេ) ។ បន្ទាប់ពីលើកទំនប់អាងជើងគ្រោះជាលើកទី២រួច ធឿន ត្រូវបានខ្មែរក្រហមចាត់តាំងឲ្យធ្វើជាប្រធានដែលមានសមាជិក១០នាក់ ដើម្បីមើលការខុសត្រូវទំនប់អាងជើងគ្រោះនោះកុំឲ្យមានការខូចខាត ធ្លុះធ្លាយ និងបាក់ជាដើម ហើយក្រៅពីការងារនោះ ធឿន និងកូនក្រុមត្រូវចល័តធ្វើការងារផ្សេងទៀត មានដូចជា ភ្ជួររាស់ ដក់ស្ទូងជាដើម ។

ធឿន ក៏ត្រូវបានខ្មែរក្រហមបញ្ជូនឲ្យទៅលើកទំនប់ត្រពាំងថ្មម្ដងម្ដាលដែរ ។ នៅចុងឆ្នាំ១៩៧៧ ឪពុករបស់ ធឿន ត្រូវបានខ្មែរក្រហមចាប់ខ្លួនបន្ទាប់ពីស្រាវជ្រាវឃើញថា ឪពុកគាត់ ធ្លាប់ធ្វើការបម្រើឲ្យរបបសាធារណរដ្ឋខ្មែរ របស់ លន់ នល់ ។ នៅពេលឪពុក ធឿន ត្រូវបានចាប់ខ្លួន ធឿន ក៏នៅទីនោះដែរ ប៉ុន្តែ ធឿន មិនអាចជួយឪពុកបានទេ ពីព្រោះ ធឿន ធ្លាប់ឃើញ តាលាភ ត្រូវបានខ្មែរក្រហមចាប់ខ្លួន ហើយពេលនោះកូនក៏មកជួយ ដូច្នេះខ្មែរក្រហមចាប់ទាំងពីរនាក់ឪពុកកូនយកទៅសម្លាប់ចោលតែម្ដង ។ ដោយនឹកឃើញដល់រឿងនោះ ទើប ធឿន មិនហ៊ានជួយឪពុក ដោយខ្លាចខ្មែរក្រហមចាប់ខ្លួនសម្លាប់ទាំងពីរនាក់ ដូច តាលាភ និងកូន ។ ធឿន បានឲ្យដឹងថា ឪពុករបស់ខ្លួនត្រូវបានខ្មែរក្រហមយកទៅសម្លាប់នៅបន្ទាយទាហានថ្មពួកចាស់ ។ ធឿន បានបញ្ជាក់ថា ខ្មែរក្រហមបានយកមនុស្សជាច្រើនទៅសម្លាប់នៅបន្ទាយទាហានថ្មពួកចាស់ ដោយក្នុងមួយរណ្ដៅមានមនុស្សយ៉ាងតិច៥០ ទៅ ៦០នាក់កប់រួមគ្នា ។ នៅចុងឆ្នាំ១៩៧៨ ធឿន ត្រូវគណៈឃុំចាប់ខ្លួនបញ្ជូនទៅសហករណ៍សាលាបន្ទាយឆ្មា ដោយសារការសារភាពរបស់ សេន ថា ធឿន រួមគំនិតលួចដឹកដំឡូង (សេន ត្រូវខ្មែរក្រហម

ចាប់ខ្លួននៅពេលលួចដឹកដំឡូង ហើយ សេន ត្រូវបានខ្មែរក្រហមធ្វើទារុណកម្មសួរចម្លើយ) ។ តែជាសំណាងល្អ នៅដើមឆ្នាំ១៩៧៨ ធឿន ត្រូវបានដោះលែងវិញ បន្ទាប់ពីមានការធានាពី ហាក់ ដែលធ្វើការខាងសេដ្ឋកិច្ចឃុំ ថា ធឿន ជាមនុស្សល្អ ស្អាតស្អំ ។ ក្រោយដោះលែង ធឿន ត្រូវបានចាត់តាំងឲ្យធ្វើស្រែ និងមើលការខុសត្រូវទំនប់អាងដើងគ្រោះជាធម្មតា ។ នៅពាក់កណ្ដាលឆ្នាំ១៩៧៨ ធឿន,ឃួន និង អាល់ បានផ្ដើមគំនិតរៀបចំគម្រោងការសម្លាប់ខ្មែរក្រហម តែគម្រោងនោះត្រូវបរាជ័យដោយសារកម្មាភិបាលខ្មែរបានដឹងមុន ដូច្នេះខ្មែរក្រហមបានដេញចាប់ក្រុមរបស់គាត់ ។ នៅចុងឆ្នាំ ១៩៧៨ ធឿន បានរត់ភៀសខ្លួនចូលប្រទេសថៃ ហើយក្រោយមកក៏បានបម្រើការងារជាទាហានប៉ារ៉ា នៅទីនោះ ដើម្បីប្រឆាំងរបបខ្មែរក្រហម ។ ចូលបម្រើទាហានប៉ារ៉ា បានរយៈពេល៤ខែ ធឿន ក៏លាឈប់ ហើយត្រឡប់មកប្រទេសកម្ពុជាវិញ ។

នៅឆ្នាំ១៩៧៩ បន្ទាប់ពីរបបខ្មែរក្រហមត្រូវបានដួលរលំ ធឿន ក៏បានចូលមកប្រទេសកម្ពុជាវិញ ។ នៅពេលមកដល់កម្ពុជាវិញ ធឿន ត្រូវបានកងទ័ពវៀតណាមចាប់ខ្លួន និងឲ្យសារភាព ពីព្រោះរាល់ប្រជាជនដែលចូលទឹកដីថៃ ហើយត្រឡប់មកវិញ គឺកងទ័ពវៀតណាមបានចាប់ខ្លួន និងតម្រូវឲ្យសារភាព ។ ក្រោយសារភាពរួច ធឿន បានទៅជួបជុំក្រុមគ្រួសារ ហើយក្រោយមកមេឃុំថ្មីឈ្មោះ ដឿម បានហៅ ធឿន ឲ្យធ្វើគ្រូបង្រៀននៅសាលាបន្ទាយឆ្មារ ប៉ុន្តែ ធឿន បានបដិសេធ ដោយគិតថាឪពុកស្លាប់ដោយសារធ្វើការងាររដ្ឋដូច្នេះ គាត់មិនចង់ធ្វើការងារនេះទេ ។

នៅឆ្នាំ ១៩៨២ ផ្ទះរបស់ប្រជាជននៅក្នុងឃុំបន្ទាយឆ្មារត្រូវបានឆេះខ្ទេចខ្ទីដោយការប្រយុទ្ធគ្នារវាងកងទ័ពខ្មែរក្រហម និងកងទ័ពវៀតណាម ។ ប្រជាជននៅក្នុងឃុំ ត្រូវបានជម្លៀសឲ្យទៅរស់នៅក្នុងឃុំសាម៉ែន និងមួយចំនួនរត់ចូលព្រៃ ។ ការរស់នៅក្នុងឃុំសាម៉ែន គឺវេទនាបំផុតសម្រាប់ ធឿន ពីព្រោះមិនមានដីធ្វើស្រែចម្ការ ប្រជាជនមួយចំនួនក៏រត់ភៀសខ្លួនទៅព្រំដែន ។ ឆ្នាំ១៩៨៨ ធឿន បានរត់ទៅរស់នៅជំរំសាយធូ ។ នៅជំរំសាយធូ ធឿន បានចូលរៀនអក្សរ និងរៀនខាងបច្ចេកទេស ជំនាញខាងគ្រឿងម៉ាស៊ីន ឡាន ម៉ូតូ និងគោយន្ត ហើយបានក្លាយជាគ្រូបង្រៀនខាងបច្ចេកទេសដល់ជនពិការនៅទីនោះ ។ ឆ្នាំ១៩៩១ ធឿន បានចាកចេញពីជំរំសាយធូ មករស់នៅស្រុកកំណើតវិញ បន្ទាប់សង្គ្រាមត្រូវបានផុតរលុតក្នុងតំបន់នោះ ។ មកដល់ភូមិវិញ ធឿន បានរស់នៅលើដីចាស់របស់ខ្លួន ជាមួយនឹងគ្រួសារ និងធ្វើការងារជាអ្នកស្រែចម្ការ ។ នៅឆ្នាំ២០០៣ ធឿន ត្រូវបានចាស់ទុំនៅក្នុងភូមិជ្រើសរើសឲ្យធ្វើជាមេភូមិបន្ទាយឆ្មារខាងជើង ពីព្រោះអ្នកភូមិគិតថា ជីតា និងឪពុករបស់ ធឿន គឺជាអ្នកបម្រើការងារដឹកនាំភូមិឃុំបានល្អ ហើយ ធឿន ក៏បានធ្វើមេភូមិរហូតមក ។ មកដល់សព្វថ្ងៃ ធឿនមានកូនបីនាក់ (ស្រី២ ប្រុស១) និងរស់នៅក្នុងជីវភាពសមរម្យជាមួយគ្រួសារ ។ រាល់ពេលបុណ្យទានម្ដង ធឿន និងគ្រួសារតែងធ្វើបុណ្យដើម្បីឧទ្ទិសកុសលដល់បុព្វការីជន ជាពិសេសឪពុកដែលបានស្លាប់ក្នុងរបបខ្មែរក្រហម ។

**យ៉ាង សេងហៀង**

# រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាន និងកំពុងសរសេរអត្ថបទ ឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន នឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម៖

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥

ទូរស័ព្ទលេខៈ (៨៥៥) (១២) ៩៩៦ ៧៥០

ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨

Email: truthbunthorn.s@dccam.org

Home page: www.d.dccam.org

# អំពើប្រល័យពូជសាសន៍៖ ការធ្វើទុកបុកម្នេញ លើជនជាតិវៀតណាម និងចាម

*សហព្រះរាជអាជ្ញាអន្តរជាតិ លោក នីកូឡាស គាំចាន់ បានធ្វើសេចក្តីថ្លែងអំពីឧក្រិដ្ឋកម្មប្រឆាំងនឹងជនជាតិវៀតណាម និងជនជាតិចាម ព្រមទាំងសមាសភាពនៃការប្រល័យពូជសាសន៍ ។*

*លោក គាំចាន់ បានចាប់ផ្តើមដោយសង្កត់ធ្ងន់ថា ការប្រល័យពូជសាសន៍គឺជាឧក្រិដ្ឋកម្មប្រឆាំងនឹងក្រុមមនុស្សណាមួយ ។ បើប្រៀបធៀបទៅនឹងឧក្រិដ្ឋកម្មនៃការសម្លាប់រង្គាលដែលតម្រូវឲ្យការសម្លាប់មានទ្រង់ទ្រាយធំនោះ គឺការប្រល័យពូជសាសន៍មិនអាស្រ័យលើចំនួនមនុស្សដែលត្រូវបានសម្លាប់ទេ ។ អាស្រ័យហេតុនេះ តាមគោលការណ៍ ការសម្លាប់មនុស្សតែម្នាក់ក៏អាចចាត់ទុកជាការប្រល័យពូជសាសន៍បានដែរ ប្រសិនបើការសម្លាប់នេះត្រូវបានធ្វើឡើងក្នុងចេតនាបំផ្លាញក្រុមមនុស្សណាមួយ ។ ក្រុមនេះត្រូវស្ថិតក្នុងចំណោមនៃក្រុមជាតិសាសន៍ ក្រុមជាតិពន្ធ ឬក្រុមសាសនា ណាមួយ ។*

*ក្នុងសំណុំរឿង០០២/០២ ការប្រល័យពូជសាសន៍ត្រូវបានចោទប្រកាន់ចំពោះការប្រព្រឹត្តលើជនជាតិវៀតណាម និងជនជាតិចាម ។*

*លោក គាំចាន់ បានពិនិត្យផ្នែកមួយនៃប្រវត្តិការប្រល័យពូជសាសន៍ ដោយកត់សម្គាល់ថាវាត្រូវបានចាត់បញ្ចូលជាឧក្រិដ្ឋកម្មនៅឆ្នាំ១៩៤៦ នៅពេលដែលមហាសន្និបាតរបស់អង្គការសហប្រជាជាតិបានថ្លែងថា ការប្រល័យពូជសាសន៍គឺជាការបដិសេធសិទ្ធិរស់រានមានជីវិតរបស់ក្រុមមនុស្សណាមួយទាំងស្រុង ដែលជាអំពើមួយដែលធ្វើឲ្យមនុស្សទាំងពួងតក់ស្លុតស្មារតី បង្កភាព*



*សហគមន៍ចាម នៅទសវត្សរ៍ឆ្នាំ១៩៨០*

វិនាសធ្ងន់ធ្ងរដល់មនុស្សជាតិ ព្រមទាំងផ្ទុយដាច់ស្រឡះពីច្បាប់នៃក្រមសីលធម៌ ។

គាត់ក៏បានពិនិត្យនិយមន័យនៃការប្រល័យពូជសាសន៍ជាពិសេស ។ តាមរយៈនិយមន័យ ខុក្រិដ្ឋកម្មនៃការប្រល័យពូជសាសន៍តម្រូវឲ្យមានការប្រព្រឹត្តអំពើណាមួយក្នុងចំណោមអំពើប្រាំប្រភេទខុសៗគ្នា ដោយចេតនាបំផ្លិចបំផ្លាញ ទោះបីទាំងមូលក្តី ឬផ្នែកខ្លះក្តី នូវក្រុមជាតិសាសន៍ ក្រុមជាតិពន្ធ ក្រុមពូជសាសន៍ ឬក្រុមសាសនាជាអាទិ៍ ។ អំពើទាំងប្រាំប្រភេទនេះគឺ៖

◆ ការសម្លាប់សមាជិកទាំងឡាយនៃក្រុមនោះ

◆ ការបង្កឲ្យមានការរងគ្រោះថ្នាក់ធ្ងន់ធ្ងរដល់រូបរាងកាយ ឬដល់បញ្ញាស្មារតីរបស់សមាជិកទាំងឡាយនៃក្រុមមួយ

◆ ការធ្វើទុកបុកម្នេញដល់លក្ខខណ្ឌជីវិតរបស់ក្រុមនោះក្នុងកម្រិតមួយដែលប្រុងនឹងនាំដល់ការបំផ្លិចបំផ្លាញជាក់ស្តែងនូវក្រុមនោះ

◆ ការដាក់ចេញវិធានការបែបបង្ខំដើម្បីទប់ស្កាត់ការបង្កកំណើត

◆ ការផ្លាស់ទីកុមារពីក្រុមមួយទៅកាន់ក្រុមមួយទៀតដោយបង្ខិតបង្ខំ ។

លោក គាំចាន់ បានកត់សម្គាល់ថា ការសម្លាប់សមាជិកនៃក្រុមមួយគឺជាអ្វីដែលត្រូវចោទប្រកាន់ក្នុងសំណុំរឿងនេះ ពោលគឺសំដៅទៅការបំផ្លិចបំផ្លាញជនជាតិវៀតណាម និងជនជាតិចាមនៅក្នុងប្រទេសកម្ពុជាដែលត្រូវបានបង្កឡើងយ៉ាងហោចណាស់មួយអន្លើដោយការសម្លាប់សមាជិកនៃក្រុមនេះ ។

មុននឹងលោកធ្វើការពិភាក្សាអំពីការប្រល័យពូជសាសន៍ លោក គាំចាន់ បានលើកឡើងពីជំហររបស់ក្រុមការពារក្តីពីចេតនា និងដំណើរពាក់ព័ន្ធរបស់វាជាមួយនឹងសហខុក្រិដ្ឋកម្មរួម ។ នៅក្នុងការសន្និបចុងក្រោយរបស់ នួន ជា គាត់បានធ្វើសេចក្តីថ្លែងការណ៍ថា ជនល្មើសដែលបានប្រព្រឹត្តសកម្មភាពបំផ្លាញរូបរាងកាយ ដាច់ខាតពិតជាមានចេតនារួមណាមួយនៃខុក្រិដ្ឋកម្មដូចនឹងសមាជិកនៃសហខុក្រិដ្ឋកម្មរួម ។ លោកសហព្រះរាជអាជ្ញា បានជំទាស់ថា សេចក្តីបកស្រាយមួយនេះស្តីពីច្បាប់ គឺមិនត្រឹមត្រូវឡើយ ។ លោកបានកត់សម្គាល់ថាមេធាវីការពារក្តីបានលើកឡើងពីសាលដីការបស់សំណុំរឿងតុលាការអន្តរជាតិកាត់ទោសខុក្រិដ្ឋជនអតីតយូហ្គូស្លាវី ហើយវាមានភាពត្រឹមត្រូវដែលអង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ពីតម្រូវការសម្រាប់ចេតនារួម ។ ទោះជាយ៉ាងណាក៏ដោយ លោក គាំចាន់ បានចង្អុលបង្ហាញថាតម្រូវការនេះត្រូវបានលុបចោលក្នុងបណ្តឹងឧទ្ធរណ៍លើករណីដដែលនោះ ។ លើសពីនេះទៀត អង្គជំនុំជម្រះសាលាដំបូង និងសាលាក្តីទាំងអស់ដែលពាក់ព័ន្ធនឹងបញ្ហានេះទទួលស្គាល់ថា សហខុក្រិដ្ឋរួមអាចប្រើប្រាស់ជនល្មើសឲ្យប្រព្រឹត្តបទល្មើសនេះ ។

គាត់បានផ្តល់ឧទាហរណ៍មួយដើម្បីពន្យល់រឿងនេះ៖ ចេតនារបស់ឆ្មាំនៅជើងឯកគឺមិនមានការពាក់ព័ន្ធទេ ពីព្រោះពួកគេគ្រាន់តែធ្វើតាមបញ្ជាប៉ុណ្ណោះ ។ វាមិនសំខាន់ទេថា តើឆ្មាំនៅជើងឯកមានចេតនាប្រល័យពូជសាសន៍ឬអត់ ដរាបណាពួកគេត្រូវបានប្រើប្រាស់ដោយសហខុក្រិដ្ឋកម្មរួមដើម្បីអនុវត្តទង្វើនោះ ។ ដូច្នេះសំណួរដែលពាក់ព័ន្ធនឹងបញ្ហាគឺថា តើខុក្រិដ្ឋកម្មគឺជាផ្នែកមួយនៃចេតនារួមរបស់សហខុក្រិដ្ឋកម្មរួមឬទេ ហើយអ្វីដែលសំខាន់ជាងគេគឺចេតនាប្រល័យពូជសាសន៍របស់សមាជិកសហខុក្រិដ្ឋកម្មរួម ។ លោក គាំចាន់ បានដកស្រង់ពីសៀវភៅមួយដែលមានឈ្មោះថា ទ្រឹស្តីរួមស្តីពីចេតនាប្រល័យពូជសាសន៍ ដែលក្នុងនោះបាននិយាយពីទស្សនៈនៃការប្រល័យពូជសាសន៍ក្នុងរបៀបផ្សេងថា «តួអង្គថ្នាក់ទាប ឲ្យអ្នកបាញ់សម្លាប់ អ្នកប្រហារជីវិតនៅជើងឯក ដោយប្រើចប និងកាំបិត មិនកាន់តួនាទីដែលអនុញ្ញាតឲ្យពួកគេអាចបំផ្លាញអ្នកក្នុងក្រុម ហើយដូច្នេះពួកគេមិនអាចមានចេតនាប្រល័យពូជសាសន៍បានទេ ។ ការដែលជនល្មើសថ្នាក់ទាបនៃសហក្រិដ្ឋកម្មរួមប្រល័យពូជសាសន៍ដែលបានប្រព្រឹត្តសកម្មភាពបំផ្លាញរូបរាងកាយ មានចេតនាប្រល័យពូជសាសន៍ឬអត់ គឺលែងពាក់ព័ន្ធនឹងការកំណត់ទំនួលខុសត្រូវខាងផ្លូវកាយនៃការប្រល័យពូជសាសន៍ហើយ» ។

បន្តទៅទៀត លោក គាំចាន់ បានពិភាក្សាអំពីខុក្រិដ្ឋកម្មប្រឆាំងនឹងជនជាតិវៀតណាម ។ លោកបានកត់សម្គាល់ថាភស្តុតាងក្នុងសំណុំរឿងនេះបង្ហាញថា ចេតនានៃការប្រព្រឹត្តដល់ជនជាតិវៀតណាមបានផ្លាស់ប្តូរតាមពេលវេលា ។ នៅពេលការចាប់ផ្តើមនៃរបបនេះ ការបណ្តេញជនជាតិវៀតណាមដែលជាធម្មតាធ្វើឡើងតាមការបញ្ជូនត្រឡប់ទៅប្រទេសវៀតណាមវិញ គឺជា

គោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ។ ប៉ុន្តែនៅពេលក្រោយមក និងរហូតដល់ទីបញ្ចប់នៃរបបនេះ ចេតនាប្រាកដគឺដើម្បីសម្លាប់ជនជាតិវៀតណាមដែលនៅសេសសល់ ។

លោក គាំចាន់ កត់សម្គាល់ថា ការនិរទេស ឬបញ្ជូនបុគ្គលត្រឡប់ទៅវិញមិនមែនជាអំពើប្រល័យពូជសាសន៍ទេ ប៉ុន្តែវាអាចបង្ហាញពីចេតនាប្រព្រឹត្តការប្រល័យពូជសាសន៍បាន ។ នៅក្នុងសំណុំរឿងការសម្លាប់រង្គាលនៅ *Srebrenica* ភ័ស្តុតាងបានបង្ហាញថាជនជាតិស៊ែប៊ីបានបញ្ជូនស្ត្រី កុមារ និងមនុស្សចាស់ចេញ ដែលជាវិធីខាងផ្លូវកាយមួយ ដើម្បីធានាការបំផ្លិចបំផ្លាញសហគមន៍មូស្លីម ជនជាតិបូស្នៀ ព្រោះវាធ្វើឲ្យមានការលំបាកក្នុងការស្តាបនាសហគមន៍ឡើងវិញ ។ នៅក្នុងសំណុំរឿង ០០២/០១ លេខាតំបន់ ១០៥ បានផ្តល់សក្ខីកម្មថា ប៉ុល ពត បាននិយាយថាគាត់ចង់កម្ចាត់ជនជាតិវៀតណាមទាំងអស់ចេញពីទឹកដីកម្ពុជាប្រជាធិបតេយ្យ ។

លោក គាំចាន់ កត់សម្គាល់ថាទស្សនាវដ្តីទង់បដិវត្តន៍មួយលេខបានរៀបរាប់ពីការបណ្តេញចេញពីប្រទេស ដោយពោលថាមានជនបរទេសជាច្រើន ប៉ុន្តែជនបរទេសមួយប្រភេទមានភាពពិសពុល និងគ្រោះថ្នាក់យ៉ាងខ្លាំងដល់ប្រជាជនរបស់យើងពីព្រោះថាពួកគេបានចូលមកដើម្បីលេបត្របាក់ពួកយើង និងយកអ្វីៗទាំងអស់ពីយើង ព្រមទាំងធ្វើឲ្យប្រជាជាតិរបស់យើងជួបប្រទះនឹងគ្រោះថ្នាក់ ។ នៅក្នុងលេខទស្សនាវដ្តីក្រោយមកទៀត មានការបញ្ជាក់ថាបដិវត្តន៍របស់យើងបានកម្ចាត់ពួកគេចេញពីទឹកដីរបស់យើង ហើយបានបោសសម្អាតពួកគេរាប់ពាន់នាក់ ។

គោលនយោបាយនៃការបញ្ជូនជនជាតិវៀតណាមត្រឡប់ទៅប្រទេសវិញ បានផ្លាស់ប្តូរហើយរឿងនេះត្រូវបានបង្ហាញដោយការផ្តល់សក្ខីកម្មរបស់កាម្មាភិបាលជាន់ខ្ពស់មួយរូបក្នុងសវនាការនេះដែលបានបង្ហាញពីចេតនាប្រាកដនៃគោលនយោបាយរបស់របបនេះ និងដំណើរការដែលវាបានផ្លាស់ប្តូរ ។ «ខ្ញុំបានដឹងពុថាជនជាតិវៀតណាមកំពុងរស់នៅក្នុងប្រទេសកម្ពុជានៅគ្រានោះ ។ ជនជាតិវៀតណាមដែលរស់នៅក្នុងប្រទេសកម្ពុជាបានត្រឡប់មកវិញដើម្បីបង្កបញ្ហាដល់ប្រជាជនកម្ពុជា ហើយមិនព្រមចាកចេញទេ ។ ដំបូងចាប់ពីឆ្នាំ១៩៧០ ជនជាតិវៀតណាមត្រូវបានបញ្ជូនដោយសន្តិវិធីទៅប្រទេសរបស់ខ្លួនវិញដោយរដ្ឋាភិបាលកម្ពុជា ហើយការបញ្ជូននេះបន្តរហូតដល់ឆ្នាំ១៩៧៥ ។ ប៉ុន្តែក្រោយមក យើងត្រូវបានគេដាក់បញ្ជាថាជនជាតិវៀតណាមត្រូវតែកម្ទេចចោលឲ្យអស់ដោយសារតែពួកគេមិនព្រមវិលត្រឡប់ទៅប្រទេសរបស់ពួកគេវិញ» ។ លោក គាំចាន់ បានបញ្ជាក់ថាគោលនយោបាយត្រូវបានផ្លាស់ប្តូរចាប់ពីចំណុចនេះឯង ។

សារស្តីពីគោលនយោបាយនេះហើយគឺជាអ្វីដែលត្រូវបានផ្សព្វផ្សាយដល់កម្មាភិបាលនៅក្នុងប្រទេស ។ នៅឆ្នាំ១៩៧៨ នួន ជា បានធ្វើការសរសើរកង់ទ័ពចំពោះការកម្ទេចយុទ្ធសាស្ត្ររបស់វៀតណាមក្នុងការលុបបំបាត់ពូជសាសន៍កម្ពុជា ។ លោក គាំចាន់ បានមានប្រសាសន៍ជាញឹកញាប់ថា មេដឹកនាំទាំងនោះដែលកំពុងធ្វើគ្រោងការប្រល័យពូជសាសន៍ជារឿយៗតែងកំណត់ថាជនរងគ្រោះជាការគំរាមកំហែងដល់ប្រជាជនរបស់ខ្លួន ដើម្បីញុះញង់ឲ្យមានការសម្លាប់នេះ ។ គាត់បានលើកឧទាហរណ៍ពី នួន ជា ខៀវ សំផន និង ប៉ុល ពត ដែលពួកគេបានទស្សន៍ទាយថា អវសាន្តនៃប្រជាជនខ្មែរនឹងកើតឡើងក្រោមស្នាដៃជនជាតិវៀតណាម និងបានបង្ហាញថាជនជាតិវៀតណាមមានភាពព្រៃផ្សៃ និងឃោរឃៅ ព្រមទាំងបានចោទប្រកាន់ពួកវៀតណាមថាមានចេតនាប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាតិខ្មែរ ។

លោក គាំចាន់ បានផ្តល់ភ័ស្តុតាងថា នេះគឺជាយុទ្ធសាស្ត្រមួយរបស់មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ដោយសារថា ព្រះបាទនរោត្តម សីហនុ បានរំឭកឡើងវិញថាព្រះអង្គបានមានព្រះរាជបន្ទូលជាមួយលោក ខៀវ សំផន ដែលក្នុងនោះ ខៀវ សំផន បាននិយាយថា ដើម្បីបង្រួបបង្រួមប្រជាជន ការញុះញង់ឲ្យពួកគេស្អប់ជនជាតិវៀតណាមកាន់តែខ្លាំងឡើងៗពីមួយថ្ងៃទៅមួយថ្ងៃ គឺជាយុទ្ធសាស្ត្រដ៏ល្អបំផុតដែលយើងអាចធ្វើទៅបាន ។

មេដឹកនាំកម្ពុជាប្រជាធិបតេយ្យបានព្យាយាមទម្លាក់កំហុសលើសត្រូវបរទេសមួយថាជាអ្នកបង្កសេចក្តីឈឺចាប់របស់ប្រជាជនរបស់ពួកគេ ។

នៅឆ្នាំ១៩៧៨ មន្ទីរ៨៧០ បានផ្សព្វផ្សាយបញ្ជាថា ការញុះញង់ឲ្យមានកំហឹងជាតិ និងវណ្ណៈប្រឆាំងនឹងវៀតណាមគឺជាការចាំបាច់ដាច់ខាត ។ នៅពេលនោះ ខៀវ សំផន គឺជាសមាជិកគណៈកម្មការតែម្នាក់គត់នៅមន្ទីរ៨៧០ ។ សាក្សីបានផ្តល់សក្ខីកម្មថា

បញ្ជាបញ្ជូនពីមេដឹកនាំដល់កម្មាភិបាលគឺឲ្យសម្លាប់ជនជាតិវៀតណាមទាំងអស់ដោយចាត់ទុកជាសត្រូវស៊ូពូជរបស់ខ្មែរ សូម្បីតែម្នាក់នោះជាទារកក៏មិនត្រូវលើកលែងដែរ ។

ទាក់ទងទៅនឹងចេតនាប្រល័យពូជសាសន៍របស់បក្សកុម្មុយនីស្តកម្ពុជា លោក គាំចាន់ បានមានប្រសាសន៍ថាពាក្យសម្តីរបស់មេដឹកនាំអគ្គការមួយមានសារសំខាន់ណាស់ក្នុងការយល់ដឹងថាតើអង្គការនោះមានចេតនាដូចម្តេច ។ ប៉ុល ពត បានថ្លែងសុន្ទរកថាមួយដោយ ក្នុងនោះគាត់បានបញ្ជាក់ថា «យើងបានអនុវត្តគោលការណ៍ មួយទល់នឹង ៣០ មានន័យថាយើងបាត់បង់តែមួយ ប៉ុន្តែយួនបាត់បង់សាមសិប» ។ គាត់បាននិយាយបន្តទៀតថា ខណៈយើងមានពីរលាននាក់ ពួកគេត្រូវការ៦០លាននាក់ ដូច្នេះយើងមានចំនួនច្រើនលើសពីចំនួនដែលយើងត្រូវការទៅទៀត ពីព្រោះថាពួកគេមានត្រឹមតែ៥០លាននាក់ប៉ុណ្ណោះ ។ នេះបង្ហាញថាប្រសិនបើមានប្រជាជនកម្ពុជាចំនួនប្រាំបីលាននាក់ នៅខណៈនោះ ប៉ុល ពត ហ៊ានស្ម័គ្រចិត្តលះបង់ប្រជាជនពីរលាននាក់ ដើម្បីសម្លាប់ជនជាតិវៀតណាមទាំងអស់ ព្រោះថាប្រជាជនពីរ លាននាក់គឺគ្រប់គ្រាន់ហើយសម្រាប់ការសម្លាប់ជនជាតិវៀតណាម៥០លាននាក់ ។

លោក គាំចាន់ បានបញ្ជាក់តទៀតថា ផលវិបាកនៃគោលនយោបាយនិងការញុះញង់នេះអាចមើលឃើញបាននៅក្នុងសកម្មភាពរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យនៅពេលពួកគេឆ្លងកាត់ព្រំដែន និងវាយប្រហារនៅវៀតណាម ។ លោកបានទទួលស្គាល់ថាការវាយប្រហារនៅក្នុងប្រទេសវៀតណាមគឺស្ថិតនៅក្រៅវិសាលភាពនៃសំណុំរឿងនេះ ប៉ុន្តែលោកក៏បានកត់សម្គាល់ថាសកម្មភាពទាំងនេះមានការពាក់ព័ន្ធនឹងចេតនារបស់មេដឹកនាំ ។ លោកក៏បានកត់សម្គាល់ថា ជំហររបស់ក្រុមការពារក្តីគឺថាការវាយប្រហារទាំងនេះមិនបានកើតឡើងទេ ។

លោក គាំចាន់ បានបញ្ជាក់ទៀតថា វាត្រូវបានបង្ហាញនៅក្នុងជំនុំជម្រះ រួមមានដោយអ្នកឯកទេសម្នាក់ដែលស្នើសុំដោយមេធាវីការពារក្តីគឺលោក ធើឡឺ ថា នៅឆ្នាំ១៩៧៧ ពួកខ្មែរក្រហមបានវាយប្រហារភូមិនិងទីប្រជុំជនជាច្រើននៅវៀតណាមភាគខាងត្បូង ដោយបានដុតផ្ទះនិងសម្លាប់មនុស្សរាប់រយនាក់ ។ សាក្សីផ្សេងទៀតបានធ្វើសក្ខីកម្មស្តីពីភាពឃោរឃៅ និងភាពអគតិនៃអំពើហិង្សានៃការវាយប្រហារ ។

លោក គាំចាន់ ក៏បានកត់សម្គាល់ថា អំពើហិង្សានេះក៏ត្រូវបានលោក ខៀវ សំផន ផ្តល់ជាទស្សនៈនៅក្នុងសៀវភៅរបស់គាត់អំពីប្រវត្តិសាស្ត្រថ្មីៗរបស់ប្រទេសកម្ពុជា ដោយគាត់បានសរសេរថាព្រឹត្តិការណ៍ដែលបានរៀបរាប់មកនេះគឺមិនអាចប្រកែកបានឡើយ ហើយការដែលខ្មែរក្រហមបានធ្វើការលុកលុយទៅក្នុងភូមិវៀតណាមនៅតាមបណ្តោយព្រំដែនដើម្បីប្រព្រឹត្តឧក្រិដ្ឋកម្មដ៏គួរឲ្យរន្ធត់ប្រឆាំងនឹងជនស៊ីវិលវៀតណាម គឺពិតជាបានកើតឡើងមែនដោយគ្មានមន្ទិលសង្ស័យឡើយ ។ មានភស្តុតាងឯកសារដែលបញ្ជាក់ថា ខៀវ សំផន និង នួន ជា បានដឹងអំពីការវាយប្រហារទាំងនេះ ហើយក្នុងឯកសារនោះរួមមានទូរលេខដែលផ្ញើទៅកាន់ ប៉ុល ពត ខៀវ សំផន នួន ជា និងការិយាល័យលេខ៨៧០ ដែលរៀបរាប់អំពីការប្រើកម្លាំងកាំភ្លើង ការបំផ្លិចបំផ្លាញផ្ទះសម្បែង យោធា និងជនស៊ីវិល និងការសម្លាប់ជនជាតិវៀតណាម ។

បន្ទាប់មកទៀត លោក គាំចាន់ បានបញ្ជាក់ថា នៅឆ្នាំ ១៩៧៧ ការសម្រេចចិត្តមួយត្រូវបានធ្វើឡើងដោយមិនឲ្យបណ្តេញជនជាតិវៀតណាមចេញទេ តែឲ្យសម្លាប់ពួកគេវិញ ។ សាក្សីម្នាក់បានផ្តល់សក្ខីកម្មថា នៅភូមិភាគពាយ័ព្យ គាត់ត្រូវបានបញ្ជាឲ្យរាយការណ៍អំពីជនជាតិវៀតណាមណាដែលគាត់ជួបប្រទះ ហើយពួកគេនឹងត្រូវសម្លាប់ចោល ។ លោក គាំចាន់ បានបង្ហាញពីបណ្តុំវីឌីអូនៃការថ្លែងរបស់សាក្សីមួយចំនួនអំពីដំណើរដែលជនជាតិវៀតណាមត្រូវបានប្រព្រឹត្តលើ ។ សាក្សីបានផ្តល់សក្ខីកម្មអំពីការដែលគេរកឃើញថាសមាជិកគ្រួសាររបស់ពួកគេត្រូវបានសម្លាប់ ជាពិសេសកូនរបស់ពួកគេ និងដំណើរដែលគោលនយោបាយគឺធ្វើឡើងដើម្បី «បើដីកស្មៅ ត្រូវដីកទាំងឫស» ដែលមានន័យថាសាច់ញាតិក៏ត្រូវបានសម្លាប់ដែរ ។ ពួកគេបានថ្លែងបន្តក្នុងសក្ខីកម្មថា ប្រសិនបើប្តីជាជនជាតិខ្មែរ ឯប្រពន្ធជាជនជាតិវៀតណាម ប្រពន្ធនិងកូនៗនឹងត្រូវគេនាំយកទៅសម្លាប់ ។ សាក្សីម្នាក់បានថ្លែងថាជនជាតិវៀតណាមទាំងអស់នៅក្នុងភូមិរបស់គាត់ត្រូវបានគេនាំយកទៅសម្លាប់ទាំងអស់ ។ ថែមពីនេះ មានភស្តុតាងឯកសារ ក្នុងនោះរួមមានទូរលេខពីភូមិភាគបស្ចិម ដែលបាននិយាយថាខ្លួនបានអនុវត្តបញ្ជាបក្សដើម្បីកម្ទេចនិងបោសសម្អាតជនជាតិវៀតណាម

ហើយលទ្ធផលសម្រេចបានគឺការកម្ទេច "ជនជាតិយួន១០០នាក់ រួមមានទាំងតូចទាំងធំ មនុស្សពេញវ័យ និងកុមារ" ។

នៅចុងបញ្ចប់នៃរបបនេះ ការប្រព្រឹត្តលើជនជាតិវៀតណាមដែលនៅសេសសល់អាចមើលឃើញបានក្នុងចំនួនជនជាតិវៀតណាមនៅស-២១ ។ លោក គាំចាន់ បានបង្ហាញក្រាហ្វិចមួយដែលបង្ហាញពីចំនួនប្រជាជនវៀតណាមប្រចាំខែដែលត្រូវបានចាប់ខ្លួននិងបញ្ជូនទៅស-២១ ហើយក្រាហ្វមួយទៀតដែលបង្ហាញថា នៅស-២១ មានបុគ្គល៧២៨នាក់ ដែលត្រូវបានសម្គាល់ជាជនជាតិវៀតណាម ដែលក្នុងនោះ ៣៥% ជាទាហានហើយ ៤៩% ទៀតត្រូវបានចាត់ថ្នាក់ជាជនស៊ីវិល ។ ទាក់ទងទៅនឹងភាពពិតនៃការរាយការណ៍នៅស-២១ លោក គាំចាន់ បានកត់សម្គាល់ថា ម្នាក់ក្នុងចំណោមកម្មាភិបាលស-២១ បានផ្តល់សក្ខីកម្មថា កុមារមិនត្រូវបានចុះកំណត់ត្រានៅស-២១ទេដូច្នេះកំណត់ត្រាទាំងនេះមិនឆ្លុះបញ្ចាំងពីចំនួនសរុបនៃកុមារដែលត្រូវបានសម្លាប់នៅមន្ទីរស -២១ ទេ ។ តែមានកុមារជនជាតិវៀតណាម៧នាក់ដែលមានឈ្មោះនៅក្នុងកំណត់ត្រាស-២១ ហើយព្រះរាជអាជ្ញាបានបង្ហាញរូបភាពមួយចំនួននៃកុមារទាំងនេះដែលភាគច្រើនមានអាយុក្រោម ១០ឆ្នាំ ។ ក្នុងនោះ កុមារពីរនាក់ជាកុមារាអាយុ៧ឆ្នាំ ហើយនៅក្នុងកំណត់ត្រាស-២១ កុមារពីរនាក់នេះត្រូវបានពិពណ៌នាថា ជា "ចារបុរសវៀតណាម" ។

លោក គាំចាន់ បានធ្វើការបង្វែរទៅលេខទស្សនាវដ្តីទង់បដិវត្តន៍ចាប់ពីខែមេសា ឆ្នាំ១៩៧៨ ដែលបានប្រារព្ធការលុបបំបាត់យួននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយបានបញ្ជាក់ថា កាលអតីតកាល ពួកគេ (យួន) មានចំនួន ១០០០.០០០នាក់ តែឥឡូវនេះពូជពួកគេគ្មាននៅសល់សូម្បីតែមួយ ។

លោក គាំចាន់ បានបញ្ជាក់ទៀតថា ការសម្លាប់រង្គាលនៃជនជាតិវៀតណាមគឺជាអំពើប្រល័យពូជសាសន៍ ដោយសារតែពួកគេព្យាយាមបំផ្លិចបំផ្លាញជនជាតិវៀតណាម នៅកម្ពុជា ។

បន្ទាប់មកលោក គាំចាន់ បានពិភាក្សាពីការប្រព្រឹត្តលើជនជាតិចាម ។ គាត់បានត្រលប់ទៅពិនិត្យនិយមន័យនៃការប្រល័យពូជសាសន៍ ហើយបានកត់សម្គាល់ថាវាជាប្រធានបទក្នុងច្បាប់អន្តរជាតិមួយដែលមានចំណុចខ្វះខាតហើយកំពុងទទួលការអភិវឌ្ឍឲ្យកាន់តែប្រសើរ ហើយសំណួរមួយក្នុងចំណោមសំណួរដ៏សំខាន់ដែលចោទលើការបកស្រាយនិយមន័យនេះគឺថា តើពាក្យថា (ជាអាទិ៍) មានន័យយ៉ាងណា ។ ដោយហេតុថាពាក្យទាំងអស់នៅក្នុងលក្ខន្តិកៈត្រូវបានសន្មត់ថាមានអត្ថន័យមួយច្បាស់លាស់ តើវាមានអត្ថន័យយ៉ាងណាចំពោះការបំផ្លាញក្រុមសាសនា "ជាអាទិ៍"?

ក្រុមព្រះរាជអាជ្ញាបានដាក់សំណើអះអាងថាក្រុមសាសនាមានការអនុវត្តជាសមូហភាពមួយ ហើយប្រសិនបើអ្នកកម្ទេចសមត្ថភាពរបស់ក្រុមនោះក្នុងការអនុវត្តសាសនានោះ ទោះបីជាមានបុគ្គលណានៅមានជីវិតក៏ដោយ ក៏ការពិតក្រុមនេះត្រូវបានបំផ្លាញជាអាទិ៍ទៅហើយ ។ លោក គាំចាន់ បានកត់សម្គាល់ថាមានវិធីផ្សេងៗគ្នាដើម្បីធ្វើរឿងនេះ ដែលខ្លះទាក់ទិននឹងអំពើប្រល័យពូជសាសន៍ ហើយខ្លះទៀតមិនទាក់ទិនទេ ពោលគឺអាស្រ័យថាតើទង្វើនោះគឺជាអំពើប្រល័យពូជសាសន៍ឬក៏អត់ ។ ការបកស្រាយខ្លះនៃពាក្យ "ជាអាទិ៍" គឺថាប្រសិនបើអ្នកសម្លាប់ជនជាតិចាមដោយសារតែពួកគេជាអ្នកកាន់សាសនាអ៊ីស្លាម នោះបានន័យថាអ្នកបានបំផ្លាញក្រុម "ជាអាទិ៍" ប៉ុន្តែលោក គាំចាន់ បានកត់សម្គាល់ថាទង្វើនេះត្រូវបានដាក់បញ្ចូលរួចហើយ នៅក្នុងនិយមន័យនៃការប្រល័យពូជសាសន៍ ដូច្នេះតើពាក្យថា "ជាអាទិ៍" មានន័យយ៉ាងម៉េច? តាមមតិរបស់គាត់ពាក្យ "ជាអាទិ៍" បានន័យថា ជាអត្តសញ្ញាណរបស់ក្រុមក្នុងលក្ខណៈក្រុមរួមមួយ ។ គាត់បានផ្តល់ឧទាហរណ៍មួយថា ប្រសិនបើអ្នកបញ្ជាប្រាប់ក្រុមសាសនាថាពួកគេត្រូវតែដូរសាសនា បើមិនអញ្ចឹងទេនឹងត្រូវគេយកទៅសម្លាប់ នោះ បានន័យថា អ្នកបានបំផ្លិចបំផ្លាញក្រុមនេះទៅហើយ ព្រោះថាអ្នកដែលមិនព្រមដូរសាសនានឹងត្រូវបានសម្លាប់ ចំណែកអ្នកដែលបានដូរសាសនានឹងលែងជាផ្នែកនៃក្រុមនេះហើយ ដូច្នេះបានន័យថាក្រុមនេះត្រូវបានបំផ្លិចបំផ្លាញទៅហើយ ។

លោក គាំចាន់ បាននិយាយថា នេះគឺជាការបកស្រាយដ៏សំខាន់មួយដោយសារតែគោលនយោបាយទាក់ទងនឹងការប្រព្រឹត្តលើជនជាតិចាមក៏វិវត្តទៅតាមពេលវេលាដែរ ហើយការប៉ុនប៉ងបង្ខំឲ្យជនជាតិចាមដូរសាសនាដើម្បីចុះសម្រុងបានកើតមានឡើងតាំងពីដំបូងក្នុងរបបនេះ គឺមុនឆ្នាំ១៩៧៥ ទៅទៀត ។ គោលនយោបាយនេះត្រូវបានផ្លាស់ប្តូរនៅឆ្នាំ១៩៧៥ នៅពេលដែល

ជនជាតិចាមបានបដិសេធការបោះបង់សាសនារបស់ពួកគេ ហើយបានធ្វើការបះបោរប្រឆាំងនឹងខ្មែរក្រហម ។ ក្រោយមក គោលនយោបាយនេះត្រូវបានផ្លាស់ប្តូរទៅជាការសម្លាប់ជនជាតិចាមវិញ ប៉ុន្តែក៏មានការព្យាយាមបំបែកក្រុមចាមឲ្យចេញពីតំបន់ប្រមូលផ្តុំរបស់ពួកគេជាយូរលង់ណាស់មកហើយ នៅតាមដងទន្លេមេគង្គ ។

លោក គាំចាន់ បានពិនិត្យមើលភស្តុតាងដែលទាក់ទងទៅនឹងការបង្ខំឲ្យជនជាតិចាមចុះសម្រុង ដែលត្រូវធ្វើឡើងដោយការហាមឃាត់ការអនុវត្តសាសនារបស់ពួកគេ ។ លោកបានកត់សម្គាល់ការលើកឡើងរបស់មេធាវីការពារក្តីទាក់ទិននឹងការធ្វើសកម្មភាពហាមឃាត់ការអនុវត្តសាសនាដែលមិនមែនជាការបំពានច្បាប់អន្តរជាតិឡើយ (ដូចជាការហាមមិនឲ្យធ្វើអធិដ្ឋាននៅតាមផ្លូវ) ។ លោកបានបង្វែរទៅករណីមួយក្នុងចំណោមករណីដែលមេធាវីការពារក្តីបានលើកឡើងដែលក្នុងនោះសេចក្តីសម្រេចពិតជាបានចែងយ៉ាងច្បាស់ថាច្បាប់អន្តរជាតិទទួលស្គាល់ថាការអនុវត្តសាសនារបស់ខ្លួនគឺជាសិទ្ធិមួយរបស់មនុស្ស ហើយសេរីភាពសាសនាគឺជារឿងមនសិការផ្ទាល់ខ្លួននិងបង្កប់អត្ថន័យនៃសេរីភាពបញ្ចេញមតិជាបុគ្គល និងតាមទីសាធារណៈ ឬតាមសហគមន៍ ដោយធ្វើឡើងជាមួយអ្នកដទៃទៀតដែលមានជំនឿសាសនាដូចគ្នា ។

ខ្មែរក្រហមហាមឃាត់ការអនុវត្តសាសនាសម្រាប់ជនជាតិចាមនិងសម្រាប់ពុទ្ធសាសនិកផងដែរ ។ ការអប់រំកុមារក៏ត្រូវបានហាមឃាត់ ហើយពួកខ្មែរក្រហមបានព្យាយាមបំបែកក្រុមចាមទៅតំបន់ផ្សេងទៀតនៃប្រទេសកម្ពុជា ។ លោក គាំចាន់ បានពិនិត្យមើលសក្ខីកម្មរបស់សាក្សីដែលគាំទ្រដល់ភាពមានពិតនិងការអនុវត្តគោលនយោបាយស្តីពីការប្រព្រឹត្តលើជនជាតិចាម ។ ជាឧទាហរណ៍ សាក្សីម្នាក់បាននិយាយថាអ្នកតំណាងជាន់ខ្ពស់ម្នាក់របស់អង្គការបានប្រាប់គាត់ថា ទៅមុខទៀតនឹងមានតែប្រជាជនជនជាតិតែមួយគត់ ហើយជនជាតិនោះគឺជាខ្មែរយើង ហើយនឹងគ្មានជនជាតិចាមទេ ។ លោកក៏បានមានប្រសាសន៍ដែរថាជនជាតិចាមមិនត្រូវបានអនុញ្ញាតឲ្យស្នាក់នៅក្នុងភូមិរបស់ពួកគេទេដោយពួកគេត្រូវបានបំបែក សាសនាពួកគេត្រូវបានលុបបំបាត់ ហើយពួកគេមិនត្រូវបានអនុញ្ញាតឲ្យគោរពសាសនាពួកគេទៀតឡើយ ។ សាក្សីជនជាតិចាមម្នាក់ទៀតបានផ្តល់សក្ខីកម្មថា ស្រ្តីទាំងឡាយត្រូវបានបង្ខិតបង្ខំឲ្យកាត់សក់ខ្លី ហើយពួកគេទាំងអស់ត្រូវបានបង្ខំឲ្យបរិភោគសាច់ជ្រូក ព្រមទាំងមិនត្រូវបានអនុញ្ញាតឲ្យនិយាយភាសាចាមទេ ។

បន្ទាប់មកទៀត លោក គាំចាន់ បានធ្វើការពិភាក្សាពីកាលៈទេសៈនៃការបះបោររបស់ជនជាតិចាម ដែលត្រូវបានរាយការណ៍នៅក្នុងឯកសារមួយពីតំបន់៥ ។ នៅភូមិភាគពាយ័ព្យ មិនមានជនជាតិចាមជាច្រើនទេ ប៉ុន្តែមានអ្នកមួយចំនួននៅទីនោះ ហើយពួកគេព្យាយាមប្រើប្រាស់សិទ្ធិសេរីភាពសាសនារបស់រដ្ឋធម្មនុញ្ញ ។ ពួកគេបានតវ៉ារឿងអាហារដែលបានផ្តល់ឲ្យ ដែលជាការប្រព្រឹត្តផ្ទុយនឹងសាសនារបស់ពួកគេ ប៉ុន្តែប្រតិកម្មឆ្លើយតបនឹងការតវ៉ានេះគឺការបញ្ជាឲ្យរកមេដឹកនាំចលនារបស់ពួកគេដើម្បីយកមកបោសសម្អាត ។

លោក គាំចាន់ បានពន្យល់ថាមធ្យោបាយមួយផ្សេងទៀតដើម្បីបំផ្លាញក្រុមមួយគឺការសំដៅទៅលើផ្នែកខ្លះនៃក្រុមនោះ ដែលមានភាពចាំបាច់សម្រាប់ការរស់រានមានជីវិតរបស់ក្រុម ។ ប្រសិនបើផ្នែកជាក់លាក់ណាមួយនៃក្រុមនេះជានិមិត្តរូបនៃក្រុមទាំងមូលឬក៏ជាការចាំបាច់សម្រាប់ការរស់រានមានជីវិតរបស់ក្រុមនោះ ហើយត្រូវបានគេសំដៅនិងបំផ្លាញចោលនោះ នោះបានន័យថាទង្វើនេះគឺត្រូវជាមួយនឹងបទដ្ឋាននៃការប្រល័យពូជសាសន៍ ហើយ ដោយសារតម្រូវការឲ្យទាមទារឲ្យមានការបំផ្លិចបំផ្លាញក្រុមមួយដោយផ្នែកទាំងមូលឬផ្នែកខ្លះ ។ លោក គាំចាន់ បានបញ្ជាក់ថា នេះជាអ្វីដែលបានកើតឡើងចំពោះជនជាតិចាម ។ នៅក្នុងកម្ពុជាប្រជាធិបតេយ្យ ចំនួនហាគីម (មេភូមិជនជាតិចាម) បានធ្លាក់ចុះពីចំនួន១១៣នាក់ ទៅ២០នាក់ ហើយចំនួនទួន (គ្រូកាន់សាសនាអ៊ីស្លាម) ធ្លាក់ពី ៣០០នាក់ ដល់ ៣៨នាក់ ។ អ្នកជំនាញបានផ្តល់សក្ខីកម្មថាក្នុងប៉ុន្មានឆ្នាំដំបូងនៃការចាប់ផ្តើមរបស់កម្ពុជាប្រជាធិបតេយ្យ ការសម្លាប់មិនត្រូវបានសំដៅប្រឆាំងនឹងជនជាតិចាមទាំងអស់ទេ ប៉ុន្តែគ្រាន់តែសំដៅលើអ្នកដែលបដិសេធការបោះបង់ចោលសាសនាសាសនា ទំនៀមទម្លាប់ និងភាសារបស់ពួកគេប៉ុណ្ណោះ ។

**រ៉ូនិត អារី**

# សេចក្តីថ្លែងការណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ស្តីពីសំណុំរឿង០០៣

នៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៧ សហព្រះរាជអាជ្ញាជាតិ និងអន្តរជាតិ បានដាក់ដីកាសន្និដ្ឋានស្ថាពររបស់ខ្លួន ក្នុងសំណុំរឿង ០០៣ ពាក់ព័ន្ធនឹងកិច្ចស៊ើបសួរលើ មាស មុត ។ ដីកាសន្និដ្ឋានស្ថាពរត្រូវបានចេញដោយសហព្រះរាជអាជ្ញា នៅពេលបិទកិច្ចស៊ើបសួរ ដោយស្នើឲ្យសហចៅក្រមស៊ើបអង្កេតបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ ឬលើកលែងការចោទប្រកាន់ ។ នៅក្នុងសំណុំរឿង០០៣ សហព្រះរាជអាជ្ញាទាំងពីរបានដាក់ដីកាសន្និដ្ឋានស្ថាពរដាច់ដោយឡែកពីគ្នា ដោយឆ្លុះបញ្ចាំងទស្សនៈខុសគ្នាអំពីថាតើសហចៅក្រមស៊ើបអង្កេតត្រូវចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះប្រឆាំងនឹង មាស មុត ដែរឬយ៉ាងណា ។

វិធានផ្ទៃក្នុង អ.វ.ត.ក ចែងថា ទោះបីជាដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាត្រូវបានដាក់ជាការសម្ងាត់ក៏ដោយ ក៏សហព្រះរាជអាជ្ញា អាចបញ្ចេញនូវសេចក្តីសង្ខេបអំពីគោលបំណងនៃសេចក្តីសន្និដ្ឋានរបស់ខ្លួនជូនសាធារណជនបានដែរ ។ ដើម្បីជាប្រយោជន៍នៃតម្លាភាពដល់សាធារណជន សហព្រះរាជអាជ្ញាអន្តរជាតិ សូមផ្តល់ជូននូវសេចក្តីសង្ខេបព័ត៌មានដូចខាងក្រោមដែលមាននៅក្នុងដីកាសន្និដ្ឋានស្ថាពររបស់ខ្លួន ទាក់ទងនឹងកិច្ចស៊ើបសួរក្នុងសំណុំរឿង មាស មុត ។ សូមអ្នកអានជ្រាបថា សេចក្តីសង្ខេបខាងក្រោមនេះ មិនរាប់បញ្ចូលនូវទស្សនៈរបស់សហព្រះរាជអាជ្ញាជាតិ (ដែលត្រូវបានសង្ខេបនៅក្នុងសេចក្តីសង្ខេបជាសាធារណៈដាច់ដោយឡែក) និងមេធាវីការពារក្តី ហើយក៏មិនមែនមានចេតនាឆ្លុះបញ្ចាំងអំពីទស្សនៈរបស់សហចៅក្រមស៊ើបអង្កេតដែរ ដោយសារពួកគាត់នឹងធ្វើការកំណត់លើបញ្ហាទាំងអស់នេះដោយពួកគាត់ផ្ទាល់ ។

ពេលនេះ ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា បានដាក់ហើយ ។ មេធាវីការពារក្តី មាស មុត នឹងមានឱកាសឆ្លើយតបទៅនឹងដីកាសន្និដ្ឋានទាំងនេះជាមួយនឹងទស្សនៈរបស់ខ្លួនអំពីច្បាប់ និងភ័ស្តុតាង ។ បន្ទាប់មក វាអាស្រ័យលើសហចៅក្រមស៊ើបអង្កេតដែលនឹងត្រូវសម្រេចថាតើ មាស មុត ត្រូវដាក់ឲ្យស្ថិតនៅក្រោមយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ឬយ៉ាងណា និងថាតើការស៊ើបអង្កេតនេះបានបង្ហាញឲ្យឃើញអំពីការទទួលខុសត្រូវរបស់គាត់ ចំពោះឧក្រិដ្ឋកម្មនានាដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ដល់បទដ្ឋានដែលតម្រូវដើម្បីចោទប្រកាន់គាត់ និងបញ្ជូនខ្លួនគាត់ទៅជំនុំជម្រះ ឬយ៉ាងណា ។ ដូចគ្នាទៅនឹងជនត្រូវចោទ និងជនជាប់ចោទទាំងអស់នៅ អ.វ.ត.ក ដែរ មាស មុត នៅតែរក្សាការសន្មតថាគ្មានទោសដដែលដែលវានឹងត្រូវអស់ តែនៅពេលណាដែលពិរុទ្ធភាពរបស់គាត់ត្រូវបានរកឃើញនៅពេលសវនាការ និងត្រូវបានតម្កល់តាមរយៈបណ្តឹងសាទុក្ខណាមួយប៉ុណ្ណោះ ។

## យុត្តាធិការបុគ្គល

ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា មានភ័ស្តុតាងបញ្ជាក់ថា មាស មុត គឺទាំងជា «មេដឹកនាំជាន់ខ្ពស់ផង និងទាំងជាជនម្នាក់ក្នុងចំណោមជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត» នៃរបបកម្ពុជាប្រជាធិបតេយ្យចំពោះឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តនៅចន្លោះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ដែលស្ថិតនៅក្នុងនិយមន័យនៃច្បាប់ អ.វ.ត.ក ដូច្នេះ គឺស្ថិតក្រោមយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ។

ដីកាសន្និដ្ឋានចង្អុលបង្ហាញថា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មាស មុត បានកាន់មុខតំណែងយោធា និងនយោបាយថ្នាក់ខ្ពស់ជាច្រើន ទាំងនៅថ្នាក់ជាតិនិងថ្នាក់តំបន់ ដែលបានធ្វើឲ្យគាត់ក្លាយជាមេដឹកនាំជាន់ខ្ពស់ និងជាជនដ៏មានអំណាចម្នាក់នៃរបបនេះ ។ មាស មុត បានធ្វើជាមេបញ្ជាការជាន់ខ្ពស់យោធារួចជាស្រេចក្នុងខែមេសា ឆ្នាំ១៩៧៥ ពេលខ្មែរក្រហមឡើងកាន់អំណាច ។ នៅក្នុងអំឡុងពេលនៃរបបនេះ គាត់ត្រូវបានដំឡើងមុខតំណែងផ្នែកយោធា និងនយោបាយកាន់តែខ្ពស់ថែមទៀត ។ មាស មុត បានប្រើប្រាស់នូវសិទ្ធិអំណាចពីតួនាទីដ៏មានឥទ្ធិពលដែលកាន់តែកើនឡើងនេះ

ដើម្បីអនុវត្តឧក្រិដ្ឋកម្មដូចបានរៀបរាប់នៅក្នុងដីកាសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ។

ចាប់ពីឆ្នាំ១៩៧៥-១៩៧៩ មាស មុត គឺជាលេខាកងពលធំ ១៦៤ ដែលជាកងពលធំដ៏ធំជាងគេនៅក្នុងកងទ័ពបដិវត្តន៍កម្ពុជា ។ កងពលធំ ១៦៤ មានទ័ពរហូតដល់ ១០.០០០នាក់ និងរួមបញ្ចូលទាំងកងទ័ពជើងទឹករបស់កម្ពុជាប្រជាធិបតេយ្យ ។ ក្នុងពេលដំណាលគ្នា មាស មុត កាន់មុខតំណែងជាលេខាតំបន់ស្វយ័តកំពង់សោម ដែលមានជនស៊ីវិលពី៨.០០០-៩.០០០នាក់ ស្ថិតនៅក្រោមសិទ្ធិអំណាចរបស់គាត់ផ្ទាល់ ។ ក្រោយមកទៀត នៅក្នុងអំឡុងពេលនៃការបោសសម្អាតផ្ទៃក្នុងរបស់កម្ពុជាប្រជាធិបតេយ្យ មាស មុត ក៏ត្រូវបានផ្តល់សិទ្ធិអំណាចលើតំបន់យ៉ាងធំនៃតំបន់ស្វយ័ត ៥០៥ (ខេត្តក្រចេះ) ។ នៅថ្នាក់ជាតិវិញ មាស មុត ត្រូវបានតែងតាំងក្នុងគណៈមជ្ឈិម ប.ក.ក ។ បន្ទាប់មកក្នុងឆ្នាំ១៩៧៨ គាត់បានក្លាយជាអនុលេខានៃអគ្គបញ្ជាការកងទ័ពបដិវត្តន៍កម្ពុជា ដែលជាមុខតំណែងយោធាដ៏សំខាន់បំផុតមួយនៅក្នុងកម្ពុជាប្រជាធិបតេយ្យ ដែលមានសិទ្ធិអំណាចចេញបញ្ជាដល់អង្គភាពកងទ័ពបដិវត្តន៍កម្ពុជាទាំងអស់នៅទូទាំងប្រទេសទាំងមូល ។ តាមទស្សនៈរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ដោយសារឋានន្តរស័ក្តិក្នុងជួរកងទ័ព និងនយោបាយរបស់គាត់ មាស មុត គឺជាមនុស្សម្នាក់ក្នុងចំណោមកម្មាភិបាលដ៏មានអំណាច និងមានឥទ្ធិពលបំផុត ឬ "មេដឹកនាំជាន់ខ្ពស់" ដែលស្ថិតនៅលើកំពូលនៃឋានានុក្រម ប.ក.ក ។

ដីកាសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាអន្តរជាតិក៏បានអះអាងផងដែរថា មាស មុត គឺជាបុគ្គលម្នាក់ដែលស្ថិតក្នុងចំណោមបុគ្គលនៃ "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងកម្ពុជាប្រជាធិបតេយ្យ ។ មុខតំណែងនៃការទទួលខុសត្រូវរបស់ មាស មុត បានផ្តល់នូវលទ្ធភាពឲ្យគាត់អាចធ្វើការរួមចំណែកជាដុំកំភួនចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តប្រឆាំងនឹងប្រជជនស៊ីវិលកម្ពុជា បុគ្គលិកយោធានៃកងទ័ពបដិវត្តន៍កម្ពុជារាប់ពាន់នាក់ និងជនបរទេស ជាពិសេសគឺជនជាតិវៀតណាម និងថៃ ។

សហព្រះរាជអាជ្ញាអន្តរជាតិក៏បានលើកអំពីការព្រួយបារម្ភថាតើការបញ្ជូន មាស មុត ទៅជំនុំជម្រះនឹងនាំឲ្យមានផលប៉ះពាល់យ៉ាងណានោះផងដែរ ក្នុងការ "ស្វែងរកយុត្តិធម៌ និងផ្សះផ្សាជាតិ ស្ថេរភាព សន្តិភាព និងសន្តិសុខជាតិ" ។ សហព្រះរាជអាជ្ញាអន្តរជាតិបានកត់សម្គាល់ថា ការកាត់ទោស និងការផ្តន្ទាទោសដាក់ពន្ធនាគារមួយជីវិតដែលបានដាក់នៅក្នុងសំណុំរឿង០០១(ប្រឆាំងនឹង កាំង ហ្កេកអ៊ាវ ហៅ ឌុច) និងសំណុំរឿង០០២/០១ (ប្រឆាំងនឹង នួន ជា និងខៀវ សំផន) មិនមានអនុភាពអវិជ្ជមានទៅលើការផ្សះផ្សាជាតិ ស្ថេរភាព សន្តិភាព ឬសន្តិសុខជាតិឡើយ ប៉ុន្តែផ្ទុយទៅវិញត្រូវបានកោតសរសើរជាញឹកញាប់ចំពោះអនុភាពជាវិជ្ជមានជាច្រើនរបស់វា រួមទាំងការផ្តល់ជូនដល់ជនរងគ្រោះនៃរបបខ្មែរក្រហមនៅកម្ពុជា នូវវិធានការយុត្តិធម៌ខ្លះៗផងដែរ ។ ជាងនេះទៀត គ្មានប្រតិកម្មអវិជ្ជមានពីសាធារណជនចំពោះការបង្ហាញ មាស មុត និងជនសង្ស័យដទៃទៀតដែលត្រូវបានដាក់ឲ្យស្ថិតក្រោមកិច្ចស៊ើបសួរក្នុងសំណុំរឿង០០៣ និង០០៤ នោះឡើយ ។ សហព្រះរាជអាជ្ញាអន្តរជាតិជឿថា ដីកាបញ្ជូនខ្លួន មាស មុត ទៅជំនុំជម្រះ នឹងមិនប៉ះពាល់ដល់ការផ្សះផ្សាជាតិ ស្ថេរភាព សន្តិភាព ឬសន្តិសុខជាតិនៅកម្ពុជាឡើយ ។ ផ្ទុយមកវិញ យើងជឿថា កិច្ចខិតខំប្រឹងប្រែងដើម្បីដាក់ឲ្យមេដឹកនាំជាន់ខ្ពស់នៃកម្ពុជាប្រជាធិបតេយ្យ ឲ្យទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដ៏រន្ធត់ចំពោះសកម្មភាពរបស់ពួកគេ នឹងបង្កើនទំនុកចិត្តសាធារណជនឲ្យមានជំនឿយ៉ាងមុតមាំថា បុគ្គលដ៏មានឥទ្ធពលមិនអាចគេចវេះជារៀងរហូតពីការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនានាឡើយ និងថាយុត្តិធម៌នឹងត្រូវសម្រេចបាន ។

## ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ

នៅក្នុងដីកាសន្និដ្ឋានស្ថាពររបស់ខ្លួន សហព្រះរាជអាជ្ញាអន្តរជាតិបានផ្តល់ការវិភាគនៅលើភស្តុតាងនានាដែលប្រមូលបាននៅក្នុងពេលស៊ើបសួរ និងការពន្យល់មួយទាក់ទងនឹងមូលហេតុដែលបើតាមទស្សនៈរបស់គាត់ ថាហេតុអ្វីបានជាវាបានកំណត់អំពីការទទួលខុសត្រូវរបស់ មាស មុត ចំពោះឧក្រិដ្ឋកម្មធ្ងន់ធ្ងរនានាដែលស្ថិតនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក ទៅនឹងបទដ្ឋានចាំបាច់ដែលត្រូវនាំខ្លួនគាត់ទៅជំនុំជម្រះ ។

សហព្រះរាជអាជ្ញាអន្តរជាតិលើកឡើងករណីថា មាស មុត គួរត្រូវបញ្ជូនខ្លួនទៅជំនុំជម្រះ និងកាត់សេចក្តីចំពោះបទប្រល័យ

ពូជសាសន៍លើក្រុមជនជាតិវៀតណាម នៅក្នុងប្រទេសកម្ពុជា ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងរូបភាពជាអំពើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញ និងអំពើអមនុស្សធម៌ផ្សេងៗទៀត (ជាពិសេស ការប្រព្រឹត្តដោយអមនុស្សធម៌ ការធ្វើឲ្យបាត់ខ្លួនដោយបង្ខំ អាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈនៅក្នុងបរិបទនៃអាពាហ៍ពិពាហ៍ដោយបង្ខំ) និងការបំពារបំពានយ៉ាងធ្ងន់ទៅលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ ។

កិច្ចស៊ើបសួរដែលផ្តោតទៅលើតួនាទីរបស់ មាស មុត នៅក្នុងការបោសសម្អាតរបស់ ប.ក.ក ជាចម្បងគឺទៅលើកងពលធំនៃកងទ័ពបដិវត្តន៍កម្ពុជា រួមទាំងកងពលធំរបស់គាត់ផ្ទាល់ គឺកងពលធំ ១៦៤ និងកងពលធំ ១១៧ ដែលមានមូលដ្ឋាននៅក្នុងតំបន់ ៥០៥ មន្ទីរសន្តិសុខចំនួនពីរ និងទីតាំងការដ្ឋាន ហើយនឹងតំបន់បង្កបង្កើនផលកសិកម្មជាច្រើនកន្លែងនៅតំបន់ស្វយ័តកំពង់សោម ព្រមទាំងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តប្រឆាំងជនទាំងឡាយដែលគេបានចាប់ខ្លួនពីសមុទ្រ និងពីកោះនានាដែលបានទាមទារដោយកម្ពុជាប្រជាធិបតេយ្យ ។ កិច្ចស៊ើបសួរដែលបានបង្កើតឡើងនូវភស្តុតាងដែលគួរឲ្យជឿជាក់បានថា មាស មុត បានអនុញ្ញាតឲ្យមានការបញ្ជូនខ្លួនជនរងគ្រោះរបស់គាត់ជាច្រើន ទៅកាន់មន្ទីរសន្តិសុខធំជាងគេ និងដ៏អសោចបំផុតរបស់កម្ពុជាប្រជាធិបតេយ្យ គឺស-២១ នៅភ្នំពេញ ដែលគេបានដឹងច្បាស់ថាពួកគាត់ត្រូវបានឃុំឃាំងក្នុងលក្ខខណ្ឌដ៏អមនុស្សធម៌ ធ្វើទារុណកម្ម និងសម្លាប់ចោល ។ ឧក្រិដ្ឋកម្មរបស់ មាស មុត មិនមែននៅដាច់ឆ្ងាយពីគេ ឬក៏មិនជាប់ទាក់ទងគ្នានោះដែរ ប៉ុន្តែ វាគឺជាឧក្រិដ្ឋកម្មដែលបានកើតឡើងជាបន្តបន្ទាប់នៅទូទាំងជីវលោនៃកម្ពុជាប្រជាធិបតេយ្យទាំងមូល ដែលជាផ្នែកនៃការធ្វើទុក្ខបុកម្នេញជាប្រព័ន្ធទៅលើប្រជាជន ។

១) ការបោសសម្អាតកងពលធំ១៦៤៖ មាស មុត បានអនុម័តិ និងបានអនុវត្តគោលនយោបាយ ប.ក.ក ដើម្បីបោសសម្អាតអ្នកដែលគេហៅថា «ខ្មាំង» ពីក្នុងជួរនៃកងទ័ពបដិវត្តន៍កម្ពុជា ដោយការអនុវត្តការបោសសម្អាតជាប្រព័ន្ធលើកងពលធំ ១៦៤ របស់ខ្លួនឯងផ្ទាល់ តាមរយៈការកំណត់អត្តសញ្ញាណ ការចាប់ខ្លួន ការឃុំឃាំង ការធ្វើឲ្យទៅជាទាសសករ និងការសម្លាប់កម្មាភិបាលជាច្រើនដែលគេសង្ស័យថា មិនស្មោះត្រង់ចំពោះមេដឹកនាំ ប.ក.ក ។ មាស មុត ជាអ្នកដែលបានមើលការខុសត្រូវលើការដាក់ក្នុងមន្ទីរឃុំឃាំងនៃជនរងគ្រោះជាច្រើននាក់នៅក្នុងមន្ទីរឃុំឃាំងរបស់ខ្លួនផ្ទាល់នៃកងពលធំ១៦៤ រួមទាំងអ្នកនៅវត្តឥន្ទញ្ញាណក្នុងទីក្រុងកំពង់សោម វត្តទឹកសាប និងស៊ឹងហាវ និងបានប្រគល់បុគ្គលិកកងពលធំ ១៦៤ យ៉ាងហោចណាស់ចំនួន ៦៧នាក់ទៅឲ្យមន្ទីរស-២១ ។ អ្នកដទៃជាច្រើនទៀតត្រូវបានធ្វើឲ្យទៅជាទាសករនៅតាមការដ្ឋានជាច្រើននៅក្នុងតំបន់ស្វយ័តកំពង់សោម ។

២) មន្ទីរសន្តិសុខវត្តឥន្ទញ្ញាណ គឺជាមន្ទីរឃុំឃាំងមួយដែលបានធ្វើប្រតិបត្តិការដោយកងពលធំ១៦៤ ដែលមានទីតាំងស្ថិតនៅចម្ងាយប្រហែលពីរគីឡូម៉ែត្រពីទីស្នាក់ការកងពលធំ និងផ្ទះរបស់ មាស មុត នៅក្នុងក្រុងកំពង់សោម ។ អតីតវត្តនេះត្រូវបានគេប្រើជាមន្ទីរឃុំឃាំង ដែលមានលក្ខណៈដ៏អមនុស្សធម៌បំផុត ការធ្វើទារុណកម្ម និងការសម្លាប់ ។ មានអ្នកទោសខ្លះមិនត្រូវបានគេសម្លាប់នៅនឹងកន្លែងទេ តែផ្ទុយទៅវិញត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខស-២១ ដើម្បីធ្វើទារុណកម្មបន្ថែម និងសម្លាប់ចោល ។

៣) មន្ទីរសន្តិសុខទឹកសាប គឺជាគុកទីពីរនៅក្នុងតំបន់ស្វយ័តកំពង់សោម ដែល មាស មុត និងអ្នកនៅក្រោមបង្គាប់របស់គាត់បានដាក់ទណ្ឌកម្មដល់អ្នកដែលមើលឃើញថាជា«ខ្មាំង»នៃរដ្ឋកម្ពុជាប្រជាធិបតេយ្យ ។ បុគ្គលិកយោធា និងប្រជាជនស៊ីវិល ត្រូវបានគេដាក់ឲ្យទៅជាទាសករនៅក្នុងសហករណ៍ជិតខាងនោះ អតីតមន្ត្រីរដ្ឋការ លន់ នល់ និងពួកជនបរទេសដែលត្រូវបានចាប់ខ្លួននៅតាមសមុទ្រ ត្រូវបានដាក់ក្នុងមន្ទីរឃុំឃាំង ស្ថិតនៅក្រោមលក្ខខណ្ឌអមនុស្សធម៌ ការធ្វើទារុណកម្ម និងត្រូវបានសម្លាប់ចោល ។ ជនរងគ្រោះជាច្រើនដែលបានយកទៅកាន់ទឹកសាបគឺត្រូវបានសម្លាប់ចោលនៅពេលទៅដល់កន្លែងនោះ ។ សាកសពរាប់រយនាក់ត្រូវបានគេឃើញនៅទីជិតខាងមន្ទីរសន្តិសុខនោះ នៅក្រោយរបបកម្ពុជាប្រជាធិបតេយ្យ ដែលជាច្រើនបានកប់នៅក្នុងរណ្តៅរាក់ៗ នៅក្រោមដើមទុរេន និងដើមស្វាយម៉ាវ ។

៤) ការដ្ឋានពលកម្មនៅស៊ឹងហាវៈ គឺជាបណ្តុំការដ្ឋានពលកម្ម និងឧបករណ៍សម្រួលពាក់ព័ន្ធ ដែលបានដំណើរការដោយកងពល ១៦៤ នៅភាគខាងជើងនៃតំបន់កំពង់សោម ។ នៅតាមទីកន្លែង

ទាំងនេះ មាស មុត និងអ្នកនៅក្រោមបង្គាប់បានបង្ខំពួកទាហានរំសាយនៃកងពល១៦៤ ឲ្យធ្វើការរហូតដល់បាក់កម្លាំងនៅក្នុងលក្ខខណ្ឌអមនុស្សធម៌ ដែលមានតម្លៃស្មើនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើឲ្យទៅជាទាសករ ។ កម្មករទាំងនេះបានរស់នៅក្រោមការគំរាមកំហែងជាប់ជាប្រចាំ ដោយការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម និងការសម្លាប់ចោលនៅតាមគុកមូលដ្ឋានដែលជាមន្ទីរសន្តិសុខមួយក្នុងចំណោមមន្ទីរសន្តិសុខដទៃទៀតនៅកំពង់សោម ឬមួយនៅក្នុងករណីខ្លះទៀតគឺនៅ ស-២១ ។

៥) ការដ្ឋានពលកម្មនៅតំបន់រាមៈ គឺជាតំបន់ផលិតកម្មកសិផលចម្បង នៅក្រោមការត្រួតត្រារបស់ មាស មុត ដែលពួកទាហានរំសាយ និងប្រជាជនស៊ីវិល ត្រូវបានដាក់ឲ្យទៅជាទាសករនៅក្រោមលក្ខខណ្ឌអមនុស្សធម៌ ក្នុងគោលបំណងដើម្បីឲ្យធ្វើស្រែចម្ការសម្រាប់របបកម្ពុជាប្រជាធិបតេយ្យ និងសាងសង់ប្រព័ន្ធស្រោចស្រពទឹក (ឧទាហរណ៍ ទំនប់ ព្រែកជីក) ។ អ្នកធ្វើការត្រូវបានចាប់ខ្លួនដោយសារ "កំហុស" បន្តិចបន្តួចដែលគេបានមើលឃើញ ហើយនិង ឬមួយត្រូវបានសម្លាប់ចោលនៅទីកន្លែងសម្លាប់មួយនៅក្បែរនោះ ឬមន្ទីរសន្តិសុខ ស-២១ ។

៦) ការបោសសម្អាតកងពល១១៧ និងតំបន់៥០៥ៈ មាស មុត ត្រូវបានចាត់តាំងដោយមេដឹកនាំ ប.ក.ក ឲ្យទទួលខុសត្រូវលើកងពល១១៧ និង តំបន់៥០៥ (ខេត្តក្រចេះ) នៅខែវិច្ឆិកា ឆ្នាំ១៩៧៨ ។ គាត់បានបោសសម្អាតកងពល និងមេដឹកនាំតំបន់ពីមុន ដោយបានបញ្ជូនពួកនោះភាគច្រើនទៅកាន់ស-២១ ដែលជាកន្លែងពួកគាត់ត្រូវបានគេធ្វើទារុណកម្ម និងសម្លាប់ចោល ។ ក្រោយមក មាស មុត បានចាត់តាំងមេបញ្ជាការកងវរៈសេនាធំនៃកងពល១៦៤ របស់គាត់ ធ្វើជាលេខាទាំងកងពល និងតំបន់ ហើយបាននាំយកនូវកងទ័ពកងពល១៦៤ ទៅកាន់ទីកន្លែងនោះ ។ កងកម្លាំងរបស់ មាស មុត បានបន្តបោសសម្អាតពួកថ្នាក់ក្រោម រួមមានប្រធានឃុំនៃតំបន់៥០៥ ប្រជាជនស៊ីវិល និងពួកយុទ្ធជនកងពល១១៧ ។ មាស មុត ក៏បានបន្តការវាយប្រហារប្រល័យពូជសាសន៍ផងដែរ ប្រឆាំងនឹងជនជាតិវៀតណាម ដោយបានបញ្ជូនជនជាតិវៀតណាមដែលបានចាប់ខ្លួននៅក្រចេះទៅកាន់ ស-២១ ។

៧) ការបោសសម្អាតកងពលនៃកងទ័ពបដិវត្តន៍កម្ពុជាដទៃទៀតៈ មាស មុត បានសម្របសម្រួលជាមួយនឹងអគ្គសេនាធិការមេបញ្ជាការកងពលមជ្ឈិម និងកងវរៈសេនាធំឯករាជ ដើម្បីអនុវត្តផែនការឧក្រិដ្ឋបោសសម្អាតកងទ័ពបដិវត្តន៍កម្ពុជា ដោយការចាប់ខ្លួន ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម និងការសម្លាប់សមាជិកកងពលមជ្ឈិម និងកងវរសេនាធំឯករាជ្យនៃកងទ័ពបដិវត្តន៍កម្ពុជាដែលត្រូវបានសង្ស័យថាជាជនក្បត់ ឬបើពុំនោះទេ ថាជាខ្មាំងរបស់ ប.ក.ក ដោយពុំមានកិច្ចដំណើរការនីតិវិធីតាមច្បាប់ណាមួយឡើយ ។ មាស មុត បានអនុវត្តផែនការនោះនៅតាមការប្រជុំយោធានានា និងអនុវត្តវានៅក្នុងតំបន់ផ្ទាល់ខ្លួនរបស់គាត់ ។ ក្នុងឋានៈជាអ្នកចូលរួមចំណែកដ៏សំខាន់ក្នុងសហឧក្រិដ្ឋកម្មរួមនេះ មាស មុត មានការទទួលខុសត្រូវចំពោះអ្នកទោសនៃកងទ័ពបដិវត្តន៍កម្ពុជាដទៃទៀត ជាង ៤.៨០០ នាក់ បន្ថែមទៅលើពួកដែលមកពីកងពល១៦៤ និង១១៧ ផង ដែលត្រូវបានបញ្ជូនទៅកាន់ ស-២១ ។

៨) ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តប្រឆាំងនឹងពួកជនដែលត្រូវបានចាប់ខ្លួន ដោយកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យនៅក្នុងសមុទ្រ និងនៅតាមកោះដែលបានអះអាងដោយកម្ពុជាប្រជាធិបតេយ្យៈ ក្នុងឋានៈជាមេបញ្ជាការកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ មាស មុត បានចូលរួមយ៉ាងសកម្មនៅក្នុងការផ្តោតគោលដៅទៅលើការចាប់ខ្លួន ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម និងការសម្លាប់ជនរងគ្រោះរាប់ពាន់នាក់ រួមមានជនជាតិវៀតណាម ថៃ និងជនបរទេសដទៃទៀត ដែលត្រូវបានចាប់ខ្លួននៅក្នុងសមុទ្រឆ្ងាយពីកោះនៃប្រទេសកម្ពុជា និងនៅលើកោះរបស់ខ្លួន ។ ការសម្លាប់បានកើតឡើងនៅតាមសមុទ្រ ឬនៅតាមកោះរបស់កម្ពុជាណាមួយ នៅតាមចម្ការទុរេន ឬចម្ការដូងណាមួយ នៅក្នុងតំបន់ស្វយ័តកំពង់សោម ឬមួយក៏នៅមន្ទីរ ស-២១ ។

សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាអន្តរជាតិ បានអះអាងបន្ថែមទៀតថា ភ័ស្តុតាងបង្ហាញអំពីការទទួលខុសត្រូវខាងព្រហ្មទណ្ឌរបស់ មាស មុត ចំពោះអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈនៅតំបន់ស្វយ័តកំពង់សោម និងចំពោះអំពើប្រល័យពូជសាសន៍នៃជនជាតិវៀតណាម នៅពាសពេញតំបន់ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់គាត់ ។ ជាពិសេស ភ័ស្តុតាងបង្ហាញថាៈ

១) អាពាហ៍ពិពាហ៍ដោយដោយបង្ខំ និងការរំលោភសេព

សន្តវៈ ៖ ក្នុងតំបន់ស្វយ័តកំពង់សោម មាស មុត និងអ្នកក្រោមបង្គាប់របស់គាត់បានអនុវត្តគោលនយោបាយ ប.ក.ក ដោយបង្ខំមនុស្សឲ្យរៀបអាពាហ៍ពិពាហ៍ និងបង្ខំជនរងគ្រោះឲ្យរួមសង្វាសនៅក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំ ដោយពុំមានការយល់ព្រមដោយសេរីរបស់ពួកគេនោះឡើយ ដែលបង្កើតបានជាការរំលោភសេពសន្ថវៈ ។ គូស្រករជាច្រើនមិនបានទទួលនូវការជូនដំណឹងជាមុនពីការផ្សំផ្គុំដែលជិតកើតមានឡើងនេះទេ ឬបានទទួលដ៏តិចតួចបំផុត ហើយស្ត្រីមួយចំនួនត្រូវបានបង្ខំឲ្យរៀបអាពាហ៍ពិពាហ៍ជាមួយនឹងបុរស ដែលបានជ្រើសរើសដោយរបបនេះ ដែលជួនកាលជាយុទ្ធជនពិការដែលពួកគាត់មិនធ្លាប់បានឃើញពីមុន ។ មាស មុត ក៏បានដាក់ឲ្យអនុវត្តផងដែរនូវវិធាន ដែលថាគូស្រករថ្មីត្រូវរួមដំណេកជាមួយគ្នាដើម្បីបង្កើតកូន ។ បន្ទាប់ពីពិធីរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ "គូស្រករថ្មី" ជាញឹកញាប់ ត្រូវបានតាមដានមើលដោយអ្នកនៅក្រោមបង្គាប់របស់ មាស មុត ដើម្បីឲ្យប្រាកដថា ពួកគេបានរួមសង្វាសជាមួយគ្នា ដែលបង្ខំឲ្យទាំងបុរស ទាំងស្ត្រីរួមភេទជាមួយគ្នាដោយពុំមានការយល់ព្រមដោយសេរីរបស់ដៃគូម្នាក់ ឬទាំងពីរនាក់ឡើយ ។ ការបង្ខំឲ្យមនុស្សពាក់ព័ន្ធក្នុងទំនាក់ទំនងផ្លូវភេទដោយគ្មានការយល់ព្រមដោយសេរី ឬមិនអាចធ្វើបានត្រូវបានចាត់ទុកថាជាអំពើរំលោភសេពសន្ថវៈ ហើយនៅក្នុងទស្សនៈរបស់សហព្រះរាជអាជ្ញាអន្តរជាតិ មាស មុត និងអ្នកនៅក្រោមបង្គាប់របស់គាត់ បានប្រព្រឹត្តនូវឧក្រិដ្ឋកម្មនេះ ។

(២) អំពើប្រល័យពូជសាសន៍លើជនជាតិវៀតណាមៈ ថ្នាក់ដឹកនាំ ប.ក.ក បានចាត់ចែងឲ្យមានការបោសសម្អាតក្រុមជាតិពន្ធុវៀតណាមឲ្យអស់ទាំងស្រុងពីកម្ពុជាប្រជាធិបតេយ្យ ដោយជាដំបូងភាគច្រើនតាមរយៈការបញ្ជូនខ្លួនអ្នកទាំងនោះឲ្យវិលត្រឡប់ទៅកាន់ប្រទេសវៀតណាមវិញ និងនៅឆ្នាំ១៩៧៧ ដោយការសម្លាប់ជនជាតិវៀតណាមទាំងអស់ដែលនៅសេសសល់ក្នុងប្រទេសកម្ពុជា ។ យុទ្ធនាការនៃអំពើប្រល័យពូជសាសន៍ ដោយការសម្លាប់នានារួមមាន ការសម្លាប់អ្នកនេសាទស៊ីវិលជាច្រើននាក់ និងជនភៀសខ្លួនដែលត្រូវបានចាប់នៅឯសមុទ្រដោយកងកម្លាំងជើងទឹករបស់ មាស មុត ។ នៅចន្លោះឆ្នាំ១៩៧៥ និង ១៩៧៩ មាស មុត បានចេញបញ្ជាថា អ្នកទោសវៀតណាមដែលបានចាប់ខ្លួននៅឯសមុទ្រត្រូវសម្លាប់ចោលនៅនឹងកន្លែង ឬត្រូវយកមកដីគោក និងបញ្ជូនទៅសម្លាប់ចោល ។ មិនដូចជាពួកអ្នកទោសថៃនោះទេ ដែលជីវិតរបស់ពួកគេនៅពេលខ្លះអាចត្រូវបានចរចាសម្រាប់កន្លែងណាដែលកម្ពុជាប្រជាធិបតេយ្យមើលឃើញថាជាផលចំណេញខាងសេដ្ឋកិច្ចក្នុងការធ្វើដូច្នោះ ការស្លាប់យ៉ាងជាក់លាក់ដែលបានកំណត់ឲ្យពួកវៀតណាមដែលត្រូវបានចាប់ខ្លួននៅឯសមុទ្រ ឬដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ មាស មុត នៅខេត្តក្រចេះ បញ្ជាក់ឲ្យឃើញថា ពួកគេត្រូវបានសម្លាប់ដោយសារតែពួកគេគ្រាន់តែជាជនជាតិវៀតណាមប៉ុណ្ណោះ ។

ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិមានចំនួន៣២០ទំព័រ ដែលជាការវិភាគលើអង្គសេចក្តីអមដោយកំណត់សម្គាល់ចុងអត្ថបទចំនួនជាង៤២០០ ដែលលើកយោងភស្តុតាងដែលប្រមូលបាននៅក្នុងអំឡុងនៃកិច្ចស៊ើបសួរ ។ ភស្តុតាងនេះមានចំនួនប្រមាណជា ៧.០០០ ឯកសារ និងសម្ភារសោតទស្សន៍ ដោយរួមបញ្ចូលទាំងកំណត់ហេតុនៃការស្តាប់ចម្លើយប្រមាណជា ១.០០០ ឯកសារ, ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលបានដាក់នៅក្នុងសំណុំរឿង០០៣ ប្រមាណជា ៦៥០ និងឯកសារសហការ ប.ក.ក និងកម្ពុជាប្រជាធិបតេយ្យជាច្រើន បញ្ជីអ្នកទោស ស-២១ បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា, ប្រតិចារឹកសវនាការពីសំណុំរឿង០០១, ០០២/០១ និង០០២/០២ រូបថត ផែនទី សៀវភៅ និងអត្ថបទសិក្សាស្រាវជ្រាវជាន់ខ្ពស់ជាច្រើន ។ សហព្រះរាជអាជ្ញាអន្តរជាតិមានបំណងស្នើសុំឲ្យសហចៅក្រមស៊ើបអង្កេតដាក់ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា និងចម្លើយតបរបស់មេធាវីការពារក្តីទៅនឹងសារណាទាំងនោះជាសាធារណៈ នៅក្រោយពេលមានការកោសលុបសមស្របដើម្បីការពារសន្តិសុខ និងសិទ្ធិជាឯកជនរបស់សាក្សី និងជនរងគ្រោះ ។

សូមរម្លឹកចំពោះអ្នកអានថា គ្រប់ជនសង្ស័យ និងជនត្រូវចោទ ឬបុគ្គលដែលបានបញ្ជូនទៅជំនុំជម្រះទាំងអស់ គឺត្រូវបានសន្មតថាគ្មានទោស លើកលែងតែ និងរហូតទាល់តែពិរុទ្ធភាពរបស់ពួកគាត់ត្រូវបានបង្ហាញសក្ខីកម្មឲ្យហួសពីវិមតិសង្ស័យ នៅក្នុងតុលាការ និងត្រូវបានតម្កល់ដោយបណ្តឹងសាទុក្ខណាមួយ ។

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

# សេចក្តីថ្លែងការណ៍របស់ការិយាល័យសហព្រះរាជអាជ្ញាជាតិ ស្តីពីសំណុំរឿង០០៣

នៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៧ សហព្រះរាជអាជ្ញាបានដាក់ដីកាសន្និដ្ឋានស្ថាពររបស់ខ្លួន ក្នុងសំណុំរឿង០០៣ ពាក់ព័ន្ធនឹងកិច្ចស៊ើបសួរលើ មាស មុត ។ វិធានផ្ទៃក្នុងសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចែងថា ខណៈដែលដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាត្រូវបានដាក់ជាការសម្ងាត់ក៏ដោយ ក៏សហព្រះរាជអាជ្ញា អាចបញ្ចេញនូវសេចក្តីសង្ខេបអំពីគោលបំណងនៃសេចក្តីសន្និដ្ឋានរបស់ខ្លួន ជូនសាធារណជនបានដែរ ។ដើម្បីតម្លាភាពជាប្រយោជន៍ដល់សាធារណៈ សហព្រះរាជអាជ្ញាសូមផ្តល់ជូននូវសេចក្តីសង្ខេបព័ត៌មានដូចខាងក្រោម ដែលមាននៅក្នុងដីកាសន្និដ្ឋានស្ថាពររបស់ខ្លួន ទាក់ទងនឹងកិច្ចស៊ើបសួរក្នុងសំណុំរឿង មាស មុត ។ សូមអ្នកអានជ្រាបថា សេចក្តីសង្ខេបខាងក្រោមនេះ មិនរាប់បញ្ចូលទស្សនៈរបស់មេធាវីការពារក្តី ហើយក៏មិនមែនមានចេតនាឆ្លុះបញ្ចាំងអំពីទស្សនៈរបស់សហចៅក្រមស៊ើបអង្កេត(សចស) ដែរ ដោយសារពួកគាត់នឹងធ្វើការកំណត់លើបញ្ហាទាំងអស់នេះដោយពួកគាត់ផ្ទាល់ ។

ដីកាសន្និដ្ឋានស្ថាពរត្រូវបានចេញដោយសហព្រះរាជអាជ្ញានៅពេលបិទកិច្ចស៊ើបសួរ ។ ក្នុងដីកាសន្និដ្ឋានស្ថាពរ សហព្រះរាជអាជ្ញាអាចស្នើឲ្យ សចស បញ្ជូនជនត្រូវចោទទៅជំនុំជម្រះ ឬលើកលែងការចោទប្រកាន់នៅក្នុងសំណុំរឿងនោះ ។

សហព្រះរាជអាជ្ញាជាតិ និងអន្តរជាតិបានដាក់ដីកាសន្និដ្ឋានស្ថាពរដាច់ដោយឡែកពីគ្នាដែលឆ្លុះបញ្ចាំងពីទស្សនៈខុសគ្នាអំពីថាតើ គួរស្នើសុំឲ្យ សចស ចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬលើកលែងចោទប្រកាន់ ។ មេធាវីការពារក្តី មាស មុត ឥឡូវនេះនឹងមានឱកាសឆ្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពរទាំងនេះជាមួយនឹងទស្សនៈរបស់ខ្លួនអំពីច្បាប់ និងភស្តុតាង ។ បន្ទាប់មក វាអាស្រ័យលើសហចៅក្រមស៊ើបអង្កេតដែលនឹងត្រូវសម្រេចថាតើ មាស មុត ត្រូវដាក់ឲ្យស្ថិតនៅក្រោមយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ឬយ៉ាងណា និងថាតើការស៊ើបអង្កេតនេះបានបង្ហាញឲ្យឃើញអំពី



អង្គជំនុំជម្រះសាលាដំបូង (រូបថត ៖ អ.វ.ត.ក)

ការទទួលខុសត្រូវរបស់គាត់ ចំពោះឧក្រិដ្ឋកម្មនានាដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ដល់បទដ្ឋានដែលតម្រូវដើម្បីចោទប្រកាន់គាត់ និងបញ្ជូនខ្លួនគាត់ទៅជំនុំជម្រះ ឬយ៉ាងណា ។ ដូចគ្នាទៅនឹងជនត្រូវចោទ និងជនជាប់ចោទទាំងអស់នៅ អ.វ.ត.ក ដែរ មាស មុត នៅតែរក្សាការសន្មតថាគ្មានទោសដដែលរហូតមកដល់ពេលនេះ ដរាបណា ឬនៅពេលណាដែលពិរុទ្ធភាពរបស់គាត់ត្រូវបានរកឃើញនៅពេលសវនាការ និងត្រូវបានតម្កល់តាមរយៈបណ្តឹងសាទុក្ខណាមួយ ។

សហព្រះរាជអាជ្ញាជាតិមានជំហរតាំងពីដើមរៀងរហូតមកថា គឺមានតែជនជាប់ចោទដែលមានស្រាប់នៅ អ.វ.ត.ក ដែលជាមេដឹកនាំជាន់ខ្ពស់ និងជាអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះបទឧក្រិដ្ឋនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យប៉ុណ្ណោះ ដែលស្ថិតក្នុងយុត្តាធិការបុគ្គលនៃ អ.វ.ត.ក ។ តាមរយៈការយល់ឃើញនេះទើបសហព្រះរាជអាជ្ញាជាតិ មិនត្រឹមតែមិនចូលរួមក្នុងកិច្ចនីតិវិធីស៊ើបអង្កេតបឋមរបស់ការិយាល័យសហព្រះរាជអាជ្ញា និងកិច្ចនីតិវិធីស៊ើបអង្កេតរបស់ការិយាល័យចៅក្រមស៊ើបសួរប៉ុណ្ណោះទេ ថែមទាំងលើកការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញាជាតិ និងសហព្រះរាជអាជ្ញាអន្តរជាតិ ស្របតាមវិធានផ្ទៃក្នុងនៃ អ.វ.ត.ក នៅគ្រប់ដំណាក់កាល ។

សហព្រះរាជអាជ្ញាជាតិកត់សម្គាល់ឃើញថា អ.វ.ត.ក គួរតែផ្តល់អាទិភាពទៅលើការវិនិច្ឆ័យទោសជនជាប់ចោទទាំងនេះ ដើម្បីបំពេញឲ្យបានគ្រប់គ្រាន់ចំពោះអាណត្តិរបស់ខ្លួន ព្រោះថាច្បាប់ អ.វ.ត.ក និងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាបានគិតទុកជាមុនរួចហើយ អំពីការវិនិច្ឆ័យទោស ដែលត្រូវធ្វើតែទៅលើបុគ្គលមួយចំនួនតូចប៉ុណ្ណោះ ។

សហព្រះរាជអាជ្ញាជាតិពិនិត្យឃើញថា តាមរយៈបុព្វកថានៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជ រដ្ឋាភិបាលកម្ពុជាដែលបានអនុមតក្នុងសេចក្តីសម្រេចចិត្តលេខៈ៥៧.២២៨ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០២ របស់មហាសន្និបាតអង្គការសហប្រជាជាតិ ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើង នៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ អង្គការសហប្រជាជាតិបានទទួលស្គាល់យ៉ាងជាក់លាក់អំពីការព្រួយបារម្ភពេញច្បាប់របស់រាជរដ្ឋាភិបាល និងប្រជាជនកម្ពុជាក្នុងការស្វែងរកយុត្តិធម៌ ការបង្រួបបង្រួមជាតិ ស្ថេរភាព សន្តិភាព និងសន្តិសុខ ។ ផ្តើមចេញពីការទទួលស្គាល់នេះ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា បានតម្រូវឲ្យសហព្រះរាជអាជ្ញា ជ្រើសរើសយកបុគ្គលតែពីរប្រភេទប៉ុណ្ណោះមកធ្វើការវិនិច្ឆ័យសេចក្តី គឺមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិ និងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ ១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ ។

សហព្រះរាជអាជ្ញាជាតិយល់ឃើញថា វានឹងមិនបម្រើផលប្រយោជន៍នៃយុត្តិធម៌ទេ ក្នុងការបញ្ជូនបុគ្គល មាស មុត ទៅជំនុំជម្រះ ប្រសិនបើការចោទប្រកាន់ទៅលើរូបគាត់នោះ នឹងបង្កក់ដល់នយោបាយក្នុងស្រុក និងបណ្តាលឲ្យមានចលាចលជាសក្តានុពលយ៉ាងធ្ងន់ធ្ងរនោះ ។

ហេតុដូច្នេះ សហព្រះរាជអាជ្ញាជាតិប្រកាន់ជំហរថា យោងតាមបទប្បញ្ញត្តិនៃច្បាប់បង្កើត អ.វ.ត.ក និងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាដែលបានបង្កើតតុលាការនេះ គឺ មាស មុត ដែលមានឈ្មោះនៅក្នុងសំណុំរឿងលេខ០០៣ មិនស្ថិតនៅក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ឡើយ ។

សូមរំលឹកចំពោះសាធារណជនថា គ្រប់ជនសង្ស័យ និងជនត្រូវចោទ ឬបុគ្គលដែលបានបញ្ជូនទៅជំនុំជម្រះទាំងអស់ គឺត្រូវបានសន្មតថាគ្មានទោស លើកលែងតែ និងរហូតទាល់តែពិរុទ្ធភាពរបស់ពួកគាត់ត្រូវបានបង្ហាញសក្ខីកម្មឲ្យហួសពីវិមតិសង្ស័យនៅក្នុងតុលាការ និងត្រូវបានតម្កល់ដោយបណ្តឹងឧទ្ធរណ៍ណាមួយ ។ វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ អនុលោមតាមមាត្រា៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

# មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងទទួលបានការលើកទឹកចិត្តទាក់ទងការងារអភិវឌ្ឍស្រុកអន្លង់វែង

អស់រយៈពេលប្រាំពីរឆ្នាំមកហើយ ដែលមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ជាគម្រោងមួយរបស់មជ្ឈមណ្ឌលឯកកម្ពុជាបានសហការជាមួយក្រសួងទេសចរណ៍តាមរយៈអនុក្រឹតអនុញ្ញាតពីរាជរដ្ឋាភិបាលកម្ពុជាបង្កើតគណៈកម្មាធិការអន្តរក្រសួងដើម្បីធ្វើការស្រាវជ្រាវចងក្រង និងសរសេរសៀវភៅប្រវត្តិសាស្រ្តសម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍ក្នុងសហគមន៍អន្លង់វែង ។ តាមរយៈអនុក្រឹតនេះ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ក៏មានតួនាទីរួមចំណែកក្នុងអភិវឌ្ឍន៍ និងអភិរក្សតំបន់ប្រវត្តិសាស្រ្តទាំង១៤កន្លែង នៅស្រុកអន្លង់វែង ដែលជាតំបន់តស៊ូចុងក្រោយរបស់ខ្មែរក្រហមដែរ ។

ជាមួយកិច្ចការដែលបានធ្វើកន្លងមក ក្រុមការងាររបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានចុះជួបអ្នកភូមិក្នុងសហគមន៍ និងបានធ្វើការសម្ភាសប្រជាជនពីបទពិសោធន៍ផ្ទាល់ខ្លួន រឿងរ៉ាវដែលបានកើតឡើងនៅក្នុងតំបន់អន្លង់វែង ។ ក្រុមការងារក៏បានធ្វើការសម្ភាសអតីតយោធា កម្មាភិបាលខ្មែរក្រហមពីជីវិត តួនាទីការងារក្នុងអំឡុងពេលរបបខ្មែរក្រហមគ្រប់គ្រង និងបានសរសេរសៀវភៅប្រវត្តិសាស្រ្តសម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍ ដែលមានចំណងជើងថា "ប្រវត្តិសាស្រ្តសហគមន៍អន្លង់វែង" តំបន់កាន់កាប់ចុងក្រោយរបស់ចលនាខ្មែរក្រហម ។ ក្រៅពីកិច្ចការសរសេរសៀវភៅ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ក៏បានធ្វើការជួសជុលអតីតទីបញ្ជាការរបស់ តាម៉ុក នៅលើភ្នំដងរែក ដែលត្រូវភ្លើងឆេះ ការសាងសង់តូបយាមនៅផ្លូវ ប៉ុល ពត ការដាក់តាំងពិព័ណ៌រូបថតនិងកាលប្បវត្តិខ្មែរក្រហមនៅអតីតផ្ទះ តាម៉ុក និងការដំឡើងស្លាកសញ្ញាសម្គាល់នៅទីតាំងប្រវត្តិសាស្រ្តទាំង១៤កន្លែង ក្នុងស្រុកអន្លង់វែង ដែលមានដូចជា កន្លែងដុតខ្មោច ប៉ុល ពត, កន្លែងកាត់ទោស ប៉ុល ពត, ផ្ទះកណ្តាលលើភ្នំដងរែក្ស កន្លែងកែច្នៃគ្រាប់លើភ្នំ ២០០, ផ្ទះ ប៉ុល ពត និង ខៀវ សំផន, ឃ្លាំងដាក់សម្ភារនៅជើងភ្នំ,



សិក្ខាសាលាបូកសរុបការងារស្តីពី "ការប្រឡងប្រណាំងរមណីយដ្ឋានទីក្រុងគំរូ" នៅសណ្ឋាគារភ្នំពេញ ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៧ ក្រោមអធិបតីភាពឯកឧត្តម ថោង ខុន រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ហើយក្នុងឱកាសនោះ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ដឹកនាំដោយបណ្ឌិត លី សុខឃាង នងជាតំណាងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ក៏ត្រូវបានអញ្ជើញឲ្យចូលរួមជាវាគ្មិនបង្ហាញពី "បទពិសោធន៍នៃការអភិវឌ្ឍន៍រមណីយដ្ឋានទេសចរណ៍ប្រវត្តិសាស្រ្តអន្លង់វែង" ដែរ ។

កន្លែងដុតខ្មោច សុន សេន, ស្រែគំរូ, ទីតាំងការដ្ឋានដឹកជញ្ជូនរបស់តាម៉ុក, បឹងអន្លង់វែង, សារមន្ទីរ តាម៉ុក, អតីតទីតាំងមន្ទីរពេទ្យតាម៉ុក្ស អតីតទីតាំងសាលារៀន តាម៉ុក ។

ជាមួយផែនការ និងទស្សនវិស័យរបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងដែលបានធ្វើ មិនត្រឹមតែចូលរួមថែរក្សា និងអភិរក្សតំបន់ប្រវត្តិសាស្ត្រអន្លង់វែងប៉ុណ្ណោះទេ ប៉ុន្តែមជ្ឈមណ្ឌលនេះ ក៏បានរៀបចំឲ្យមានដំណើរទស្សកិច្ចសិក្សាស្តីពីសន្តិភាព និងការផ្សះផ្សានៅក្នុងតំបន់អន្លង់វែង ។ ដោយសារតំបន់អន្លង់វែង ជាតំបន់ដែលធ្លាប់តែមានការប្រយុទ្ធគ្នា អំពើហិង្សា ការឈឺចាប់ និងគ្រប់គ្រងដោយអតីតយោធាខ្មែរក្រហម ទើបធ្វើឲ្យប្រជាជនមានទស្សនយល់ឃើញផ្សេងគ្នាលើប្រវត្តិសាស្ត្រក្នុងតំបន់នេះ និងធ្វើឲ្យមានគម្លាតគ្នាកាន់តែឆ្ងាយរវាងអតីតខ្មែរក្រហម និងជនរងគ្រោះពីរបបនេះ ។ ដើម្បីបង្កើតឲ្យមានការសន្ទនាកិច្ចគ្នាក្នុងចំណោមប្រជាជន និងស្វែងយល់ឲ្យកាន់តែស៊ីជម្រៅពីតំបន់អន្លង់វែងនេះ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានសហការជាមួយអាជ្ញាធរមូលដ្ឋាន និងក្រសួងអប់រំ យុវជន និងកីឡា រៀបចំដំណើរទស្សកិច្ចសិក្សាសម្រាប់សិស្ស និស្សិត មកពីសាកលវិទ្យាល័យនានានៅទូទាំងប្រទេសកម្ពុជា ឲ្យមកទស្សកិច្ចសិក្សានៅស្រុកអន្លង់វែង ជារៀងរាល់ខែ ។ ក្នុងចំណោមសិស្ស និស្សិតទាំងនោះក៏មានកូនរបស់អតីតជនដៃដល់ និងកូនរងគ្រោះពីរបបខ្មែរក្រហមដែរ ។ បន្ទាប់ពីស្តាប់វាគ្មិនធ្វើបទបង្ហាញដោយសង្ខេបពីតំបន់អន្លង់វែង សិស្សនិស្សិតទាំងនោះ បានចុះទៅជួប និងសួរនាំប្រជាជនក្នុងសហគមន៍អន្លង់វែង ពីបទពិសោធន៍របស់ប្រជាជនទាំងនោះក្នុងរបបខ្មែរក្រហម ។ សិស្សនិស្សិតមិនត្រឹមដឹងរឿងផ្ទាល់ខ្លួនរបស់មនុស្សម្នាក់ៗប៉ុណ្ណោះទេ ប៉ុន្តែក៏បានដឹងពីប្រវត្តិអន្លង់ដែរ ។ ចំណេះដឹងទាំងនេះមានសារសំខាន់ណាស់សម្រាប់សិស្ស និស្សិត ក្នុងការចូលរួមថែរក្សាប្រវត្តិសាស្ត្រក្នុងសហគមន៍អន្លង់វែង និងក្នុងដំណើរការផ្សះផ្សាជាតិទាំងមូល ។

ភ្ជាប់ជាមួយកិច្ចខាងលើ មកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងក៏បានសហការជាមួយក្រសួងទេសចរណ៍ បានរៀបចំវគ្គបណ្តុះបណ្តាលដល់មគ្គុទ្ទេសទេសចរណ៍ពីតំបន់អន្លង់វែង ។ វគ្គបណ្តុះបណ្តាលនេះ បានជួយពង្រឹងសមត្ថភាពដល់មគ្គុទ្ទេសទេសចរណ៍ឲ្យយល់ដឹងកាន់តែស៊ីជម្រៅពីតំបន់អន្លង់វែង ដោយធានាថាព័ត៌មានដែលបានផ្តល់ទៅដល់ភ្ញៀវដែលបានមកទស្សនាតំបន់នេះមាន




រូបរាប់ពីឆ្វេង ៖ អ្នកស្រី ធិនទី មុនីរស្មី ប្រធានមន្ទីរទេសចរណ៍ ខេត្តឧត្តរមានជ័យ, បណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង, លោក ឈាង សុខហេង ប្រធានការិយាល័យទេសចរណ៍ ស្រុកអន្លង់វែង ទទួលបានជ័យលាភីរមណីយដ្ឋានទីក្រុងគំរូ និងលិខិតសរសើរពីឯកឧត្តម ថោង ខុន រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ក្នុងសិក្ខាសាលាបូកសរុបការងារស្តីពី "ការប្រឡងប្រណាំងរមណីយដ្ឋានទីក្រុងគំរូ" នៅសណ្ឋាគារភ្នំពេញ ។ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ

ភាពច្បាស់លាស់ និងអាចជឿទុកចិត្តបាន ។ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ក៏បានបង្កើតគេហទំព័ររបស់ខ្លួនដើម្បីផ្តល់ព័ត៌មាន និងបង្ហាញពីកិច្ចការប្រចាំថ្ងៃរបស់ខ្លួនទៅដល់សាធារណជនដែលមានចំណាប់អារម្មណ៍តំបន់អន្លង់វែងនេះ ។ ទន្ទឹមនេះ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងក៏បានបង្កើតប្លង់គោលដែលគូរដោយអ្នករចនាប្លង់ ដេវ៉ា កាង នៃក្រុមហ៊ុន ហ្សាហា ហាឌីត ជាក្រុមហ៊ុនដ៏ល្បីដែលមានមូលដ្ឋាននៅប្រទេសអង់គ្លេស ។ ប្លង់គោលនេះ បានគូសយ៉ាងលម្អិតទាក់ទងនឹងទីតាំងប្រវត្តិសាស្ត្រសំខាន់ៗ នៅក្នុងតំបន់អន្លង់វែង ជាមួយតំបន់ដែលត្រូវអភិវឌ្ឍថ្មី រួមមាន ៖ តំបន់រមណីយដ្ឋាន ផ្ទះសំណាក់ សណ្ឋាគារ តំបន់រោងចក្រ និងតំបន់ព្រៃធម្មជាតិ ។

ជាមួយកិច្ចការដែលមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងបានសម្រេចកន្លងមក នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៧ ក្រសួងទេសចរណ៍ បានអញ្ជើញបណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង និងជាតំណាងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ចូលរួមជាវាគ្មិនលើប្រធានបទ «បទពិសោធន៍នៃការអភិវឌ្ឍន៍រមណីយដ្ឋានទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែង» ក្នុងសិក្ខាសាលាបូកសរុបការងារស្តីពី «ការប្រឡងប្រណាំងរមណីយដ្ឋានទីក្រុងគំរូ» ក្នុងនាមជាដៃគូអភិវឌ្ឍន៍រួមជាមួយផ្នែកសាធារណ និងវិស័យឯកជនមួយចំនួន ក្រោមអធិបតីភាពរដ្ឋមន្ត្រីក្រសួងទេសចរណ៍ ឯកឧត្តម ថោង ខុន នៅសណ្ឋាគារភ្នំពេញ ។

ជាការកត់សម្គាល់នៅក្នុងសិក្ខាសាលានេះ ឯកឧត្តម ថោង ខុន មានប្រសាសន៍ថា វិស័យទេសចរណ៍នៅកម្ពុជា ជាវិស័យអទិភាព ដែលជួយកាត់បន្ថយភាពក្រីក្រ ភាពអត់ការងារធ្វើ និងជួយដល់ផ្នែកបរិស្ថាន ជាពិសេស បម្រែបម្រួលអាកាសធាតុ ។ ទន្ទឹមនេះ ភ្ញៀវទេសចរណ៍បានកើនឡើងជាបន្តបន្ទាប់ ដោយក្នុងឆ្នាំ២០១៧នេះ មានភ្ញៀវអន្តរជាតិ៥.៦លាននាក់ ហើយអាចនឹងកើនឡើងជាង៧លាននាក់ នៅឆ្នាំ២០២០ ខាងមុខ ។ ឯកឧត្តមបន្តថា សព្វថ្ងៃនេះ ប្រទេសកម្ពុជាមានរមណីយដ្ឋាន ប្រមាណ៤០០ កន្លែង រួមមាន រមណីយដ្ឋានបែបសណ្ឋាគារ រមណីយដ្ឋានបែបធម្មជាតិ និងរមណីដ្ឋានវប្បធម៌ និងប្រវត្តិសាស្ត្រ ដែលមានតម្លៃមិនអាចកាត់បាន ។ ឯកឧត្តម ថោង ខុន បានជំរុញឲ្យមានការរិតខំប្រឹងប្រែងអភិវឌ្ឍន៍វិស័យទេសចរណ៍ដែលមានធនធានដ៏សម្បូរបែបស្រាប់ រួមទាំង ជំរុញឲ្យមានការអភិវឌ្ឍន៍ធនធានមនុស្សវ័យក្មេង ។ ឯកឧត្តម ក៏បានអំពាវនាវឲ្យមានការសហការ និងវិនិយោគលើវិស័យទេសចរណ៍នេះ ពីផ្នែកសាធារណៈ វិស័យឯកជន និងដៃគូអភិវឌ្ឍន៍នានាដែរ ។

បន្ទាប់មក លោកបណ្ឌិត លី សុខឃាង បានធ្វើបទបង្ហាញដោយសង្ខេប ដល់អង្គសិក្ខាសាលាទាំងមូលស្តីពីប្រវត្តិសាស្ត្រតំបន់អន្លង់វែង ដែលជាតំបន់តស៊ូ និងជាតំបន់សមាហរណកម្មចុងក្រោយរបស់អតីតខ្មែរក្រហម នៅឆ្នាំ១៩៩៩ ។ លោកបានបន្តរយៈពេលបីឆ្នាំបន្ទាប់ពីការសមាហរណកម្ម រាជរដ្ឋាភិបាលកម្ពុជាបានចេញអនុក្រឹតប្រែក្លាយតំបន់អន្លង់វែងទៅជាតំបន់ប្រវត្តិសាស្ត្រ ហើយក្រោយមកបានកំណត់ទីតាំងប្រវត្តិសាស្ត្រសំខាន់ៗ នៅក្នុងតំបន់នេះដើម្បីអភិរក្ស ។ ដោយសារតំបន់អន្លង់វែងមានសក្តានុពលផ្នែកប្រវត្តិសាស្ត្រ នៅឆ្នាំ២០១០ គណៈកម្មាធិការអន្តរក្រសួងមួយត្រូវបានបង្កើតឡើងដឹកនាំដោយ ឯកឧត្តម ថោង ខុន ហើយក្នុងនាមមជ្ឈមណ្ឌលឯកសារជាសមាជិក បានធ្វើការចងក្រងសៀវភៅ «ប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង» តំបន់កាន់កាប់ចុងក្រោយរបស់ចលនាខ្មែរក្រហម និងបានបង្កើតជាសៀវភៅសម្រាប់បង្រៀនមគ្គុទ្ទេសក៍ទេសចរណ៍ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាក៏បានកែប្រែអតីតទីបញ្ជាការរបស់ តាម៉ុក នៅលើភ្នំដងរែកធ្វើជាការិយាល័យធ្វើការរបស់ខ្លួនដែលដាក់ឈ្មោះថា «មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង» ដើម្បីធ្វើការងារជួយដល់សហគមន៍ក្នុងតំបន់អន្លង់វែង ។ ក្រុមការងាររបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងក៏បានធ្វើការងារជាមួយនិស្សិតស្ថាបត្យកម្មដើម្បីរចនាប្លង់អន្លង់វែងតាមគំរូដើម និងសាងសង់ខ្ទមសម្រាប់ផ្តល់ព័ត៌មានដល់ភ្ញៀវទេសចរណ៍ ដំឡើងស្លាកសញ្ញាសម្គាល់ទីតាំងប្រវត្តិសាស្ត្រ និងបានសហការជាមួយក្រុមហ៊ុន ហ្សាហា ហាឌីត ដើម្បីគូរប្លង់គោលសម្រាប់ស្រុកអន្លង់វែងទាំង ។ នៅថ្ងៃខាងមុខមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង នឹងធ្វើការជាមួយក្រុមស្ថាបត្យកម្មដើម្បីសិក្សាបន្តលើប្លង់អភិវឌ្ឍពីស្រុកអន្លង់ រហូតទៅដល់អូរស្មាច់ ខេត្តឧត្តរមានជ័យ ។ បន្ទាប់មក លោក លី សុខឃាង បានបង្ហាញវីដេអូខ្លីអំពីប្លង់គោលស្រុកអន្លង់វែង ។ នៅក្នុងអំឡុងចូលរួមសិក្ខាសាលានេះ លោក លី សុខឃាង ក៏បានដាក់តាំងបង្ហាញប្លង់គោលសម្រាប់

អភិវឌ្ឍន៍សម្រាប់ស្រុកអន្លង់វែងដល់ភ្ញៀវទេសចរណ៍ដែរ ។

លោក ឈាង សុខហេង ប្រធានការិយាល័យទេសចរណ៍ស្រុកអន្លង់វែង ដែលបានចូលរួមសិក្ខាសាលាបូកសរុបការងារស្តីពី "ការប្រឡងប្រណាំងរមណីយដ្ឋានទីក្រុងគំរូ" បានមានប្រសាសន៍ថា កន្លងមក មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានជួយដល់សារមន្ទីររបស់គាត់ ដូចជា ជួយជុលផ្ទះដែលរងការខូចខាត បណ្តុះបណ្តាលមគ្គុទ្ទេសក៍ទេសចរណ៍ និងដាក់តាំងពិព័រណ៍រូបថតមួយចំនួន ។ លោកបានបន្តថា ជារៀងរាល់ខែ សារមន្ទីររបស់គាត់បានទទួលទេសចរណ៍ជាតិប្រមាណជិត១.០០០នាក់ ចំណែកភ្ញៀវអន្តរជាតិជាង១០០នាក់ ។ ថ្ងៃទៅខាងមុខ លោកសំណូមពរឲ្យមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងដាក់តាំងពិព័រណ៍ទៀតបន្ថែម ជាពិសេស ទាក់ទងនឹងរូបថតមេដឹកនាំខ្មែរក្រហម ។

អ្នកស្រី ធិនទី មុនីរស្មី ប្រធានមន្ទីរទេសចរណ៍ ខេត្តឧត្តរមានជ័យ ដែលបានចូលរួមសិក្ខាសាលាបូកសរុបការងារស្តីពី "ការប្រឡងប្រណាំងរមណីយដ្ឋានទីក្រុងគំរូ" បានមានប្រសាសន៍ថា មន្ទីររបស់ខ្លួន បានសហការជាមួយមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ដើម្បីអភិរក្សតំបន់ប្រវត្តិសាស្ត្រអន្លង់វែងទាំង១៨កន្លែង តែរហូតមកដល់ពេលនេះយើងធ្វើបានបីកន្លែងហើយ ។ អ្នកស្រីបន្តថា មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានធ្វើការជួលជួលផ្ទះរបស់ តាម៉ុក លើភ្នំដងរែកដើម្បីធ្វើជាការិយាល័យ ធ្វើការងារ ដាក់តាំងពិព័រណ៍រូបថត និងបណ្តុះបណ្តាលមគ្គុទ្ទេសក៍ទេសចរណ៍ ។ កន្លងមក ដោយសារមន្ទីរខ្វះខាតឯកសារពីតំបន់នេះ ដូច្នេះយើងក៏បានស្នើសុំមជ្ឈមណ្ឌលនេះដើម្បីធ្វើការស្រាវជ្រាវ និងបានសរសេរសៀវភៅប្រវត្តិសាស្ត្រមួយក្បាលសម្រាប់មគ្គុទ្ទេសក៍ទេសក៍ រួមទាំង ស្នើរូបថតមេដឹកនាំខ្មែរក្រហមមួយចំនួន ។ នៅខែធ្នូ ខាងមុខនេះ ក្រសួងនិងមន្ទីរទេសចរណ៍ខេត្ត នឹងរៀបចំសម្ភោធពិព័រណ៍នេះ ។ លោកស្រីបន្តថា ដោយសារតំបន់អន្លង់វែងជាអតីតតំបន់ដូច្នេះការរៀបចំត្រូវឲ្យស្របទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល ហើយលោកស្រីក៏សប្បាយរីករាយដែរដែលបានសហការជាមួយមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ។ លោកស្រីបានបញ្ជាក់ថា មន្ទីរទេសចរណ៍ខេត្តឧត្តរមានជ័យ បានស្នើដាក់រមណីយដ្ឋាន ផ្ទះតាម៉ុកជារមណីដ្ឋានគំរូសម្រាប់ខេត្តឧត្តរមានជ័យ ហើយនៅថ្ងៃនេះបានទទួលលិខិតសរសើរពីក្រសួងទេសចរណ៍ ។ នៅថ្ងៃខាងមុខ លោកស្រី នឹងរៀបចំបន្ទប់ទឹក និងអនាម័យនៅតាមរមណីយដ្ឋាននីមួយៗ និងសំណូមពរឲ្យមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងជួយបណ្តុះបណ្តាលធនធានមនុស្សថែមទៀត ។ **សោម ប៊ុនថន**



ភ្ញៀវទស្សនាប្លង់គោលស្រុកអន្លង់វែង គូរដោយក្រុមហ៊ុន ហ្សាហា ហាឌីត មានមូលដ្ឋាននៅប្រទេសអង់គ្លេស ដែលបានដាក់តាំងបង្ហាញនៅក្នុងសិក្ខាសាលាបូកសរុបការងារស្តីពី "ការប្រឡងប្រណាំងរមណីយដ្ឋានទីក្រុងគំរូ" នៅសណ្ឋាគារភ្នំពេញ ។

# ព្រលឹងមាសម្តាយ

## យប់មានដួងចន្ទ

យប់មួយនាដើមឆ្នាំ១៩៧០ ព្រះចន្ទរៀងរះជះកាំរស្មីពណ៌ប្រាក់ស្រទាប់ស្រទន់លើនភាល័យ បង្អួតសម្រស់ ប្រដែងនឹងផ្កាំងពពកសក្បុសដូចសំឡីដែលកំពុងហោះហើរ រសាត់អេរវិលវល់គ្មានឈប់ឈរ ក្រោមកម្លាំងវាយោខែមីនា ដែលច្រើនតែបក់បោកវិលវល់មិនទៀង ជួនមកពីទិសឦសាន្ត ជួនមកពីនិរតី ។

នៅតាមបណ្តាភូមិដ្ឋានស្រុកស្រែចម្ការ រាល់យប់ខែភ្លឺដូច្នេះ ស្នូរវ៉ោកវ៉ាកនៃត្បាល់កិនស្រូវ ស្នូរឌុកឌាក់ ង៉េតង៉តនៃត្បាល់ជាន់អង្ករ ស្នូរឆាចៗឈូរឆរនៃកម្លាំងចង្អេរអុំស្មៅរបស់ក្រុមយុវកសិករ កសិការិនីប្រគុំឡើងយ៉ាងសុខដុមរម្យនា ។ ពីនាយឆ្ងាយស្នូរសន្ទឹកជើងអង្រែប្រដេញគ្នាឮសន្ទឹក រសាត់ចូលសោតាអ្នកភូមិផងរបងជាមួយ ព្រមជាមួយនោះ ក្លិនប្រហើរឈ្ងុយឈ្ងប់នៃរសជាតិអំបុកស្រូវថ្មីគួរឲ្យរមួលប្រួលក្នុងពោះ ។ ម្អមវាលស្រែព័ទ្ធជុំវិញជើងភូមិក៏បញ្ចេញក្លិនពិដោរឈ្ងុយឈ្ងប់សាយភាពប្រាស់នឹងដំណក់សន្សើមរាត្រី ពុះជ្រែកលំហរវេហា ហាក់ចង់ហិចហោះផ្ងោះនភាល័យទៅថ្វាយពរជ័យដល់ដួងចន្ទពេញបូរមី ។ សូរសំឡេងរហាត់ទឹកឯវាលប្រាំងពីនាយជើងភូមិ លាយនឹងសំឡេងប្រវ៉ាក់ប៉ោតឯអណ្តូងទឹកក្នុងភូមិប្រគុំជាចង្វាក់ង៉េតៗ ថែមនឹងសព្ទសំឡេងហ្លួចដ៏ក្រលួចយ៉ាងពិរោះលន្លង់លន្លោចពោរពេញដោយក្តីសង្ឃឹមរបស់យុវកសិករ ។

ក្លិនទាំងនេះ ដក់ជាប់ក្នុងនាសាខ្ញុំ សូរសំឡេងទាំងនេះដក់ជាប់ក្នុងសោតាខ្ញុំ ខ្ញុំពោរពេញដោយអារម្មណ៍ជ្រះថ្លាពន់ពេក ខ្ញុំចង់តែសម្លឹងគយគន់ដួងចន្ទ្រា គន់ហើយ គន់ទៀត គន់មិនចង់ឈប់ ខ្ញុំជឿថា ខ្ញុំកំពុងរស់ក្នុងមោទកភាពជាតិខ្មែរ ខ្ញុំមានវាសនាបានកើតជាកូនខ្មែរ ជាពិសេសខ្ញុំជាកូនស្រីខ្មែរស្រុកស្រែចម្ការ ដែលមានឱកាសស្គាល់វិទ្យាល័យដូចអ្នកទីក្រុងដែរ ។ ខ្ញុំគិតថា ខ្ញុំមានជីវិតរឹងប៉ឹង ជីវិតគ្រោតគ្រាត ជីវិតជាអ្នកប្រយុទ្ធតតាំងនឹងធម្មជាតិនិយាយរួមខ្ញុំពេញចិត្តនឹងជីវិតខ្ញុំដែលស្គាល់ជីវិតច្រើនជាងមិត្តសិស្សានុសិស្សឯទៀតដែលជាកូនអ្នកទីក្រុង ទោះបីជាខ្ញុំត្រូវធ្វើដំណើរទៅរៀនក្នុងចម្ងាយជាង១០គីឡូម៉ែត្រ ដោយក្តីនឿយលំបាកយ៉ាងណាក្តី រាល់ល្ងាចចេញពីសាលាម៉ោង៥ នៅថ្ងៃខ្លះត្រូវបន្ថែមម៉ោងគេហកិច្ច ឬកីឡារហូតម៉ោង៦ព្រលប់ ទើបបានចាកចេញពីសាលា ទោះបីពោរពេញដោយការភ័យខ្លាចនឹងភាពអន្ធការនៃស្បែរាត្រី និងខ្លាចពើបប្រទះចោរខ្មួញតាមផ្លូវដែលត្រូវខំធ្វើដំណើរយ៉ាងសស្វាក់សស្វើតយ៉ាងណាក្តី ក៏ខ្ញុំមិនដែលភ្លេចទេថា ទោចក្រយានដ៏រខេករខាករបស់ខ្ញុំបាននាំឲ្យធ្វើពនេចរគយគន់ធម្មជាតិដ៏ត្រកាលនៃស្រុកស្រែចម្ការអមទីរួមខេត្តព្រៃវែងនេះជាអលង្ការ ពេលខ្ញុំក្រឡេកទៅក្រោយម្តងៗ មើលឃើញទីរួមខេត្តព្រៃវែងប្រៀបដូចជាដួងចន្ទពណ៌បៃតងរះប៉ប្រិះនឹងផែនដី ដែលហ៊ុមព័ទ្ធទៅដោយដួងតារាដ៏ភ្លឺព្រោងព្រាតនៃអំពូលចង្កៀងអគ្គិសនី សម្រាប់បំភ្លឺទីក្រុងនាពេលរាត្រី បើនៅរដូវវស្សាវិញ វាហាក់ដូចជាកូនកោះកណ្តាលលំហរសមុទ្ទ ។ ខ្ញុំស្រមៃចង់មានវាសនាអាចជួយនាំភាពរុងរឿងបែបបនេះមកដាក់នៅជនបទ ប្រសិនបើជីវិតសិក្សារបស់ខ្ញុំបានទៅដល់គោលដៅ ។ ខ្ញុំ និងមិត្តខ្ញុំពីរបីនាក់ទៀតជាកូនអ្នកភូមិជាមួយគ្នា មានប្រុស មានស្រីតែងតែធ្វើដំណើរជាមួយគ្នានិងជួយគ្នារាល់ពេលមានធុរៈតាមផ្លូវ ពេលខ្លះយើងសាសងគ្នាយ៉ាងក្លៀវក្លាអំពីក្តីស្រមៃទៅអនាគតរបស់យើង និងពីការប្រណែននឹងវាសនាអ្នកទីក្រុងដែលរស់សុខស្រួលពេក នាំឲ្យអ្នកខ្លះរស់ក្នុងភាពទំយើ និយាយស្តីមិនចំតួអក្សរ ។ យើងស្របគ្នាថា នេះមកពីអ្នកដឹកនាំមិនស្គាល់ជីវិតកសិករ ប្រសិនបើពួកយើងអ្នកស្គាល់ជីវិតតស៊ូនឹងធម្មជាតិបែបនេះ មានវាសនាទទួលបានមុខនាទីក្នុងសង្គមយើងពិតជានឹងខិតខំជួយស្រុកភូមិជាទីស្រឡាញ់របស់យើងឲ្យបានស្គាល់វឌ្ឍនភាព ឬ ឲ្យបានខិតជិតទៅនឹងទិដ្ឋភាពទីក្រុងតាមដែលយើងអាច ។

ម៉ោង១០យប់ទៅហើយ អ្នកភូមិនិទ្រាលក់ដោយស្កប់ស្កល់ ក្រោយពីពលកម្មយ៉ាងហត់នឿយនៅពេលថ្ងៃ ។ នៅក្នុងភូមិនេះយប់ថ្មើរនេះ ប្រហែលជាសល់មនុស្សបួនប្រាំនាក់ទេ ដែលមិន

ទាន់អាចចូលនិទ្រាបាន ពោលគឺអ្នកដែលកំពុងរៀននៅវិទ្យាល័យព្រៃវែងជាមួយខ្ញុំនេះ ។

បទចម្រៀង «ឱផ្ទៃស្រុកខ្មែរ» បានទម្លាក់សំឡេងពីរលកវិទ្យុជាតិ ឯផ្ទះអ៊ំ សៀន ។ បទនេះ ជាមួយបទចម្រៀងដ៏ពេញនិយមមួយសម្រាប់កសិករខ្មែរនាសម័យនោះ ។ ស័ព្ទសំនៀងដ៏ពោរពេញដោយសុទិដ្ឋិនេះ ពិរោះថ្លាឆ្អេងដូចទិព្វអម្រឹត ជ្រោតជ្រាបត្រជាក់ស្រិប ដល់ជំរៅនៃដួងចិត្តកសិករ ពលកម្មនឿយហត់តែពោរពេញដោយក្ដីអំណត់ សាមគ្គី ទូលាយ អធ្យាស្រ័យល្អ ជួយគ្នាជាក្រុមប្រវះដៃយ៉ាងស៊ីសង្វាក់ នេះជាប្រពៃណីក្រុមសាមគ្គីក្នុងមុខរបរកសិកម្មមួយបែប ដែលលើកគ្នាទៅជួយគ្នាទៅវិញទៅមកយ៉ាងរាក់ទាក់ ។ ពោល គឺជាសម័យដែលការជួលពលកម្មមិនត្រូវបាននិយមទេ ហើយពលកម្មប្រវះដៃទើប ជាការពេញនិយមរបស់ស្មារតីមនុស្សនាសម័យកាលនោះ ។ ខ្ញុំបន់ឲ្យតែដល់ថ្ងៃអាទិត្យម្ដងៗ ដែលខ្ញុំមានឱកាសអាចទៅស្ទូង ឬច្រូតស្រូវប្រវះដៃនឹងគេស្ដាប់ការដាក់បណ្ដៅ ឬដោះប្រស្នាគ្នាយ៉ាងស្ទាត់ជំនាញរបស់បងៗក្រមុំកម្លោះភូមិខ្ញុំ ដែលខ្ញុំសូមកោតសរសើរថា បណ្ដៅប្រស្នាទាំងនេះ គ្មានបង្រៀនទេ នៅវិទ្យាល័យ ។ ខ្ញុំអាចនិទាន និងធ្វើវិភាគរឿងទុំទាវ មាយើង មាយាស្ត្រីសាសងជាមួយបងៗ បានពូកែជាងពួកគាត់អ្នកមិនបានចូលសាលា តែជាមួយពាក្យបណ្ដៅខ្ញុំត្រូវគេលក់ជាញឹកញាប់ ។ គិតទៅជម្រៅនៃពាក្យបណ្ដៅទាំងនោះមិនងាយស្វែងយល់ន័យវាបានទេ មានតែអ្នកប្រយុទ្ធនឹងធម្មជាតិដូចយុវកសិករទាំងនេះ ទេដែលពូកែលេងបណ្ដៅ ។ ឧទាហរណ៍ថ្ងៃមួយ គេដាក់បណ្ដៅមកលើខ្ញុំថា «អ្នកមួយមកពី ស្រុកបារាំងរន្ទះបាញ់ផាំងយកដៃខ្ទប់» តើជាអ្វី? ខ្ញុំឆ្លើយថា «ដែកកេះ» ។ ជាចម្លើយត្រូវ ខ្ញុំរួចខ្លួនពីការលក់ ។ ប៉ុន្តែ គេបណ្ដៅមួយតទៀតថា អ្នកមួយមកពីបារាំង អារក្សជាន់ផាំងគ្រវីខ្វាត់ខ្វាយ តើជាអ្វី? ខ្ញុំមិនអាចរកចម្លើយនេះឃើញឡើយ ដើម្បីទទួលបានចម្លើយនេះ ខ្ញុំត្រូវយល់ព្រមឲ្យគេលក់ខ្ញុំ ។ បងៗទាំងនោះ បានបង្កើតជាពាក្យកម្រងកែវយ៉ាងណែងណងថា លក់ មារយាទ (ជាឈ្មោះរបស់ខ្ញុំ) ទៅដល់ស្រុកបារាំង ទិញចានទិញឆ្នាំងត្រឡប់មកស្រុកយើងវិញ ។ បណ្ដៅនោះ គឺសំដៅលើត្បាល់កិនស្រូវ (ដោយដៃ) ព្រោះកាលណាយើងចាប់ផ្ដើមកិន ត្បាល់នឹងត្រូវគ្រវីបង្វិលជុំវិញ ហើយស្រូវដែលកិនចេញជាគ្រាប់អង្ករលាយ នឹងអង្កាមហូរចេញខ្វាយប្រសាចជុំវិញត្បាល់ ។

ពិតជាធូរស្រាលអារម្មណ៍ណាស់ គួរឲ្យជ្រះថ្លាខ្សៀវខ្សារក្នុងដួងចិត្តមែន ។ ឱផ្ទៃស្រុកខ្មែរ គឺជាទិដ្ឋភាពពិតៗ នៃសង្គមារម្មណ៍ នៃព្រលឹងវិញ្ញាណខ្មែរជំនាន់មុនសង្គ្រាម ។ សម័យកាលនោះ បទចម្រៀង និងសិល្បៈល្អៗជាច្រើនបានឆ្លុះបញ្ចាំង និងបកស្រាយនូវអារម្មណ៍ស្រេកឃ្លានសេរីភាព នៃការថ្លៃថ្នូនមនោសញ្ចេតនារបស់សង្គមខ្មែរ ។

ពេលព្រលឹម រាល់វេលាមាន់រងាវមួយដង ឬពីរដង អ៊ំ សៀន ដែលតែងតែម៉ឺងម៉ាត់ ក្រោកដាំបាយ រៀបចំឲ្យប្ដី និងកូនគាត់ចេញទៅវាល ខ្ញុំក៏តែងតែងើបដណ្ដាំបាយ ដើម្បីវេចទៅសាលាដែរ ។ ព្រលឹមមួយនោះ ស្រាប់តែមានសំលេងស្រែកខ្ទរខ្ទាន់ឡើង «ផ្កាយព្រឹកដុះកន្ទុយ! ផ្កាយព្រឹកដុះកន្ទុយ!» ។

តើផ្កាយដុះកន្ទុយជាប្រផ្នូលអ្វី ហេតុអ្វីហាក់ដូចជាមានការជ្រួលច្របល់ ខ្ញុំរត់ទៅផ្ទះ អ៊ំ សៀន តាមស្ដាប់ការបកស្រាយរបស់ចាស់ៗ ។ អ៊ំ សៀន បានរៀបរាប់ប្រាប់អ្នកភូមិបួន ដប់នាក់ដែលកំពុងតាមដានព្រឹត្តិការណ៍នេះជាមួយគាត់ថា ព្រឹកនេះតាមប្រឡោះជញ្ជាំង ស្លឹករហែកមួយដុំនៅផ្ទះបាយគាត់ មានពន្លឺចាំងប្លែកខុសប្រក្រតី អ៊ំក៏អើតតាមមើលទៅក្រៅ ងើយដេញរកមើលតាមពន្លឺនោះទៅ ឃើញវាចេញពីប្រភពផ្កាយព្រឹកដ៏ឆ្ងាយសន្ធឹមឯទិសបូព៌ ជះការស្មើជាបាច់ពន្លឺឆ្នូតវែង ចុះមកស្រុកខ្មែរតែម្ដង ។ សំឡេងជ្រួលច្របល់អ៊ូអរ ក៏ចាប់លាន់ឮឡើងពីមាត់មួយ ទៅមាត់មួយ ជួយមើល! ជួយមើល! ផ្កាយព្រឹកដុះកន្ទុយ! ផ្កាយព្រឹកដុះកន្ទុយ! កន្ទុយវាបាញ់ចំស្រុកយើង ច្បាស់ជានឹងមានសង្គ្រាមទុរភិក្សកើតឡើងដល់ស្រុកយើងមិនខានឡើយ ។ សំឡេងបញ្ចេញយោបល់របស់អ្នកស្រុកលាន់ឡើង ជាមួយនឹងដង្ហើមធំយ៉ាងណែនដើមក ។

រាត្រីបន្ទាប់មកទៀតនៅលើរានហាលមុខផ្ទះអ៊ំ សៀន លោកឪពុកខ្ញុំ (ពូសាយ) លោកពូ សន របស់ខ្ញុំ បងប្អូនគាត់ទាំង៣នាក់ព្រមទាំងលោកយាយ ម៉ៅ របស់ខ្ញុំផងដែរ ។ អ្នកជិតខាងមួយ ចំនួនដែលមិនទាន់មានវិទ្យុស្ដាប់ តែងតែស្កាត់ទៅរកហូបតែ ជជែកគ្នាលេង ស្ដាប់ចម្រៀង ស្ដាប់រឿងល្ខោន ស្ដាប់ព័ត៌មានតាមវិទ្យុជាតិវិភាគពីរឿងស្រុកទេស ។ រាស្ត្រខ្មែរគ្រប់រូបពេលនោះ

តែងរស់ក្នុងមោទកភាពក្បៀវក្លាចំពោះដោគវាសនារុងរឿងនៃប្រជាជាតិខ្មែរ ។

អ៊ឹំ សៀន និយាយបណ្ដើរស្ដោះទឹកមាត់ម្លូរបណ្ដើរថា « ក្រោមកិច្ចដឹកនាំរបស់អង្គសម្ដេចឪ ស្រុកយើងសុខសប្បាយណាស់ សព្វថ្ងៃនេះ យើងមានវិទ្យុស្ដាប់ស្ទើរតែគ្រប់ផ្ទះ ក្នុងភូមិយើងក៏ដូចជាភូមិជិតខាងដែរ ផ្ទះក្បឿងក្រហមប្រាល ស្ទើរគ្រប់ដំបូល ឆ្នាំនេះ អន្ទិតជុន អន្ទិតហុង អន្ទិតសយ ដាន់ ទិញម៉ូតូបានជិះ ជនបទយើងកាន់តែឈានឡើង ទាន់ទីក្រុងហើយ» ។

ខ្ញុំទន្ទេញមេរៀនបណ្ដើរ ផ្ទៀងត្រចៀកលួចស្ដាប់ការសន្ទនានេះបណ្ដើរ ។ ជារៀងរាល់យប់ ជាទូទៅខ្ញុំចាប់អារម្មណ៍ណាស់លើការជជែកវិភាគពីទស្សនៈនយោបាយ ខ្ញុំបន់ឲ្យតែពួកគាត់ជជែកគ្នាឲ្យបានច្រើនពីរឿងនយោបាយ ។

លោកយាយ ម៉ៅ បាននិយាយថា «តំណតទៅ កូនចៅជំនាន់ក្រោយមិនដឹងជាសម្បូរសប្បាយយ៉ាងណាទេ ។ តាំងពីដណ្ដើមឯករាជ្យពីបារាំងមក ស្រុកយើងបានសន្តិភាពជឿនលឿនណាស់ នៅជុំវិញស្រុកយើង ស្គរកាំភ្លើងគ្មានស្ងាត់ទេ យួនក៏អ៊ីចឹង សៀមក៏ដូចគ្នា រាស្ដ្រគេរត់សង្គ្រាម គ្មានបានធ្វើស្រែជួបជុំកូនចៅដូចយើងទេ ។

អ៊ឹំ សៀន ៖ ខ្ញុំឮបងស្រីៗ និងមីងៗភូមិយើងនិយាយថា ឥឡូវនេះ ពួកគាត់អានអក្សររួច ដោយសារលោកបងគាត់ជួយបង្រៀន ។

ឪពុកខ្ញុំ៖ ត្រូវហើយ សនបងធ្វើស្រែខ្ទួនឯង ចំណាយលុយទិញប្រេងកាតចាក់មាំងសុងអុជ បង្រៀនអក្ខរកម្មដល់អ្នកភូមិយើង មិនមែនចង់និយាយថា បងធូរធារទេ តែគឺបងពេញចិត្តនឹងបានបម្រើមាគ៌ានយោបាយរបស់សម្ដេចឪ ដែលអំពាវនាវឲ្យអ្នកចេះអក្សរជួយបង្រៀនអក្ខរកម្មដល់អ្នកមិនចេះអក្សរ ពីព្រោះថា មានតែអក្សរនេះហើយ ដែលបើកភ្នែកមនុស្សទៅរកការចេះដឹង អាចជួយសង្គ្រោះមនុស្សឲ្យចាកផុតពីក្ដីល្ងង់ខ្លៅបាន ហើយគឺកម្ពៅនេះហើយដែលធ្វើឲ្យមនុស្សចូលចិត្តទីងងឹតជាងទីភ្លឺ ពោលគឺចូលចិត្តបង្កទុក្ខសោក និងវិនាសកម្មដល់គ្រួសារខ្លួនឯងផង ដល់សង្គមជាតិផង ។

អ៊ឹំសៀន ៖ នែៗ លោកប្អូនស្ដាប់ព័ត៌មានសិនមើល គេផ្សាយពីរឿងប្រជុំសភា ។ ស្ដាប់ ស្ដាប់សិនសភាគេប្រជុំពីរឿងអ្វី?

«ខ្ញុំសេនាប្រមុខ លន់ នល់ ខ្ញុំសូមប្រកាសជាមហោឡារិកថា កិច្ចប្រជុំសភានៅថ្ងៃទី១៨ មីនា ឆ្នាំ១៩៧០នេះ បានមូលមតិគ្នាជាឯកច្ឆ័ន្ទ ទម្លាក់សម្ដេច សីហនុ ចេញពីតំណែងប្រមុខរដ្ឋ ព្រោះព្រះអង្គជាស្ដេចមិនស្មោះត្រង់នឹងផលប្រយោជន៍ជាតិ លក់ដីឲ្យយួន ។ នេះគឺជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រមួយ ដែលនឹងកែប្រែមាតុភូមិជាទីស្នេហានៃយើងចេញពីរបបសក្តិភូមិផ្ដាច់ ទៅរករបបសេរីនិយមពិតប្រាកដ ។ នៅទីបញ្ចប់នៃបដិវត្តន៍នេះ បងប្អូននឹងមានបានស្មើគ្នា គ្មានអ្នកក្រ» ។

ភីង1 ភីង1 ហ៊ឹ1 ហ៊ឹ1 ស្គរគក់ទ្រូង និងដង្ហើមធំអួលណែនជ្រែកបំពង់កក្រុមកសិករដែលកំពុងស្ដាប់វិទ្យុទាំងនោះចេញមកហាក់ស្ទើរផ្ទុះបែករហែកដើមទ្រូង៖

◆ សម្ដេចឪ ក្បត់ជាតិ1 មិនជឿទេ1 មិនជឿទេ1 ពីព្រោះមុនពេលសម្ដេចឪយាងចេញទៅទស្សនកិច្ចនៅរុស្ស៊ីលើកនេះ ទ្រង់បានតែងតាំងឧត្តមសេនីយ៍ លន់ នល់ ជាប្រមុខរដ្ឋស្ដីទីរួចទៅហើយ តើឧត្តមសេនីយ៍ លន់ នល់ ចាំបាច់អីទៅក្បត់សម្ដេចឪ នេះគឺជាផែនការតែមួយទេ យើងរាស្ត្រកុំឆ្ងល់ច្រើនពេក ។

◆ ត្រូវហើយ យើងគិតទៅមើល តើហេតុអ្វីក៏សម្ដេចឪតែងតាំងឧត្តមសេនីយ៍ លន់ នល់ ជាសេនាប្រមុខ នោះគឺជាសេនាដៃឯក យើងគួរតែយល់

◆ ស្រុកយើងមុខជាកើតសង្គ្រាមហើយ

◆ កុំព្រួយខ្វាំងពេក នគរគោកធ្លក ទឹកដីសុវណ្ណភូមិ មិនងាយសាបសូន្យទេ

◆ ពូជព្រះជិនវង្សគ្រាន់តែកំសត់ មិនងាយស្លាប់ទេ

◆ រឿងនេះ សុទ្ធតែរឿងនយោបាយកុំដេកដួលម្នាងៗ យើងរាស្ត្រចាំតែគេគូរមុខយក្សឲ្យជល់គ្នាទៅ

◆ ស្រុកខ្មែរដូចស្រីក្រមុំ ប្រទេសជិតខាងតែងតែចិញ្ចឹមចិត្តចង់លេបត្របាក់ ម្ល៉ោះហើយ អ្នកដឹកនាំខ្មែរពិបាកនឹងឋិតនៅក្នុងឯករាជ្យណាស់

◆ ប៉ុន្តែនយោបាយចាយមនុស្ស មិនមែនដូចមនុស្សចាយប្រាក់ទេ ធ្វើម្ដេចវាសនាស្រុកទេស យើងរាស្ត្រខំតែធ្វើស្រែទៅ

◆ ស្ថានតែស្រុកសង្គ្រាម គេទុកឲ្យយើងធ្វើស្រែស្រួលៗហ្អ?

◆ យើងខំទៅវត្ត វេរភត្តប្រគេនព្រះសង្ឃ អុជធូបទៀនបួងសួងព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ សុំជួយបវៀសបញ្ចៀសសង្គ្រាមឲ្យឆ្ងាយពីភូមិស្រុកយើងា

សព្ទសំឡេងជជែកគ្នាដែលចាប់ផ្តើមឡើងដោយសំឡេងដ៏ក្លៀវក្លា ដែលធ្លាប់តែអួតដាក់គ្នាតាំងពីឆ្នាំ១៩៥៣ (ការទាមទារឯករាជ្យ) របស់ព្រះករុណាព្រះបាទសម្តេច សីហនុ មកទល់សព្វថ្ងៃនេះ ស្រុកយើងចម្រើនរុងរឿងកើនទៅមុខយ៉ាងត្រចះត្រចង់ ដូចរាត្រីកាលបក្សនោះ ។ ឥឡូវនេះ បានប្រែផ្លាស់ទៅជាសភាពរំជួលអួលអាក់ ជ្រួលច្របល់ ខ្វាយខ្វល់ ម្នាក់ៗស្ថិតក្នុងអារម្មណ៍ដូចជាមានផ្ទាំងថ្មដ៏ធំសង្កត់លើចិត្តគំនិតស្មារតីឲ្យក្រៀមក្រំរកថ្លែងពុំបាន ។

## រនោចអាប់អួរ

ម៉ោង១២អធ្រាត្រ កសិករគ្រប់រូបដែលធ្លាប់តែឆាប់និទ្រាពីព្រលប់ ឥឡូវនេះ ទោះជានឿយហត់ពីថ្ងៃយ៉ាងណា ក៏នៅតែពេលយប់សម្រាន្តមិនលក់សោះ ព្រឹត្តិការណ៍១៨ មីនា ១៩៧០ បានប្រែផ្លាស់ដួងចិត្តប្រជាកសិករខ្មែរគ្រប់រូបឲ្យស្រងាកស្រងល់ចុកឆ្អល់ពេញដើមទ្រូង ម្នាក់ៗមានទឹកមុខស្រពាប់ស្រពោន ពោរពេញទៅដោយក្តីថប់បារម្ភតប់ប្រមល់អព្វមង្គលរកអ្វីប្រៀបពុំបាន ។ដួងព្រះចន្ទដែលធ្លាប់តែថ្លាឆ្វេងកាលពីរាត្រីខ្មើត ឥឡូវហាក់ចង់ថយរិទ្ធិគេចខ្លួនចូលពួនក្នុងលម្ហអាកាសភ្លឹបភ្លែតទៅហើយ សន្ធឹកខ្យល់វូរៗពីទិសនិរតីរុញច្រានពពកខ្មៅទាំងផ្ទាំងៗ ឲ្យហិចហាក់មកគ្របដណ្តប់ពាសពេញលំហរអាកាស ។ បាត់ភ្លឹប ទៅហើយ ដួងព្រះចន្ទដែលធ្លាប់តែភ្លឺត្រចះ ឥឡូវប្រែផ្លាស់ជាលិចបាំងបាត់សូន្យឈឹង ។ ស្បែអន្ធការអាប់អួរបានលាតផ្ទាំងសំពត់ខ្មៅមកពាសសន្ធឹងផ្ទៃវេហាឲ្យងងឹតស្លុងស្លុប សន្ធឹកផ្គរគ្រហឹមៗគ្រឹមៗពីលើមេឃ ផ្លេកបន្ទោរពុះជ្រែកហែកស្បៃវេហាខ្វាកៗគួរឲ្យព្រឺស្បែកយប់ចម្លែកៗ ភ្លៀងខុសរដូវអីក៏កំណាចម្ល៉េះ តើអ្នកខំបញ្ចេញចង្គមសាហាវយ៉ាងនេះ ដើម្បីត្របាក់លេបយកវាសនាជាតិខ្មែរឥឡូវនេះឬ?

ភ្លៀងព្យុះឈូរឆរក្នុងដួងចិត្ត ផ្គរស្រែកកម្រិតឲ្យទុកភ័យ រន្ទះផ្ទាំងៗបាញ់កាប់ប្រល័យ បាញ់ឲ្យខ្មែរក្ស័យក្សិនមរណា វិបត្តិវិកកើតវិបល្លាស សុខសោះប្រែផ្លាស់ជាឈឺផ្សា ធ្លាប់រស់សុខុដុមជួបជុំគ្រួសារ មិនដែលគិតថា មានគ្រោះកាច ។ គ្រាប់ភ្លៀងពេលរសៀលមិនទាន់ដាច់ផង ស្រាប់តែគ្រាប់កាំភ្លើងពេលព្រលប់បាចសាចបន្ត ។

ក្រោយថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ហ្វូងបាតុករដែលមាននិន្នាការរាជានិយមបេះ តែធ្វើសកម្មភាពឡើងនៅពាសពេញផ្ទៃប្រទេស ប្រឆាំងនឹងរបបសាធារណរដ្ឋគ្មានឈប់ឈរ ។ ដោយគ្មានការអត់ឱន និងដើម្បីសម្តែងឥទ្ធិឫទ្ធិនៃអាវុធយុទ្ធភ័ណ្ឌដ៏សម្បូរបែប ក្រោមជំនួយចក្រពត្តិអាមេរិក ក្រុមទាហានរបស់រដ្ឋាភិបាលបានបាញ់ប្រហារស្រោច ដូចជះទឹកភ្លៀង ទៅលើហ្វូងបាតុករមួយក្រុមនៅក្បែរផ្សារព្រៃវែងនៃទីរួមខេត្តព្រៃវែង ។ នោះគឺហ្វូងបាតុករដឹកនាំដោយលោកតា កេត ចៅកែឡុតដ្ឋភូមិស្វាយអន្ទរដែលមានសភាពសន្ធោរសន្ធៅជាងក្រុមបាតុករដទៃទៀត ។ ក្រុមនេះត្រូវរងការបាញ់ប្រហារ ដោយកងទ័ពលោកសេនាប្រមុខ លន់ នល់ នៅជិតផ្សារព្រៃវែងនាំឲ្យស្លាប់ និងរងរបួសរាប់មិនអស់ ហើយក៏រត់ខ្ចាត់ខ្ចាយ មេបាតុករ និងអ្នកចូលរួម៣នាក់ទៀត បានស្លាប់ក្នុងថ្លុកឈាមកណ្តាលផ្លូវថ្នល់ ។ លោហិតក្រហមឆ្អៅរបស់វីរបុរសខ្មែរប្រជាកសិករស្លូតត្រង់ខ្មែរចាប់ផ្តើមហូរស្រោចលើដែនសុវណ្ណភូមិជាបណ្តើរៗ ហូរហែទៅហើយ ។ សង្គមខ្មែរទាំងស្រុកស្រែ ចម្ការ និងទីក្រុងដែលធ្លាប់តែអួតខ្វះខ្វារដាក់គ្នាប្រកួតប្រជែងគ្នាថា រដ្ឋាភិបាលល្អ ខ្លាំងពូកែ ឬក៏ថា ព្រះរាជាមានមេត្តាករុណាទសពិធរាជធម៌ទូលំទូលាយ ប្រែជាស្ងប់ស្ងាត់ ល្អក់កករ ក្នុងអារម្មណ៍ ម្នាក់ៗលែងហ៊ានក្អកពីរឿងនយោបាយទៀតហើយ ភាពអវិចិត្តនឹងគ្នា ការភ័យខ្លាច ការមិនទុកចិត្តគ្នា បេះតែកើនឡើងពីមួយថ្ងៃទៅមួយថ្ងៃ ។

ឱ!បទចម្រៀង «ខ្មែរអើយចូរចាំដាក់ថា តាមសាវតារជាតិខេមរាធ្លាប់តែថ្កើង ទឹកដី ខ្មែរធំទូលំទូលាយសព្វសាយរុងរឿង គេឯងតែងលើកតម្កើងតម្កល់ជាតិ យើងចាត់ទុកឡើងជាជាតិច្បង ។ អារ្យធម៌ខ្ពង់ខ្ពស់ឆើតឆាយ បានចេញផ្សព្វផ្សាយគ្រប់ទិសទាំងឡាយចុងបូព៌ា» ។ តែឥឡូវនេះ បិសាច៨ទិសកំពុងលាក្រញាំបញ្ចេញចង្កូម ដំឡើងស្បែក បើកភ្នែកក្រលួងដាក់ខ្មែរហើយ ។ ស្ថានទូតចិនបានដកខ្លួនរត់បាត់ហើយ រដ្ឋាភិបាលនៃសាធារណរដ្ឋ

ខ្មែរ បានរឹតចំណងជាមួយសហរដ្ឋអាមេរិក និងសាធារណរដ្ឋវៀតណាមខាងត្បូងជាជំនួសវិញ ដើម្បីជំនួយយោធា ។

ខាងរាជានិយមបានភៀសខ្លួនចូលព្រៃ ចងមិត្តជាមួយសាធារណរដ្ឋសង្គមនិយមវៀតណាមខាងជើង និងចិនប្រជាមានិត ។ ខេត្តស្ទឹងត្រែងទាំងមូលត្រូវវាយដណ្តើមយក និងកាន់កាប់ដោយកងទ័ពរំដោះពីឆ្នាំ១៩៧០មកម្ល៉េះ ។ សម្តេចព្រះនរោត្តមសីហនុ បានស្រែកអំពាវនាវតាមរលកសំឡេងវិទ្យុក្រុងប៉េកាំង និងវិទ្យុរណសិរ្សខ្មែរដែលមានស្ថានីយ៍ នៅខេត្តស្ទឹងត្រែង សូមឲ្យកូនចៅជនរួមជាតិខ្មែររត់ចូលព្រៃម៉ាគី ដើម្បីរួមចំណែកវាយទ័ពអាយ៉ងធីវគី និង លន់ នល់ ចេញពីទឹកដីខ្មែរ ។ ពាក្យស្លោកទឹកឡើងត្រីស៊ីស្រមោច ទឹកហោចស្រមោចស៊ីត្រី ជាមេរៀនដែលកសិករទន្ទេញគ្រប់មាត់ ដើម្បីទប់ស្កាត់ការរៀងខ្លួនកុំឲ្យជ្រុលទៅម្ខាងៗតាមការអូសទាញពីសាចញាតិ ឬមិត្តភក្តិ ។

ពេលថ្ងៃអ្នកមាននិន្នាការខាងរដ្ឋាភិបាល តែងអួតក្អេងក្អាងពីកម្លាំងសព្វាវុធទំនើប គ្រប់បែបគ្រប់ធុនរបស់ចក្រពត្តិ ពួកគេបញ្ចេញយោបល់ថា «ធ្វើស្រែនឹងទឹក ធ្វើសឹកនឹងបាយ ជិះឡានជិះយន្តហោះទៅច្បាំងប្រសើរជាងធ្វើជាអ្នកកំសត់រត់លូនកាត់វាលកាត់ព្រៃ ទៅច្បាំង គេលើកពាក្យស្លោកថា «ធ្វើឆ្កែអ្នកមានស៊ីសាច់គោ ធ្វើឆ្កែអ្នកចិញ្ចឹមគោលិឍទឹកប្រហុក» ។

ពេលយប់មកដល់អ្នកមាននិន្នាការរាជានិយម ខំដំឡើងសំឡេងវិទ្យុប៉េកាំងឮងៗ «អាយ៉ង លន់ នល់ បានធ្វើរដ្ឋប្រហារទម្លាក់សម្តេចនរោត្តម សីហនុ ព្រះប្រមុខរដ្ឋនៃព្រះរាជាណាចក្រកម្ពុជាចេញពីតំណែងនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ដើម្បីដណ្តើមអំណាច និងដាក់ប្រទេសកម្ពុជាឲ្យទៅជាឈ្នាន់វាតទីរបស់ចក្រពត្តិនិយមអាមេរិកាំង ដើម្បីឈានទៅត្រួតត្រាអាស៊ីអាគ្នេយ៍ ។ បងប្អូនរួមជាតិខ្មែរ ទាំងកសិករ កម្មករ ព្រះសង្ឃ បណ្ឌិតសិស្សនិតបញ្ញវន្តគ្រប់រូប សូមអ្នកក្រោកឈរឡើងរត់ចូលព្រៃម៉ាគី រួមសាមគ្គី និងកម្លាំងតស៊ូរណសិរ្សសេរីកាជាតិរបស់ចលនាបដិវត្តន៍រំដោះជាតិខ្មែរ ដែលកើតមានឡើងនៅគ្រប់ទិសទីនៃតំបន់រំដោះជាតិខ្មែរ ហើយដែលពីមួយថ្ងៃទៅមួយថ្ងៃកាន់តែរីកធំធាត់ឥតឈប់ឈរ» ។

«ក្រោកឡើងៗអស់អ្នកក្រីក្រខ្ញុំគេទាំងប៉ុន្មាន ក្រោកឡើងៗអស់អ្នកតោកយ៉ាកគ្រប់ប្រាណ តស៊ូនេះដើម្បីគ្រាបំផុត International ជាសង្គមអនាគត» ។ នេះជាបទចម្រៀងគោរពទង់ជាតិប្រចាំវិទ្យុសំឡេងរណសិរ្សខ្មែរផ្សាយចេញពីទីក្រុងប៉េកាំង ។ បទចម្រៀងអីក៏ពិរោះម្ល៉េះ! និយាយត្រូវម្ល៉េះ! កសិករបន្តទៀត ខាងមានប្រាក់ខែ នឹងខាងអត់ប្រាក់ខែ ខ្ញុំទៅខាងអត់ប្រាក់ខែហើយ ព្រោះជាកងកម្លាំងដែលមានសីលធម៌ខ្ពស់ និងមានចរិតស្នេហាជាតិពិតៗ» ។ សំឡេងផុសចេញពីវង់អ្នកស្តាប់វិទ្យុប៉េកាំង ។

នៅលើកំណាត់ផ្លូវជាតិលេខ១ ចរាចរចេញចូលទៅមកបានប្រសើរតែត្រឹមអ្នកលឿង-ភ្នំពេញប៉ុណ្ណោះ ចំណែកពីអ្នកលឿង-ស្វាយរៀង ក៏ដូចជាកំណាត់ផ្លូវជាតិលេខ១១ អ្នកលឿង-ព្រៃវែង-អូរពងមាន់ដែរ គ្មានរថយន្តណាមានសេចក្តីក្លាហាន ហ៊ានឆ្លងកាត់ទេ មានតែឡានទ័ព នីរសាររបស់កងទ័ពរំដោះ និងអ្នកដឹងភូមិសាស្ត្រ និងស្គាល់ស្ថានការណ៍ជាក់លាក់ក្បែរនេះទេ ដែលហ៊ានចេញចូលទាំងសស្នើតសស្ទក់ភ្នែកនៅកញ្ជឹងក ។ ទិដ្ឋភាពបែបនេះកើតមានឡើងនៅពាសពេញឆ្នាំ១៩៧០ ។

## សញ្ញាណដំបូងនៃការគិតពីសង្គ្រាម

ខែសីហា ឆ្នាំ១៩៧១ នៅតាមដងផ្លូវជាតិលេខ១ ដែលធ្លាប់តែស្ងាត់ជ្រងំ វាលស្រែដែលទទួលបានការដាំដុះតែប្រមាណ៤០ភាគរយ កំពុងតែប្រែពណ៌ពីបៃតងទៅជាស្លាបសេកមួយៗ ។ ក្រុមគង្វាល និងអ្នកដេញចាបតាមវាលនេះ បានប្រទះឃើញរថយន្តកង់១០ ពីរគ្រឿងបោះពួយលឿនស្លេវ ដូចក្រពើហោះពីត្បូងទៅជើង ។ នៅលើរថយន្ត ក្រុមយុវជនដ៏មានរាងខ្ពស់ស្រឡះមាឌមាំដំបង ស្រាងប៉ុនៗគ្នា អង្គុយលើកៅអីជាជួរក្នុងរថយន្ត រាងកាយគេស្ថិតក្នុងសម្លៀកបំពាក់ឯកសណ្ឋានស្លឹកឈើខ្ចី រុំកដោយកន្សែងក្រហម ពណ៌ឈាមប្រាលឆ្អៅយ៉ាងសង្ហារ ទឹកមុខហំហួនភ្នែកមុតថ្លា ពោរពេញដោយកិត្តិយស ហាក់ហោះយ៉ាងសាហាវជាមួយល្បឿនរថយន្តកង់១០ មើលទៅទំនងជាអ្នកតាំងចិត្តរឹងដូចដែកថែបមែន ពួកគេហាក់គ្មានស្ទុតរន្ធត់នឹងបញ្ហាអសុវត្ថិភាពនៅតាមដងផ្លូវ ដែលរថយន្តកង់១០ កំពុងតែលូនកាត់យ៉ាងហាវហាននេះឡើយ ពីព្រោះជាផ្លូវដែលធ្លាប់មានការពួនស្ទាក់វាយឆ្មក់ជាច្រើនលើករួចមកហើយ ។ ឱ! ពេលនោះ គឺចុងជំនោររដូវនៃសម័យសុខសាន្ត បុរសខ្មែរគ្រប់រូបនៅសម័យនោះ សុទ្ធសឹងជា

អ្នកទទួលបានការអប់រំល្អ និងបំពាក់នូវសីលធម៌តាមអរិយធម៌ដ៏ថ្លៃថ្នូរ និងប្រពៃណីនិយមរបស់ខ្មែរ ទោះបីជាអ្នកចេញពីសាលារៀនក្តី ពីវត្តអារាមក្តី សុទ្ធតែជាមជ្ឈដ្ឋានអប់រំដែលបានបំពេញសមត្ថភាព និងការអប់រំយ៉ាងប្រសើរឲ្យ ពួកគេនូវសភាពពេញលេញ ជាបុរសរស់នៅពោរពេញដោយសារប្រយោជន៍ ជាទឹកកក់ក្តៅ រមនាសម្រាប់គ្រួសារ និងសង្គមជាតិផង យ៉ាងស័ក្តិសម ជាកូនប្រុសដើមទ្រូងប្រាំហត្ថ ។

ប៉ុន្តែតាមប្រតិកម្មពីក្រោយកងរថយន្តនោះ រថក្រោះរាប់សិបគ្រឿងបញ្ចេញសំឡេង ដូចសម្រែកយក្សា ពុះព្រៃព្រឹក្សាផ្ទៃងផ្ទោះអាកាសវេហា ហែកហួរប្រឫកព្រឹកព្រឺកញ័ររំពើក អ្នកដែលបានឮស្នូរសុទ្ធសឹងភ័យរន្ធត់តក់ស្លុតរកអ្វីប្រៀបពុំបាន ។ ហ្វូងគង្វាលបំបោលសត្វពាហណៈ ប្រសាចសំដៅចូលភូមិករ ឆ្នាំចាបនាំគ្នាត្បុលសសុលចូលគុម្ពស្រូវ ស្រែករកព្រះធរណីជាទីសក្ការៈ សូមឲ្យជួយបិតបាំងរាងកាយខ្លួនពីភ្នែកកងទ័ពមួកដែក ។ នៅក្នុងភូមិ អ្នកស្រុកស្រីប្រុសរត់ចូលដើររបង អ្នកខ្លះលាក់ខ្លួនពួនអាត្មានៅក្នុងគុម្ពចេក យុវនារីរត់ឆ្វេឆ្វាស្ទុះស្ទោររកកន្លែងលាក់ខ្លួន និងដោះគ្រឿងអលង្ការរកកន្លែងលាក់ទុក ព្រោះធ្លាប់ឮសុះសាយពីរឿងទ័ពមួកដែកវៀតយ៉ា (យោធាវៀតណាមខាងត្បូង) រំលោភស្រ្តីភេទ ចាប់បេះក្រវិលពីត្រចៀកនារី យកវិទ្យុអ្នកស្រុកធ្វើជាដុំចង្រ្កានដាំបាយ ។ ក្នុងពេលមានសង្រ្គាម សង្រ្គាមចិត្តសាស្រ្តបែបនេះ ធ្វើឲ្យប្រជាកសិករខ្មែរភ័យស្ទើរលោះព្រលឹងស្លាប់មុនអាយុ ។

សន្ទឹកអ្វីក៏ចម្លែកយ៉ាងនេះ មិនដែលឮ មិនដែលដឹងទេតាំងពីដូនតាមក សំឡេងនេះ សំឡេងឮញ័រដី កក្រើកមេឃ មិនដឹងជាអ្នកជិះក្នុងយានយន្តនេះ សាហាវដល់កម្រិតណាទេ ពេលជួបយើងប្រហែលជាហែកហួរឈាមយើងមិនឲ្យស្រក់មួយតក់ដល់ដីទេមើលទៅ ។ នេះជាការរិះគិត និងក្តីកង្វល់ដ៏ធ្ងន់ធ្ងររបស់ប្រជាករក្នុងឈុតដំបូងនៃការចាប់ផ្តើមពើបប្រទះនឹងសង្រ្គាមលើដី លើអាកាសា ។

មិនទាន់រកកន្លែងបានពួនស្កប់ចិត្តផង ម្នាក់ៗនៅតែសសុបសសាប់ រត់ទៅចូលគម្ពោតនេះបន្តិច គម្ពោតនោះបន្តិច ស្រាប់តែលេចចេញនូវក្រុមទាហានខ្មែរ និងវៀតយ៉ា ដើរចេញប្រសាចពីគ្រប់ទិសចូលមកក្នុងភូមិ នេះគឺជាដំណើររ៉េសឺម៉ង់ *(Rassement)* លើកទី១របស់ទ័ពសម្ព័ន្ធមិត្តកាត់តាមភូមិបណ្តោយផ្លូវជាតិលេខ១១នេះ ក្នុងសភាពប្រញាប់ប្រញាល់ទៅរុករានទន្ទ្រានភូមិបន្ទាប់ទៀត ។

"អញ្ជើញចូលផ្ទះវិញមក ពុកម៉ែមាមីងអើយ ខ្ញុំមករកតែយៀកកុងទេ" សម្តីមេបញ្ជាការម្នាក់ ។ ហាសហាសហា! គេអត់ធ្វើអីឯងសោះ នាំគ្នាញ័រស្ទើររាកអាចម៍រាកនោម រត់ចូលពួនឲ្យរង្គើព្រៃ ស្មានតែគេមិនដឹង បើគេចង់សម្លាប់ ឬចាប់ចងយើង ស្មានថា ព្រៃដើររបងនឹងអាចជួយរួចឬ? ហាស! ហាស! សំណើចហួសចិត្តរបស់ប្រជាករ ក្រោយពេលសំឡេងរោទ៍ទ្រហឹង ដូចយក្សារបស់កងរថក្រោះចាកចេញស្ងាត់បាត់ទៅ ។

# សង្គ្រាមអាកាស

## សង្រ្គាមទឹកក្រូត

សង្រ្គាមអាកាសបានចាប់ផ្តើមឡើងនៅចុងឆ្នាំ១៩៧១ ។ រាត្រីមួយ ខ្ទម្ពាគប្រេក អាមេរិក៨គ្រឿង ហោះហើររង្គើមេឃរង្គើដី ទាំងថ្ងៃទាំងយប់ យន្តហោះយកការណ៍ធុន ស្ទាបកាត់ ហោះឆ្វេបឆ្វាបលើកំពូលភ្នំឈើកាច់រេចុះរេឡើង តាំងពីព្រលឹមទល់ព្រលប់គ្មាន ឈប់ឈរសោះ មិនដឹងរឿង ហេតុអ្វីទេ បន្ទាប់ពីបោះពួយចុះបោះពួយឡើង ឆ្វេលទៅលិច ឆ្វេលទៅកើត ឆែលទៅត្បូង ឆៀងទៅជើង កាច់រាង បះគូទងខ្ទើតស្លួយស្មែតហាក់ចង់ គ្រលែងខ្លួនអួតអាងថា អង្គអញនេះជាស្តេចឥន្រ្ទីយ៍ដ៏មានរិទ្ធិបេស្តាអាចពុះ ជ្រែកអាកាស វេហាយ៉ាងមហស្ចារ្យណាស់ គ្មានបុគ្គលណាហ៊ានប៉ះពាល់អាត្មាអញបានឡើយ ។

ភូមិឋាននានា តាមបណ្តោយដងផ្លូវជាតិលេខ១១ រំដើបរំជួលគយគន់ទៅទិដ្ឋភាពភ្នំ ឈើកាច់ទាំងសោករន្ធត់ កងខ្ទម្ពាគចក្រដែលធ្វើសកម្មភាពហោះឆ្វេលក្រឡឹងភ្នំរាប់ម៉ោង មកហើយ បន្ទាប់មក នៅពេលព្រលប់ វាក៏តាំងដាំក្បាលចុះដោយបោះពួយង៉ាវ រួចនៅពេលដែលវាងើបក្បាលឡើងដោយរោទ៍ម៉ាស៊ីនរំពងនោះ គ្រាប់កាំភ្លើងហូរឆ្វាច បាញ់ចេញ តាមគូទយន្តហោះទៅស្រោចស្រង់ភ្នំគ្មានឈប់ឈរនោះ គឺជាអាវុធរ៉ុក្កែត តែដោយពុំធ្លាប់ស្គាល់ ប្រជាកសិករស្រែកប្រកូកប្រាប់ថា "យន្តហោះចាក់ទឹកក្រូតដុះភ្នំឈើកាច់ហើយ" ។ ភូមិដ្ឋានដែលស្ថិតនៅចម្ងាយរាប់សិបគីឡូម៉ែត្រជុំវិញទីលានប្រតិបត្តិការ នាំគ្នាបរទេះដឹក ជញ្ជូនកូនចៅ

រត់ចេញពីភូមិទៅពួននៅតាមរនាមវាលប្រាំង តាមបណ្តោយដងទន្លេ ដោយសារតែការភ័យខ្លាចមិនយល់ទិសតំបន់ ម៉្យាងទៀតដោយសារនិន្នាការទំនោរទៅលើកងទ័ពរំដោះ ដែលបានបំពាក់ប្រជាជននូវកំហឹងឈឺចាប់ចំពោះចក្រពត្តិអាមេរិកថា ចក្រពត្តិតែងប្រើកម្លាំងអាវុធយុទ្ធភណ្ឌដ៏សម្បូរបែបដូចជបាញ់បានឯង១ បាញ់រះស្រោចដូចទឹកភ្លៀង ទៅលើភូមិដ្ឋានដែលគេសង្ស័យថាមានទ័ពរំដោះ ដោយគ្មានគិតគូរ ស្តាយស្រណោះដល់អាយុជីវិតប្រជាជនស្លូតត្រង់ អ្នកឥតកាន់អាវុធឡើយ ។ គ្មាននរណាអាចដឹងព័ត៌មានអ្វីជាក់លាក់ពីសង្គ្រាមទឹកក្រុតនៅភ្នំឈើកាច់នោះទេ ពីព្រោះចាប់តាំងពីក្រោយរដ្ឋប្រហារ ប្រមាណកន្លះឆ្នាំមក គ្មាននរណាម្នាក់អាចដើរចេញពីភូមិ ដោយគ្មានការសុំអនុញ្ញាតពីប្រធានភូមិ ដោយមានបញ្ជាក់ពីមូលហេតុជាក់លាក់បានទេ ស្ថានភាពគុកឥតជញ្ជាំង និង បញ្ញត្តិដាំដើមគរបានចាក់គ្រឹះឡើង និងរីករាលដាលនៅពាសពេញតំបន់រំដោះ ។ ទស្សនាទានថា «សង្គ្រាម» ទឹកក្រុតនោះ ធ្វើឲ្យប្រជាពលរដ្ឋដែលរស់នៅក្នុងចម្ងាយភ្នែកមើលឃើញព្រឹត្តិការណ៍នោះ មានការភ័យស្ទើរលោះព្រលឹង ហើយសម្ងំលាក់ខ្លួនក្នុងលេណដ្ឋាន រហូតដល់ប្រតិបត្តិការនោះរំសាយទៅ ។ ម្នាក់ៗបន់ព្រះ សំពះទេព្តាខ្លាចតែយន្តហោះទាំងនោះ បត់ក្បាលមករកភូមិដ្ឋានខ្លួន ហើយគ្រប់គ្នាលើកដៃសំបូងសង្រួងបន់ស្រន់ អ្នកខ្លះរើសយកដុំដីដាក់ទូលលើក្បាលបន់សូមយកព្រះធរណីជាជម្រកនឹករកកូនទឹកដោះអ្នក ម្តាយថ្ងៃសូមជួយឲ្យព្រឹត្តិការណ៍នេះត្រូវបរវៀសចៀសឆ្ងាយទៅ ។

## សង្គ្រាមសាច់ឈាម

ពូសាយ (លោកឪពុកខ្ញុំ) ដែលមានជំហររឹងបឹងជាងគេ បានពន្យល់ទៅក្រុមគ្រួសារ ពូសន និងអ៊ំ សៀន របស់ខ្ញុំថា យើងមិនអាចរត់ទៅណារួចឡើយ ព្រោះលោកយាយ ម៉ៅ របស់ខ្ញុំ ម្តាយពួកគាត់ទាំងបីនាក់ បានដួលស្លាប់មួយចំហៀងខ្លួន ដោយជំងឺលើសឈាម ។ មីង បាន (ម្តាយខ្ញុំ) មានជំងឺខ្សោយបេះដូង រាល់ពេលឮស្នូរផ្ទុះអាវុធម្តងៗ ទោះនៅជិត ឬ ឆ្ងាយរាប់សិបគីឡូក្តី គាត់ត្រូវខ្យល់ចាប់រឹងមុខរឹងតំបារពោះ ហឹងត្រចៀក ញ័រញាក់សព្វសារពាង្គកាយ ស្រែករើសរ៉ាស់គ្មានឈប់ ហៅរកខ្ញុំ និងលោកឪពុកខ្ញុំឲ្យជួយអាយុជីវិតគាត់ ។ ទាំងបីគ្រួសារនេះ ប្រមូលផ្តុំមកនៅក្នុងលេណដ្ឋានអ៊ំ សៀន ជាមួយគ្នា ព្រោះដើម្បីរួមគ្នាជួយថែរក្សាលោកយាយផង និងដោយក្តីថប់អារម្មណ៍នឹងភាពស្ងាត់ជ្រងំក្នុងភូមិផងយើងព្រួយណាស់ ខ្លាចតែកងទ័ពខាងណាមួយចូលមកអាចនឹងបាញ់សម្លាប់យើងចោលក្នុងលេណដ្ឋាន ដូច្នេះការផ្តុំគ្នាអាចរំលោះការភ័យព្រួយបានខ្លះ និងម៉្យាងទៀតដើម្បីរួមគ្នាធ្វើសេចក្តីសម្រេចថា តើពេលណា យើងគួរធ្វើយ៉ាងណាផង គួរបន្តលាក់ខ្លួនក្នុងលេណដ្ឋានក្នុងភូមិ ឬក៏គួររត់ចេញទៅជ្រកពួនក្នុងព្រៃជាមួយអ្នកភូមិឯទៀត?

នៅក្នុងលេណដ្ឋាន ណាក្តៅហប់ ស្អៀបរមាស់ ណាភិតភ័យនឹងបរិយាកាសលើដី ដែលភ្នែកមើលមិនឃើញ តើនឹងមានហេតុការណ៍យ៉ាងណាកើតឡើងនៅជុំវិញខ្លួនយើង អំពល់ទុកនឹងត្រូវគក់ប្រាប់ បក់ផ្លិតឲ្យអ្នកជំងឺដល់ទៅពីរនាក់ទៀត តើធ្វើម្តេចអាចរត់ចេញពីភូមិដូចអ្នកដទៃបាន គេរត់ស្ងាត់ស្រុកឈឹង នៅតែគ្រួសារយើងយ៉ាងនេះ ចម្បែងចិត្តខ្លាំងណាស់ សង្គ្រាមទឹកក្រុតជុំវិញភ្នំឈើកាច់ ធ្វើឲ្យអ្នករស់នៅចម្ងាយរាប់សិបគីឡូម៉ែត្រ ជុំវិញភ្នំមានអារម្មណ៍ថា ជាវត្ថុរាវដ៏ក្តៅរាប់ពាន់អង្សា បាញ់ចេញមិនឈប់ឈរពីយន្តហោះទាំងនោះ ដោយព្រួសចេញជាអាវុធភ្លើងស្រោចទៅលើតំបន់ភ្នំឈើកាច់ ហើយកុំថាឡើយ មនុស្សសត្វសូម្បីតែរុក្ខជាតិ ផ្ទាំងថ្ម និងសំបកផែនដីនៅទីនោះ ក៏ប្រហែលជាខ្លោចរោល ស្លាប់ ហិលរិចរឹលអស់ជីជាតិគ្មានសល់ឡើយ យើងបារម្ភខ្លាំងជាងនេះទៅទៀត ខ្លាចក្រែង តែជាមួយនឹងទឹកក្រុតជុំនោះ មានរលាយទៅដោយអាវុធគីមី ដែលបំផ្លាញឲ្យហិរដីអស់ជីជាតិ នឹងបន្តឥទ្ធិពលអាក្រក់ក្នុងរយៈពេលវែងទៅលើជីវិតអ្នកស្រុកយើង ដូចអ្វីដែលយើង ធ្លាប់បានឮអំពីសង្គ្រាមគីមីវៀតណាម និងសង្គ្រាមបរមាណូនៅណាកាសាគីប្រទេសជប៉ុន គ្មានការពន្យល់អ្វីទាំងអស់ពីភាគីសង្គ្រាមទាំងសង្ខាង យើងលែងមានពេលស្តាប់វិទ្យុរបស់គូបច្ចាមិត្តសាច់ឯងឈាមឯងទាំងនេះទៀតហើយ ។ សង្គ្រាមទឹកក្រុត លើភ្នំឈើកាច់ធ្វើឲ្យ យើងញាប់ញ័រ ដូចមើលឃើញរាងរោដ៏មាំសាហាវ និងស្តាប់ឮសម្រែកដ៏កំណាចរបស់មច្ចុរាជ មិនទាន់ស្ងប់ពីអារម្មណ៍ញ័រញាក់របស់យើងផង ស្រាប់តែការភ្លើងត្បាល់ធុនធំរបស់ទ័ពរឹកយ៉ា ដែលដាក់លើនាវាចំបាំងក្នុងទន្លេមេគង្គធំ ឯភូមិជ្រោយជ្រៃបានបន្តបាញ់គ្រាប់ផ្លោងរាប់រយ

គ្រាប់ក្នុង១យប់ៗ បាចសាចមកលើភូមិដ្ឋាន តាមដងផ្លូវជាតិលេខ ១១ ដើម្បីការពារ កុំឲ្យទ័ពខ្មែររំដោះ មកកាន់កាប់ផ្លូវជាតិបាន ។

ភុចៗៗ វឺៗៗ វ៉ាក់ៗៗ ខ្វាកៗ! វាជាសំឡេងគ្រាប់ ផ្លោងដែលហើរឆ្ងាយពីយើង ។ ឌុងៗៗ វឺៗៗ ទាំង វឺៗៗ ទាំងៗ ជាសំឡេងគ្រាប់ដែលហើរចំពីលើយើង វានឹងធ្លាក់ ក្នុងរង្វង់១ ឬ ២គីឡូ ជុំវិញយើង ។ ឌុងៗ វ៉ោកៗ វ៉ាប់ៗ វ៉ាកៗ ជាសំឡេង គ្រាប់ដែល ហើរជិតយើងបំផុត ឬចំយើងផងក៏មិនដឹង “ពុទ្ធំ ធម្មំ សង្ឃំ!” ជួយកូន ជួយចៅផង! ផ្ទះយើង យ៉ាងណាទៅហើយ ជិត ណាស់១គ្រាប់នេះ! អ៊ំ សៀន ភ័យនឹងជីវិតខ្លួនឯងខ្លាំងពេក ទាំង អស់គ្នាភ្លេចគិតពីជីវិតសត្វពាហណៈ ។ នៅក្នុងលេណដ្ឋាន បងគង់ កូនអ៊ំ សៀន របស់ខ្ញុំបារម្ភណាស់នឹងផ្ទះក្បឿងបីខ្នងទើបសង់ថ្មី របស់គាត់ រាល់ពេលស្នូរគ្រាប់ផ្លោងផ្ទុះក្លាំងកក្រើកលេណដ្ឋានគាត់ ដែលគាត់សន្និដ្ឋានថា ជាគ្រាប់ធ្លាក់ជិត គាត់តែងតែអើតប្រឡឹម មាត់លេណដ្ឋានយ៉ាងអន្ទះសារ ដើម្បីមើលទៅផ្ទះគាត់ ។ មួយ គ្រាប់នេះ ធ្វើឲ្យគាត់មានអារម្មណ៍ថា ពាហណៈរបស់គាត់កំពុង កញ្ជ្រោលក្នុង ចំណងយ៉ាងវក់វីរ ជ្រួលជាន់គ្នាពេញក្នុងក្រោល ដោយភិតភ័យនឹងគ្រាប់កាំភ្លើងត្បាល់ទាំងនោះ ។ បង គង់ ប្រះ ប្រាលៗ មួយសន្ទុះរួចក៏ស្ទុះរឹងលោតចេញទៅស្រាយចំណង ក្របី គោ ប្រលែងចោលទៅវាល បានរួចពីចំណងភ្លាមពួកវានាំគ្នាដាក់ មេផាយលឿនដូចព្យុះ គ្រាប់ធ្លាក់ក្នុង១គ្រាប់ទៀត កាន់តែលឿន ឡើងៗ ធ្វើឲ្យដីហុយទ្រលោមបាំងពាហណៈទាំងនោះជិត បង គង់ ដែលតាមគយគន់ពាហណៈរបស់គាត់រហូតដល់មើលលែងឃើញ នោះ ស្ថិតក្នុងអារម្មណ៍ស្រពេចស្រពិលសង្ស័យ មិនដឹងជាពាហណៈ ទាំងនោះបាំងបាត់ដោយដីហុយ ឬជាក៏ផ្សែងគ្រាប់ធ្លាក់មួយគ្រាប់ ទៀតប្រល័យជីវិតសត្វក៏ជាមិត្តសម្លាញ់ និងដ៏មានគុណមកលើ ជីវិតគ្រួសារគាត់ទាំងនោះ ឬយ៉ាងណា? គួរឲ្យអនិច្ចារជីវិតមនុស្ស សត្វភិតភ័យលោះព្រលឹងចំពោះសេចក្តីស្លាប់ ចំពោះគ្រឿងអាវុធ ដែលមានស្នូរក្លាំងដូចសម្រែក រាមាសូរយ៉ាងនេះ!

បង គង់ ផ្ងៀងត្រចៀកនៅមាត់លេណដ្ឋានភ្នែកក្រឡិក ក្រឡាប់អើតក្បាលចេញមួយភ្លែត ក្រាបចុះវិញភ្លាម ដោយសំឡេង ឌុងៗៗ វ៉ាប់ៗ ចេញពីជ្រោយជ្រែមកទៀតហើយ “ផ្ទះយើងមិន អីទេម៉ែ” បង គង់ ស្រែក ។ ឌុង វ៉ាប់ៗ គ្រាំងៗ ប្រោកៗ ប្រាវ! សំឡេងគ្រាប់ធ្លាក់ ព្រមទាំងអម្បែងអេក្វាហើរច្រវ៉ាត់ដើមអំពិល បារាំងតាមដើងរបងភូមិ ធ្លាក់មែកចុះប្រាវដូចគេកាប់ លេណដ្ឋាន របស់គ្រួសារយើងពេលនេះញ័រដូចគេកន្ត្រាក់ ដីជុំធ្លាក់ប្រាវដូច គេចោលចេញពីដំបូលដី ដែលគ្របលើដើមឈើតម្រៀបលើខ្នង លេណដ្ឋាន ដីរាយធ្លាក់ ស្រោចឈូរដូចគេជះខ្សាច់ទាំងល្អិតៗមក លើក្បាល អ្នកជ្រកពួននៅក្នុងលេណដ្ឋាននេះ ។

អ៊ំសៀន ៖ “ផ្ទះយើង! ផ្ទះយើង! យ៉ាងណាហើយ!” អារម្មណ៍គាត់ជិតជាប់នឹងផ្ទះក្បឿងសង់ថ្មីរបស់គាត់ ។ អើតឡឹមៗ ម្តងទៀត យកដៃឈ្ងីភ្នែក បង គង់ មុជក្បាលភ្លឹបមកវិញ ស្រែកវ៉ាស ឡើង “ផ្ទះយើងហុយផ្សែងជុកហើយម៉ែ មិនដឹងជាយ៉ាងណាទេ” ។

មួយថ្ងៃទល់ល្ងាច មួយយប់ទល់ភ្លឺនៅក្នុងលេណដ្ឋាន ។ ព្រលឹមស្រាងៗហើយ ឥតឮមាន់រងាវសោះ! យប់នេះ មាន់ឥត ហ៊ានរងាវទេ ហើយក៏មិនហ៊ានដេកលើទ្រុកដែរ នាំគ្នាហើរទុំលើ ចុងឈើខ្ពស់ៗតាមដើងរបង នៅទីណាដែលមានព្រៃទ្រុពទ្រុលនាំ គ្នាពួនក្រាបកំប្រោនហាក់ដូចជារងាររញាក់ ។ “សូម្បីតែបក្សីបក្សា សត្វក៏ភិតភ័យតក់ស្លុតនឹងស្នូរកាំភ្លើង លែងដឹងយប់ថ្ងៃអ្វីទាំងអស់ ។

ក្រោយពីស្ងប់គ្រាប់ យើងចេញពីលេណដ្ឋានមកមើលផ្ទះ ភ្លាម គ្រាប់ដែលធ្លាក់ជិតបំផុតនោះ មានចម្ងាយដប់ម៉ែត្រខាងមុខ ផ្ទះអ៊ំ សៀន សសរជួរមុខបី របែកច្រៀកដូចគេពុះពីក្រោមដល់ដី ដោយសារសម្ពាធនៃកម្លាំងផ្ទុះរំសេវ ផ្ទះមួយចំហៀងបាក់ស្រុត និងខ្លោចរោលខ្មៅ ក្បឿងរបើកហើរធ្លាក់ពាសពេញភូមិ ផ្ទះអ៊ំ សៀន ក្លាយជាដំបូលប្រក់មេឃ ជញ្ជាំងផ្ទះដាច់ធ្លាក់រយ៉ាក និង ជាប់ដោតដោយអម្បែងអេក្វារាប់សិបនៅតាមសសរ ឃ្នាប រ៉ត និងរនូតរណែងផ្ទះ ដើមឈើដែលដាំព័ទ្ធរបងមុខផ្ទះ ដាច់មែកធាង ធ្លាក់ចុះដូចគេកាប់ ប្រសិនបើពុំមានដើមឈើរងអេក្វាពីមុខទេ ប្រហែលជាគេហដ្ឋាននេះត្រូវរងគ្រោះធ្ងន់ជាងនេះទៅទៀត ។ សសរជង្រុកមួយបានបាក់លុតជង្គង់ចុះ ជញ្ជាំងជង្រុកមួយចំហៀង ដាច់ធ្លាក់ចុះ ស្រូវក្នុងជង្រុកហូរចេញអស់បីភាគបួន ហើយរោល ខ្លោចទៅដោយផ្សែងរំសេវ ពីថ្ងៃនេះទៅ យើងត្រូវតែទ្រាំលេប អង្ករដែលឈ្ងៀមខ្លោចនេះ ហើយនឹងត្រូវដាច់ស្បៀង ក្នុងរវាង ២-៣ខែខាងមុខទៀតផង ។ ភូមិករទាំងមូល ក្លាយជាទីរហោស្ថាន ។

សមរភូមិក្តៅព្រៃកណ្តៀងដែលជាទីតាំងបន្ទាយធំ និងជា

ខ្សែលីញទី១ របស់កងទ័ព សម្ព័ន្ធមិត្តនៃទាហានរដ្ឋាភិបាល លន់ នល់ ជាមួយនឹងទាហានវៀតណាមខាងត្បូង (វៀកយ៉ា) ។ សមរភូមិបាបោងលើ បាបោងក្រោម ត្រូវបានបាក់ទ័ព និងកាត់ផ្តាច់មិនឲ្យមករួម កម្លាំងគ្នាជាមួយបន្ទាយព្រែកល្អៀងបាន ។ បាបោងលើ បាបោងក្រោម ជាបន្ទាយស្ថិតនៅម្តុំពាក់កណ្តាលផ្លូវជាតិ ព្រៃវែង-អ្នកលឿង ហើយមានតួនាទីជាប៉ុស្តិ៍ប៉មការពារទីរួមស្រុកពាមរក៍ និងកំពង់ចម្លងអ្នកលឿង តទល់គៀកស្នាគ្នានឹងបន្ទាយព្រែកល្អៀង ដែលមានតួនាទីជាប៉ុស្តិ៍ប៉មការពារទីរួមខេត្តព្រៃវែងយ៉ាងដូច្នោះដែរ ។

ព្រលប់មួយប្រមាណម៉ោង៦ល្ងាច នៅបន្ទាយព្រែកល្អៀងបានលាន់រំពងទៅ ដោយស្នូរផ្ទុះអាវុធយ៉ាងទ្រហឹងអឺងអាប់ ។ ក្រាកៗ ប្រាវៗ ជាស្នូរនៃគ្រាប់អាកា ឌឹកៗៗ ជាស្នូរកាំភ្លើងសេរិនធីណៃ និងប៉ក់ក្ដូងៗៗ ជាស្នូរជំនួយនៃកាំភ្លើងត្បាល់បាញ់ផ្លោងមកពីទីរួមខេត្តព្រៃវែងផង និងពីទីរួមស្រុកពាមរក៍ផង ។

អ៊ំ សៀន ដែលដឹងច្បាស់ថាកូន ហម របស់គាត់ជាមេបញ្ជាការបន្ទាយព្រែកល្អៀង ហើយកូន កន របស់គាត់ជាមេបញ្ជាការទ័ពរំដោះដែលដឹកនាំការវាយឆ្មក់សមរភូមិព្រែកល្អៀងបាបោងលើកមុនៗនោះ គាត់លើកដៃទូលមេឃ ស្ទាបដែនដីបន់ស្រន់ សូមឲ្យតែអ្នកទាំងពីរបេះត្រូវរ៉ូវនឹងគ្នា ដោយកុំចាំបាច់បង្ហូរឈាម ។ គាត់សំបូងសង្រួងអស់ហើយ គុណរតនត្រៃយ៍ទាំងបីថា «សូមគុណព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ» ជួយថែរក្សាកូនខ្ញុំទាំង សង្ខាងឲ្យមានសេចក្តីសុខ សូមឲ្យគ្រាប់រំសេវទាំងឡាយត្រូវបរវៀសចៀសឆ្ងាយ សូមឲ្យខ្សែលោហិតដែលហូរខ្លាយចេញពីសារពាង្គកាយម៉ែតាមថែជីវិតកូនមាសព្រលឹងទាំងពីររបស់ម៉ែ ។

វរសេនីយ៍ឯក ហម ៖ ក្រោយពីការផ្ទុះអាវុធដូចលាចផ្ទុះបានថយរិទ្ធិទៅ លោកវរសេនីយ៍ឯក ហម មេបញ្ជាការទ័ពរដ្ឋាភិបាលឆ្លុះកែវយិត ឃើញបង កន របស់គាត់ (មេបញ្ជាការខាងទ័ពរំដោះ អ្នកទាំងពីរសុទ្ធតែជាកូនអ៊ំ សៀន) ពួននៅគល់ត្នោតអែបឡាននេះ ។ ការសន្ទនារវាងបងប្អូនប្រុសទាំងពីរនេះ ត្រូវបានលាន់ឮរំពងពេញភូមិ ។ គឺលោកបងទេឬ? បងប្រុសជាទីគោរព លោកបងជាអ្នកបួសសាលាវត្ត ប្អូនជាអ្នករៀនពីសាលារាជការ លោហិតយើងនៅតែត្របាញ់រកគ្នា ។

សមមិត្ត កន ៖ ត្រូវហើយអាប្អូន! បួសដោយវត្ត ចិត្តដោយខ្លួន ។ ឯងកើតចេញពីខ្សែលោហិតជាមួយយើងឈាមជ័រយើងជាឈាមកសិករ ហេតុអ្វីក៏ឯងធ្វើខ្លួនជាឧបករណ៍ចក្រពត្តិ? ក្បត់វណ្ណៈធាតុខ្លួនឯង ទៅធ្វើជាឆ្កែបម្រើអាយ៉ងអាមេរិក ។ កង់ប្រវត្តិសាស្ត្របដិវត្តន៍នឹងកិនបំបែកក្បាលពួកឯង ។ ឯងគួរតែចុះចូលជាមួយយើង ។

វរសេនីយ៍ឯក ហម ៖ លោកបងទៅធ្វើការជាមួយប្អូនវិញទៅ មេបញ្ជាការប្អូនសន្យាថា នឹងបំពាក់ឋានន្តរស័ក្តិជូនបងជាវរសេនីយ៍ត្រី ។

សមមិត្ត កន ៖ ឯងកុំយកមាសប្រាក់ស័ក្តិយសមកធ្វើជានុយប៉ុនប៉ងអូសទាញយើង អាឆ្កែចក្រពត្តិ បេះដូងអ្នកបដិវត្តន៍ស្នេហាជាតិដូចយើង មិនលក់ក្បាលឲ្យអាយ៉ងចក្រពត្តិ ដែលទម្លាក់គ្រាប់បែកដុតបំផ្លាញផ្ទះសម្បែងអ្នកស្រុក សម្លាប់ជីវិតសត្វពាហណៈ និងជីវិតប្រជាជនខ្មែរស្លូតត្រង់គ្មានឈប់ឈរយ៉ាងនេះទេ ។

វរសេនីយ៍ឯក ហម ៖ យើងជាបងប្អូនរួមផ្ទៃ ខ្ញុំមិនជឿថាបងដាច់ចិត្តបាញ់ខ្ញុំទេ ។

គ្រាប់កាំភ្លើងមួយបង់តភ្ជាប់គ្នាដូចគ្រាប់ភ្លៀងបានហូរស្រោចមកជិតជើងគាត់ លោកវរសេនីយ៍ឯក ហម ស្រឡាំងកាំងរកពាក្យអ្វីនិយាយតបទៅបងប្រុសរួមផ្ទៃជាមួយលែងកើត កាំភ្លើងគាត់នៅនឹងដៃ តែគាត់គ្មានសេចក្តីក្លាហាននឹងតម្រង់កាណុងទៅរកបងសោះ ។ គាត់ដឹងថា បងគាត់ដៃត្រង់ណាស់ បើគាត់ដាច់ចិត្តសម្លាប់ប្អូនច្បាស់ជាគេចមិនរួចឡើយតែមួយបង់អម្បាញ់មិញនេះ ច្បាស់ជាគ្រាន់តែជាការព្រមានប្អូនហើយ ។ ហម ខំតាំងស្មារតីបោះជំហានឲ្យកាន់តែជិតបងដើម្បីបង្ហាញឲ្យបងឃើញនូវទំហំនៃសេចក្តីស្រឡាញ់របស់គាត់ចំពោះបង ។

គាត់ចាប់ផ្តើមដឹងខ្លួនថា ជើងស្តាំរបស់គាត់ហាក់ដូចជាមិនគោរពបញ្ជាគាត់ឡើយ ខំបញ្ជាវាជាលើកទី២ គាត់ហាក់ទទួលអារម្មណ៍ថា មានការឈឺចាប់ខ្លាំង គាត់ឈ្ងោកសម្លឹងវាភ្លាម ឃើញជើងខោគគីរពណ៌បៃតងរបស់គាត់ជោគទៅដោយឈាមក្រហមឆ្អៅ គាត់ងងឹតមុខស្ទុប ស្រែករោទ៍គ្រលួចដោយការឈឺចាប់ឥតគណនា «អូយ! យូយ! ជើងខ្ញុំ ត្រូវគ្រាប់ហើយ! អូយ! ជួយផង!ៗ» ។ គាត់ដួលព្រុសសន្ធប់បាត់មាត់ឈឹង ។ សមមិត្ត កន

បញ្ជាឲ្យកងទ័ពបាញ់សម្លាប់សម្រុកទៅលើគូសត្រូវស៊ីសាច់ហុត ឈាមបម្រុងចូលចាប់ខ្លួនទាំងរស់ ឬកាត់ក្បាលមេបញ្ជាការ ហម ទៅជូនអង្គការថ្នាក់លើ ប៉ុន្តែពេលនោះ ម៉ោង ៦ភ្លឺ ហើយយន្តហោះ ស្ទាបកាត់បានមកដល់ល្មម ផ្អែលក្រឡឹងជារង្វង់លើលានប្រយុទ្ធ អមដោយយន្តហោះមិចមួយគូ រេចាក់ផែល ង៉ារចុះ! ង៉ារឡើង! ប្រកិតពីក្រោយជង ។ ព្រះអាទិត្យចាំងពន្លឺកាន់តែច្បាស់ហើយ ជាទូទៅទ័ពខ្មែររំដោះខ្លាចពន្លឺថ្ងៃណាស់ ពួកគេខ្លាំងពូកែនៅពេលយប់ ដូចពស់ស្រកាចាស់ ហើយពេលថ្ងៃក៏រសាយទ័ពចេញដូចក្រមួនត្រូវថ្ងៃ ។ កន ក៏បញ្ជាឲ្យកងទ័ពខ្មៅលាក់ខ្លួនចាកចេញពីសមរភូមិ ទៅតាំងក្តោបក្រហាយ ។

បែរមកមើលខាងក្រុមគ្រួសារទាំងបីនៃអ្នកភូមិស្តៅ ដោយទ្រាំទ្រលែងបាននឹងភាពស្ងាត់ជ្រងំក្នុងភូមិ និងដោយសំឡេងរោទិ៍ទ្រហឹងអឺងអាប់របស់យន្តហោះ ធ្វើឲ្យសេចក្តីភ័យខ្លាចកាន់តែកើនឡើងហួសកម្រិត ។

អ៊ំ សន ៖ ប្រហែលជាយើងគិតខុសហើយ អ្នកភូមិគ្រប់រូបគេគិតត្រូវបានជាគេមូលមតិគ្នារត់ចេញពីភូមិទៅជ្រកពួនក្នុងព្រៃនាម ណ្ហើយចុះ បើអ្នកស្រុកស្លាប់អស់ នៅតែយើងបីគ្រួសារនេះ ក៏រស់មិនកើតដែរ គួរតែរត់លូនទៅព្រៃនាមនឹងគេ ឆាប់រស់ជាមួយគេឯងទាំងអស់គ្នាចុះ ។ លោកឪពុកខ្ញុំធ្វើសេចក្តីសម្រេចចិត្តនាំមុខ ក្រុមគ្រួសារទាំងអស់ក៏មូលមតិគ្នា គ្រួសារទាំងពីរ ក៏រូតរះរៀបចំអង្រឹងស្នែងសែងលោកយាយ ម៉ៅ ក្រាបលូនតាម គម្ពោតព្រៃរបោះតូចៗ សំដៅចូលព្រៃនាមធំដីបូកប្រយ៉ាបដែលមានចម្ងាយប្រមាណ២-៣គីឡូម៉ែត្រ នៅចន្លោះឆៀងខាងក្រោយភូមិស្តៅ និងភូមិពន្ទៃ ។ តាមបណ្តោយផ្លូវធ្លាដែលទក់ទីដោយស្នាមកង់រទេះរបស់អ្នកស្រុក ។

លោកឪពុក ៖ យើងគិតខុស គិតទៅគេអ្នករត់កាលមិនទាន់ភ័យមែនទែន គេបររទេះ ដឹកអីវ៉ាន់មកស្រួលៗ ។ យើងនៅរហូតដល់ទឹកឈ្លក់ច្រមុះទើបរត់ទាំងវេទនាយ៉ាងនេះ ហ៊ានបររទេះឯណា បើយន្តហោះវឺៗលើក្បាលយ៉ាងនេះ ។ អង្ករ ចាន ឆ្នាំង ក៏យកមកមិនបានច្រើននឹងគេ ។

អ៊ំ សៀន ៖ លោកប្អូនរកកន្លែងក្រាបសិន មើលកន្ទុំរុយ២គ្រឿងនោះកំពុងផ្អែលក្រុម ទ័ពខ្មៅមួយក្រុម ដែលផ្តុំគ្នាបាំងមែកឈើនៅក្រោមដើមជ្រៃជិតទួលសំរោងនោះ វាផ្អែល ផ្អែលឆាបខ្លាំងណាស់ ។ ខ្ញុំខ្លាចតែក្រុមលោកកូន កន ទេ! កងទ័ពមួយក្រុមនេះទំនងជាទើបដកចេញពីការវាយប្រហារឯផ្ទាល់ជាតិយប់មិញនេះ ។

អ៊ំ សៀន អារម្មណ៍គាត់ជិតជាប់នឹងកូនប្រុសមាសព្រលឹងទាំងពីរដែលបម្រើទ័ពទាំងសងខាង គាត់មមៃពីសុខទុក្ខកូនខ្លាំងណាស់ ។ គាត់មានសភាពជាស្ត្រីដែលមានដើមទ្រូងឈឺចុកចាប់ស្ទើរប្រេះធ្លាយ ។

យន្តស្ទាបកាត់មួយគ្រឿងដែលនៅរេប្រចាំការលើសមរភូមិព្រៃកណ្តៀងនោះបាន បែរមករកទួលសំរោង រេចុះ រេឡើងមួយសន្ទុះ ស្រាប់តែមានខទ្វម្ភាគចក្រ២គ្រឿងហោះ ហើរពីទិសខាងលិចដែលយើងសន្និដ្ឋានបានថា មកពីភ្នំពេញ បានធ្វើប្រតិបត្តិការក្រឡឹង ទួលសំរោង ឯយន្តស្ទាបកាត់ និងយន្តហោះអាមេរិក២គ្រឿងផ្អែលផ្លៀងចុះ ផ្លៀងឡើង គ្រលែងខ្លួនសម្តែងឫទ្ធិកក្រើករេហា ខទ្វម្ភាគចក្របោះពួយង៉ារចុះ ងើបក្បាលឡើងវិញ ង៉ោងៗ គ្រាប់ភ្លើងដេញទន្ទុះថ្ងៃព្រាកៗ ទាំងកណ្តាលថ្ងៃត្រង់ ចាំងពេញមេឃា ស្ទើរខ្ទាក់គ្រាប់ភ្នែក កងទ័ពខ្មៅជ្រួលឆ្វាចុះឆ្វាឡើងវិលជុំវិញគល់ជ្រៃ ។ អ៊ំ សៀន ថប់អារម្មណ៍ណាស់ថា ក្នុងក្រុមនោះអាចមានលោកកូន កន របស់គាត់ ។

ក្រុមនោះទំនងជាមានអ្នកត្រូវរបួសធ្ងន់ហើយ ព្រោះឮសំឡេងថ្ងូរគ្រលួចមានពីរនាក់ក្រាបនៅស្ងៀម លែងរត់គេចយន្តហោះទៀតហើយ ។

កូនគេ កូនខ្ញុំ សូមព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ លោកជួយរក្សាជីវិតកូនចៅខ្ញុំទាំងសងខាងឲ្យបានសុខ ។ ទួលជ្រៃស្ថិតចម្ងាយប្រមាណ១គីឡូម៉ែត្រប៉ុណ្ណោះ ខាងជើងរនាម ដីបូកប្រយ៉ាប ចន្លោះពេលដែលកន្ទុំរុយបែរក្បាលទៅលិចវិញ ទំនងជាអស់គ្រាប់ហើយហើយត្រូវត្រឡប់ទៅភ្នំពេញវិញ ដើម្បីយកគ្រាប់បន្ថែម នៅមិនបានទេ អ៊ំ សៀន បង ម៉ាច (កូនស្រីទី៦របស់អ៊ំ សៀន) និងបង គង់ បានចាកចេញពីក្រុមគ្រួសារទៅតាមមើលកងទ័ពរំដោះ ។ ប្រមាណ ៣០ម៉ែត្រ មុនទៅដល់កងទ័ពខ្មៅ អ៊ំស្រែកឡើងថា លោកកូន! លោកកូន! ម៉ែសង្ស័យយូរហើយថា លោកកូន ត្រូវរបួសមែន?

បង កន ៖ ម៉ែៗ មកពីណា មើលកូនកូនឈឺចុកចាប់ណាស់ម៉ែ តែមិនអីទេកូនទ្រាំបាន សូមម៉ែតាំងស្មារតីកុំតក់ស្លុតធ្វើអ្វីម៉ែ គង់

និង ម៉ាច មកចំពេលហើយ សូមម៉ែឲ្យប្អូនទាំងពីរទៅជាមួយកូន ទៅជួយមើលថែកូន និងរួមចំណែកតស៊ូបដិវត្តន៍ជាមួយកូន ។

បង គង់ ៖ កូនសុំទៅតាមលោកបងហើយ សូមម៉ែកុំឃាត់កូន កូននៅស្ងៀមឱបដៃ គទៅទៀតមិនសុខទេ ។ កូនក៏មិនអាចទ្រាំមើលចក្រពត្តិប្រើអាវុធយុទ្ធភណ្ឌបំផ្លាញមូលដ្ឋាន ភូមិស្រុកយើងបែបនេះដែរ ។

បង ម៉ាច ៖ រស់នៅក្នុងភូមិឃុំ ក៏នៅតែរត់គាត់គ្រាប់រំសេវដែរ សូមម៉ែឲ្យកូនទៅមើល ថែលោកបងទៅ ។

អ៊ំ សៀន មានតែទឹកភ្នែក ហឹតហត់ គាត់និយាយពុំចេញ បេះដូងគាត់ចុកចាប់ដូចគេហែកជាមួយរយចម្រៀក ពីព្រោះបើគាត់ឃាត់ គង់ ទុក ហាក់ដូចជាមិនអាណិត កន ដែល ត្រូវការប្អូនៗជួយមើលថែពេលមានរបួស ម៉្យាងទៀត ដោយ កន នេះចេះតែបញ្ឆោទ័ពឲ្យទៅមុខឲ្យបានឆាប់ទាន់ឱកាសដែលយន្តហោះបែរទៅផ្តោតប្រតិបត្តការរបស់វាលើសមរភូមិព្រៃកណ្ដៀង ។ អ៊ំទន់ជង្គង់ទៅហើយ ទោះគាត់ខំរត់ដេញតាមពីក្រោយកងទ័ព តាមមើលមុខរបួសកូនគាត់ឲ្យប្រាកដថាត្រូវត្រង់ណានោះ ក៏ដេញមិនទាន់ឡើយ ជរាភាពមិនគោរពសម្បជញ្ញៈគាត់ឡើយ គាត់ក៏ស្រែកផ្ដាំថា អន្ទិត គង់ និង នាង ម៉ាច! មើលថែបង ថែខ្លួនផងកូនណា!

យុគសម័យនៃការចាប់ផ្ដើមសង្គ្រាមដើមដំបូងនេះ ស្ថានភាពនៃសន្ទុះទឹកចិត្តក្លៀវក្លារបស់យុវជនយុវនារីខ្មែរ មិនខុសអ្វីពីទ្រឹស្ដីនៃបដិវត្តន៍ក្រហមឆ្អិនឆ្អៅដែលខាងកងទ័ព ខ្មែររំដោះតែងលើកឡើងថា កងទ័ពបដិវត្តន៍ប្រសូត្រឡើងពីដេះដង់កម្ទេចគ្រាប់បែកគ្រាប់ផ្លោងរបស់ចក្រពត្តិ ។

ស្ត្រីចំណាស់ដែលមានបេះដូងប្រេះឆ្ងាយមួយរយចម្រៀក ខំត្រដរលូនក្រាបសសៀរតាមព្រៃល្បះ ដើម្បីលាក់ខ្លួនពីយន្តហោះ រត់មកកាន់ក្រុមគ្រួសារគាត់ដែលកំពុងតាមគយគន់ទៅទិដ្ឋភាពដ៏ចុកចាប់នោះយ៉ាងសោករន្ធត់រកថ្លែងពុំបាន ។ បេះដូងអ៊ំស្រែកខ្ទាំនថា ព្រលឹងមាសម្ដាយអើយ! សូមគុណទឹកដោះម្ដាយតាមថែរក្សាអាយុជីវិតកូនទាំងបួននាក់តរៀងទៅ ។

ក្នុងព្រៃរនាម ដែលមានទំហំរាប់សិបហិកតា ប្រជាជនមកពីភូមិស្ដៅ ពន្ទៃ ព្រៃកណ្ដៀង បានចូលពួនពីងពាក់ស្នាក់អាស្រ័យពីរយប់ហើយ ព្រៃទាំងមូល តាំងពីវាលរនាម បន្ទាយដេក ដំបូកប្រយ៉ាប រហូតដល់ឫស្សីមួយគុម្ព ហាក់មានសភាពញាប់ញ័ររកងរំពង ដោយចំនួនមនុស្សកុះករ ។ តាំងពីម៉ោង៩ព្រឹកមក យន្តហោះស្ទាប់កាត់២បោះពួយ ដាំចុះ ដាំឡើង ក្រឡឹងព្រៃគ្មានឈប់ឈរ ។ តើពួកគេកំពុងចង់ស្វែងយល់ថា ហ្វូងមនុស្សដើរផ្ដើព្រៃនេះ ជាទ័ពរំដោះ ឬជាអ្នកស្រុកឬយ៉ាងណា? បើគេដឹងច្បាស់ថា ពួកយើងជាអ្នកស្រុក ឥតកាន់អាវុធ តើគេនៅតែទម្លាក់គ្រាប់បែកសម្លាប់ទៀតឬយ៉ាងណា? ឬមួយក៏ពួកគេមិនអាច មើលឃើញអ្វីច្បាស់លាស់ទេ ឲ្យតែសង្ស័យគិតតែពីទម្លាក់គ្រាប់បែកឬយ៉ាងណា? តើមាននរណាអាចបកស្រាយចម្ងល់សន្ទុះសង្ស័យស៊ើរដាច់ប្រមាត់នេះបាន ។

ពូ សន ៖ គេមានកែវយឺត អាចឃើញយើងនៅនឹងភ្នែក

ឪពុកខ្ញុំ ៖ តែយើងនៅក្នុងព្រៃ ទោះបីកែវយឺត ក៏វាមិនអាចឃើញច្បាស់ដែរថា តើនរណាជាទ័ព នរណាអ្នកស្រុកនោះ ។

អ៊ំ សៀន ៖ ឱ! ស្ដាយណាស់! នៅឯភូមិមានលេណដ្ឋានគ្រាន់នឹងជ្រកពួន សុខៗមិននៅបែរជានាំគ្នារត់ចូលព្រៃ តើបានអ្វីជាទីពឹង ។

«កូនអើយ! ចៅអើយ! ងាប់អស់ហើយយ៉ាងនេះ!» ។ លោកយាយ ម៉ៅ របស់ខ្ញុំ ទោះបីជាគាត់ស្ទាប់មួយចំហៀងខ្លួនវង្វេងស្មារតីយ៉ាងធ្ងន់ធ្ងរយ៉ាងណាក្ដី ក៏គាត់នៅតែយល់ច្បាស់អំពីមរណៈភ័យនេះដែរ ។ នៅពេលស្នូរគ្រាប់ផ្លោង គ្រាប់បែកផ្ទុះឡើងក៏ដូចជា ស្នូរយន្តហោះបោះពួយង៉ាវៗ លោកយាយទន្ទេញ ពុទ្ធោ! ធម្មោ! ជាប់នឹងមាត់ ដៃរាវប្រវ៉ា ចាប់អ្វីៗទាំងអស់ ដែលគាត់អាចប៉ះវាបាន ។

យន្តហោះឆ្អែលវ៉ាវចុះ វ៉ាវឡើង កាន់តែរន្ថើនឡើង ទ្រូងតឹងស៊ើរប្រេះគ្រប់គ្នា ម្នាក់ៗ មុខស្លាស់បាត់អស់ព្រលឹង ។ នោះ! គ្មានព្យុះសូរសោះមកដល់ទៅហើយ វ៉ាវៗ យន្តហោះ ប្រតិកម្មអាមេរិកបីគ្រឿងទៀត សុទ្ធតែមានល្បឿនលឿនជាងសំឡេង ឆ្អែលប្រកិតតាមក្រោយយន្តហោះអាមេរិកពីរគ្រឿងលើកមុន ហាក់ដូចតម្រៀបគ្នាជាក្បួន១-២-៣ ក្នុងគំលាតចម្ងាយពីគ្នាយ៉ាងថេរដោយល្បឿនស្មើគ្នា ស៊ីចង្វាក់ផ្លៀងផ្លូង គ្រលែងខ្លួនបង្ហាញរាងធ្វើឲ្យយើងមើលឃើញច្បាស់នូវគ្រាប់បែកដ៏ធំៗ ដែលផ្ទុកនៅក្រោមស្លាបទាំងសងខាងរបស់វា ។

*ពុទ្ធោ! ពុទ្ធំ! សំឡេងថ្ងូរណែនគល់កហាក់គ្មានដង្ហើមក្នុងទ្រូង លាន់ឮគ្រប់ទិសទីក្នុងព្រៃរនាម ។*

*មីង ង៉ាន ស្ត្រីវ័យកណ្តាលម្នាក់ ជាអតីតខ្មែរកម្ពុជាក្រោម គាត់ជាភរិយារបស់ពូ ចេវ អតីតទាហានខ្មែរឥស្សរៈ គាត់បានតាមប្តីមករស់នៅភូមិស្តៅតាំងពីក្រោយឯករាជ្យ គាត់បានប្រាប់ថា «យើងត្រូវតែនាំគ្នា ពរកូន ពរចៅ ចេញពីក្នុងព្រៃ ទៅឈរឲ្យកុះករលើទួល លើកសំពត់ស ឬចានដែកស ល្អឹកញើ គ្រវីជាសញ្ញាឲ្យយន្តហោះ មើលឃើញច្បាស់ថា យើងគឺជាប្រជាជន ភាន់ច្រឡំដោយការភិតភ័យនឹងសង្គ្រាមពេក រត់ចោលភូមិមកជ្រកពួន នៅក្នុងទីព្រៃនេះ ខ្ញុំធ្លាប់រត់សង្គ្រាមអាមេរិកាំងតាំងពីក្មេង ជឿខ្ញុំទៅ! បើបន្តរង់យូរ យើងនឹងស្លាប់រលពេញព្រៃ!» ។*

*ឪពុកខ្ញុំ ៖ សមហេតុសមផលហើយ តោះយើងចេញតាមអ្នកង៉ាន ទៅ ។ យើងត្រូវបង្ហូកហៅគ្នាឲ្យចេញមកលើទួលវាលមាត់ព្រៃនេះឲ្យបានច្រើន បើចេញទៅវាលអាចរស់ អាចស្លាប់ បើនៅសម្ងំក្នុងព្រៃឃើញតែសេចក្តីស្លាប់តែមួយមុខទេ ។ ព្រះតេជគុណព្រមនិមន្តចេញទៅលើទួលទេ? ។ចម្រើនពរ! អាត្មាក៏យល់ស្រប ដែរ ។ ព្រះចៅអធិការ និងព្រះសង្ឃវត្តស្តៅទាំងអស់ក៏និមន្តចូលព្រៃជាមួយអ្នកស្រុកដែរ ។*

*នៅលើទីវាលរាប់សិបហិកតា បណ្តោយមាត់ព្រៃរនាម ដែលក្រាលដោយគុម្ពស្បូវ ពណ៌បៃតង មនុស្សដូចស្រមោច បានលើកកូនង៉ែតតូចធំបង្ហាញយន្តហោះ ព្រះសង្ឃគ្រងស្បង់ក្រហមប្រាលទាំង៧អង្គ ក៏ស្ទុះគ្រចេញគ្រវីស្បង់សុំជីវិតពីយន្តហោះដែរ ។ យន្តហោះ ស្វាបកាត់ដាំចុះកាន់តែទាបមែនទែន ង៉ាវចុះ ង៉ាវឡើង ហើយក៏បត់ក្បាលតម្រង់ទៅថ្ពល់ជាតិ ដោយយន្តហោះអាមេរិកទាំង៨គ្រឿង ប្រកិតតាមជានិច្ច ។ ផ្លែលង៉ាវចុះ ង៉ាវឡើង ផ្សៀងផ្សងទំនងជាពិនិត្យមើលហេតុការណ៍ឲ្យជាក់ស្តែង ។ អ្នកស្រុកទាំងនៅលើ ទាំងក្នុងព្រៃ កំពុងសន្ធិះគានតឹងក្នុងទ្រូង ស្ទើរប្រេះបែក បើវាបន្ទាបខ្លួនរំពងខ្សុរដីយ៉ាងនេះ តើម៉ោងណា នាទីណាមួយ មុខជាមួយគ្រាប់ផាំងចំកណ្តាលហ្វូងមនុស្សនេះឬយ៉ាងណា? តើរៀបនឹងស្លាប់ឈឺចុកចាប់ដល់កម្រិតណា? យន្តហោះស្វាបកាត់បត់ក្បាលង៉ាវទៅទិសខាងកើត ។*

*«នោះៗ យើងរស់ហើយ អាស្វាបកាត់បាញ់ផ្សែងស ឯលើថ្ពល់ជាតិរួចហើយ!» ។ សម្រែកដោយអំណររបស់ហ្វូងកសិករ ។*

*ភ្នែកប្រជាកសិកររាប់ពាន់គូ សម្លឹងទៅផ្សែងស ដែលចេញពីយន្តហោះស្វាបកាត់ ហើយចេះតែភាយធំៗឡើងដូចជាអព្ភជាសពេញអាកាស ។ យន្តហោះអាមិចពីរគ្រឿងដាំក្បាលចុះង៉ាវ ទាបទៅៗ ។ រហូតបាំងបាត់នឹងកំពូលព្រះវិហារព្រៃកណ្តៀងឲ្យប្រហែលជាគ្រាប់មួយគ្រាប់របស់កងទ័ពខ្មៅធ្លាក់ទៅហើយទេដឹង? ទេមិនមែនទេ វាងើបឡើងវិញហើយ ហើយបោះពួយទៅទិសខាងជើង ទន្ទឹមគ្នាដូចក្បួនដែលរៀបឥតខ្ចោះ សំឡេងង៉ោងៗរោទ៍ឡើងតាមក្រោយជាមួយនឹងផ្សែងខ្មៅខ្នួលខ្នាញ់ត្របាញ់ពីដីឡើងទៅលើមេឃ ព្រមទាំងស្នូរគ្រាំងៗកក្រើកដីញ័ររញ្ជួយខ្សុរដើមទ្រូងប្រជាកសិករដែលនៅឈរលើវាលស្បូវចម្ងាយ ប្រហែល៤គីឡូម៉ែត្រពីកន្លែងប្រតិបត្តិការនោះ ស្ទើរតែប្រេះទ្រូងហួរឈាម ។ ព្រៃព្រឹក្សាញ័ររកក្រើកប្រជាកសិករក្រាបចុះត្រៀប ក្មេងតូចៗស្រែកយំយ៉ៃៗប្រវាឱបឪពុកម្តាយដោយសភាពញ័ររញ្ជាក់សព្វសាច់ ។*

*យន្តហោះអាមិច២គ្រឿង ងើបឡើង យន្តហោះ២ទៀតដាំចុះង៉ាវ យន្តហោះអាមិច ៤ បត់ក្បាលតម្រង់ភ្នំពេញ យន្តហោះអាមិច៤គ្រឿងទៀត ហក់មកពីភ្នំពេញដល់លំហប្រតិបត្តការល្មម ហើយក៏បន្តបេសសកម្មកំណាច ដូចហ្វូងឥន្ទ្រី សម្តែងរិទ្ធិ និងប្រកបដោយយុទ្ធសាស្ត្រ រៀបចំផែនការយ៉ាងជាក់លាក់ណាស់ ។*

*សំឡេងឆ្លើយឆ្លងរបស់ប្រជាកសិករៈ*

*ឱ! អស់ហើយផ្ទះសម្បែង គោក្របី ស្រូវជង្រុក មាន់ទាគ្មានសល់អ្វីទេ ។ យើងខំកាប់ឆ្ការរុករានទន្ទ្រានដីទម្រាំបានកវែកកន្លាំប៉ុណ្ណេះ ញើសហូរជាឈាម ។ តាំងពីដឹងក្តី ចេះធ្វើស្រែ ស្ទើរជ្រុះក្បាលជង្គង់រិចអស់ទាំងកែងជើង ស្រូវមិនដែលបានថ្លៃដូចឆ្នាំនេះទេ ។ ដល់ពេលស្រូវបានថ្លៃ មិនត្រឹមតែមិនបានលក់ទេ ថែមទាំងអត់បានហូបទៅទៀត យើងត្រូវអត់បាយក្រហាយទឹកទៀតផង ។ ជាសំឡេងទួញថ្ងូរលាន់ជ្រែកបំពង់ករបស់ហ្វូងកសិករគ្រប់រូបនៅលើទីទួលវាលប៉ប្រះមាត់ព្រៃដំបូកប្រយ៉ាប់នេះ ហើយបើតាមទ្រឹស្តីពុទ្ធទំនាយ «នេះបានចំជាមានផ្ទះអត់មនុស្សនៅមានស្រូវអត់មនុស្ស ហូបមែន» ។* **(តទៅលេខក្រោយ)** **អ៊ុំ ចណ្ណា**

# ដំណឹងស្វែងរកបងប្អូន

ខ្ញុំបាទឈ្មោះ ផុន សារួន រស់នៅភូមិពោធិ៍ស្នាយ ឃុំព្រៃឃ្នេស ស្រុកមេសាង ខេត្តព្រៃវែង ។ សូមប្រកាសរកបងប្រុសបងស្រី ដែលបានបាត់ខ្លួនក្នុងរបបខ្មែរក្រហម ដូចមានរាយនាមដូចខាងក្រោម ៖

១) កុន ចាន់ថា (ស្រី) កើតឆ្នាំរកា នៅពេលបាត់ខ្លួនមានអាយុ២១ឆ្នាំ ។ បងស្រី កុន ចាន់ថា បានបាត់ខ្លួននៅឆ្នាំ១៩៧៧ នៅពេលដែលខ្មែរក្រហមជម្លៀស និងឲ្យគាត់ទៅធ្វើការនៅជប់ពាមជាំង ស្រុកអូររាំងឪ ខេត្តកំពង់ចាម (ត្បូងឃ្មុំ) ។ បងស្រីធ្វើជាកម្មករនៅរោងចក្រស្លកៅស៊ូ នៅជប់ពាមជាំង ហើយក្រោយមកក៏បាត់ដំណឹងពីគាត់រហូត ។ ចាន់ថា មាឌធំល្មម សម្បុរខ្មៅស្រអែម និងមានកម្ពស់ ១.៥៥ម៉ែត្រ ។

២) កុន សាបី (ប្រុស) កើតឆ្នាំឆ្លូវ នៅពេលបាត់ខ្លួនមានអាយុ១៧ឆ្នាំ ។ បងប្រុស កុន សាបី បានបាត់ខ្លួននៅឆ្នាំ១៩៧៧ អំឡុងពេលដែលខ្មែរក្រហមចាត់គាត់ឲ្យទៅធ្វើទ័ពនៅខេត្តស្វាយរៀង ។ ចាប់តាំងពីពេលចេញទៅធ្វើទ័ពក៏បាត់ដំណឹងពីបងប្រុសរហូត ។ សាបី មាឌធំល្មម សម្បុរខ្មៅស្រអែម កម្ពស់ ១.៦៥ម៉ែត្រ ។ អ្នកទាំងពីរមានស្រុកកំណើតនៅភូមិពោធិ៍ស្នាយ ឃុំព្រៃឃ្នេស ស្រុកមេសាង ខេត្តព្រៃវែង ។ ខ្ញុំមានឪពុកឈ្មោះ ពោច កុន (ស្លាប់) និងម្តាយឈ្មោះ ខាត់ ស៊ី និងមានបងប្អូនបង្កើតចំនួន១៤នាក់ ៖

១) កុន ចាន់ថា (ស្រី) បាត់ខ្លួន

២) កុន សម្បត្តិ (ប្រុស)

៣) កុន សាបី (ប្រុស) បាត់ខ្លួន

៤) កុន សាបន (ប្រុស) ស្លាប់

៥) កុន សាបាន (ប្រុស)

៦) កុន សុកុន (ប្រុស)

៧) កុន សុគៀន (ប្រុស)

៨) កុន សុគួន (ប្រុស)

៩) កុន ចាន់ឡាន (ស្រី)

១០) កុន ចាន់ឌី (ស្រី)

១១) កុន សំអឿន (ស្រី)

១២) កុន សំអួន (ស្រី)

១៣) កុន សារួន (ប្រុស)

១៤) កុន រិទ្ធិ (ប្រុស)

អាស្រ័យដូចបានរៀបរាប់ខាងលើ ប្រសិនបើបងប្អូនណាបានស្គាល់ និងដឹងដំណឹងអំពីបងប្រុសបងស្រីរបស់ខ្ញុំទាំងពីរ ដូចដែលបានរាយនាមខាងលើ សូមមេត្តាទំនាក់ទំនងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជា តាមរយៈអាសយដ្ឋានផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន និងទូរសព្ទ ០២៣ ២១ ៨ ០ ០៩ ឬក៏ទំនាក់ទំនងមកខ្ញុំបាទផ្ទាល់តាមរយៈទូរសព្ទលេខ ០៩២ ២០៤ ៣៦៧ , ០៦៩ ៥៨៣ ៥០០ ឬសារអេឡិចត្រូនិច phunsaroun@gmail.com ។ **សូមអរគុណ!**

# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់ នៅក្នុងរបបខ្មែរក្រហម










មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាង១លាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ វ៉ាន់ថាន់ ពៅដារ៉ា ទូរសព្ទលេខ ០១២ ៨៤៦ ៥២៦ ឬ អ៊ីម៉ែល ៖ truthpdara@dccam.org ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។

**សូមផ្តល់ព័ត៌មានដូចខាងក្រោមៈ**

១) ឈ្មោះអ្នកប្រកាសប្រាប់, ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់, ៤) ភេទអ្នកស្លាប់, ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន), ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍ៈ ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ឬប្អូនស្រី), ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍ ៖ ស្លាប់នៅទីណា? មូលហេតុអ្វី?), ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ), ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍ៈ លេខទូរស័ព្ទ អាស័យដ្ឋាន) ។

**ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោមៈ**

១) ឈ្មោះអ្នកបាត់ខ្លួន, ២) ភេទ, ៣) អាយុ, ៤) ត្រូវជាអ្វី, ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា, ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។

ដើម្បីយុត្តិធម៌និងការចងចាំ
ដែលជាមូលដ្ឋានដ៏សំខាន់ក្នុងការផ្សះផ្សាជាតិ


ឧបត្ថម្ភការបោះពុម្ពផ្សាយដោយ ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ សហរដ្ឋអាមេរិក (USAID)
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម.៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩



**មជ្ឈមណ្ឌលឯកសារកម្ពុជា : ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ : (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ : (៨៥៥) ២៣ ២១០ ៣៥៨
DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.



A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 215, 2017 ◆ Funded by USAID.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.